ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលការណ៍ណែនាំថ្នាក់ជាតិ សម្រាប់ប្រព័ន្ធសុខាភិបាល ស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រីនិងកុមារ

ឆ្នាំ ២០១៤

នាយកដ្ឋានការពារសុខភាព

# មាតិកា


អារម្ភកថា........................................................................................................................I

សេចក្តីថ្លែងអំណរគុណ.........................................................................................................III

ពាក្យកាត់.........................................................................................................................IV

សន្ទានុក្រម........................................................................................................................V

**១ សេចក្តីផ្តើម**...................................................................................................................១

១.១ ហេតុអ្វីត្រូវមានគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រី និងកុមារ?.......................................................................................................................១

១.២ គោលបំណងនៃគោលការណ៍ណែនាំថ្នាក់ជាតិ សម្រាប់ប្រព័ន្ធសុខាភិបាលស្តីពី ការគ្រប់គ្រងអំពើហឹង្សាលើស្ត្រី និងកុមារ.......................................................................................................................១

១.៣ រចនាសម្ព័ន្ធនៃគោលការណ៍ណែនាំ.........................................................................................២

១.៤ តើអំពើហឹង្សាទៅលើស្ត្រីនិងកុមារជាអ្វី?...................................................................................២

១.៤.១ ស្ថិតិថ្មីៗស្តីពីអំពើហឹង្សាទៅលើស្ត្រី និងកុមារកម្ពុជា.................................................................២

១.៤.២ ផលវិបាកផ្នែកសុខភាពរបស់ស្ត្រី និងកុមាររងគ្រោះ....................................................................៣

១.៥ ច្បាប់ និងគោលនយោបាយក្នុងការដោះស្រាយអំពើហឹង្សាលើស្ត្រី និងកុមារនៅកម្ពុជា..............................៤

**២ ការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលទៅនឹងអំពើហឹង្សាទៅលើស្ត្រី**..................................................៦

២.១ គោលការណ៍ណែនាំ.........................................................................................................៦

២.២ ថែទាំស្ត្រីរងគ្រោះដោយអំពើហឹង្សាក្នុងសេវាថែទាំសុខភាពដែលមានស្រាប់...........................................៧

២.២.១ ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលជាតិ.......................................................................................៧

២.២.២កន្លែងថែទាំសំខាន់ៗសម្រាប់ស្ត្រីរងគ្រោះដោយអំពើហឹង្សា..........................................................៧

២.៣ បទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងស្ត្រីរងគ្រោះដោយសារអំពើហឹង្សា .........................................៨

២.៣.១ កញ្ចប់សេវាថែទាំសុខភាពអប្បបរមា......................................................................................៨

២.៣.២ សម្ភារវេជ្ជសាស្ត្រនិងរដ្ឋបាលអប្បរមាតាមកម្រិតសមត្ថភាពរបស់អ្នកផ្តល់ការថែទាំ...........................៩

២.៣.៣ ការបណ្តុះបណ្តាលអប្បបរមាសម្រាប់បុគ្គលិកសុខាភិបាល...........................................................១០

២.៤ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងស្ត្រីរងគ្រោះដោយសារអំពើហឹង្សាក្នុងប្រព័ន្ធសុខាភិបាល.................១០

២.៤.១ ការកំណត់អំពើហឹង្សាទៅលើស្ត្រី......១០

២.៤.២ ការទទួលយកជនរងគ្រោះ......១១

២.៤.៣ ការគាំទ្រដំបូងសម្រាប់អំពើហឹង្សាពីដៃគូស្និទ្ធស្នាល និងអំពើហឹង្សាផ្លូវភេទទៅលើស្ត្រី......១១

២.៤.៤ ការថែទាំបន្ថែមសម្រាប់ជនរងគ្រោះដោយសារអំពើហឹង្សាពីដៃគូស្និទ្ធស្នាល......១២

២.៤.៥ ការថែទាំបន្ថែមសម្រាប់ជនរងគ្រោះពេញវ័យដោយសារការចាប់រំលោភ ឬអំពើហឹង្សាលើផ្លូវភេទ......១៤

២.៤.៦ ការព្យាបាលស្ត្រីរងគ្រោះដោយសារអំពើហឹង្សា......២០

២.៤.៧ ការថែទាំតាមដាន និងការបញ្ជូន......២៣

២.៤.៨ ការចងក្រងឯកសារ......២៤

**៣ ការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលទៅនឹងអំពើហឹង្សាទៅលើកុមារ......២៥**

៣.១ គោលការណ៍ណែនាំ......២៥

៣.២ សមាហរណកម្មសេវាថែទាំកុមាររងគ្រោះដោយអំពើហឹង្សាក្នុងសេវាថែទាំសុខភាពដែលមានស្រាប់......២៦

៣.២.១ ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលជាតិ......២៦

៣.២.២ កន្លែងថែទាំសំខាន់ៗសម្រាប់កុមាររងគ្រោះដោយអំពើហឹង្សា......២៧

៣.៣ ស្តង់ដារអប្បបរមាសម្រាប់ការគ្រប់គ្រងកុមាររងគ្រោះដោយអំពើហឹង្សា......២៧

៣.៣.១ កញ្ចប់សេវាថែទាំសុខភាពអប្បបរមា......២៧

៣.៣.២ សម្ភារវេជ្ជសាស្ត្រ និងរដ្ឋបាលអប្បបរមាតាមកម្រិតសមត្ថភាពរបស់អ្នកផ្តល់ការថែទាំ......២៨

៣.៣.៣ ការបណ្តុះបណ្តាលអប្បបរមាសម្រាប់បុគ្គលិកសុខាភិបាល......២៩

៣.៤ គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រីនិងកុមារ......២៩

៣.៤.១ ការកំណត់អត្តសញ្ញាណនៃអំពើហឹង្សាទៅលើកុមារ......២៩

៣.៤.២ ការទទួលកុមាររងគ្រោះដោយសារអំពើហឹង្សា......៣១

៣.៤.៣ ការផ្តល់ការគាំទ្រដំបូងដល់កុមារ......៣១

៣.៤.៤ ការយល់ព្រម និងការពិនិត្យប្រវត្តិ......៣២

៣.៤.៥ ការពិនិត្យរាងកាយ......៣៥

៣.៤.៦ ការពិនិត្យរបស់មន្ទីរពិសោធន៍......................................................................................................៣៧

៣.៤.៧ ការព្យាបាល ...............................................................................................................................៣៧

៣.៤.៨ តាមដានការព្យាបាល និងការបញ្ជូនទៅមន្ទីរពេទ្យបង្អែក.......................................................៤០

៣.៤.៩ ការចងក្រងឯកសារ....................................................................................................................៤២

**៤ ការធានាគុណភាព**..................................................................................................................................៤២

៤.១ ទម្រង់ការនៃការធានាគុណភាព..............................................................................................................៤២

ឧបសម្ពន្ធ ១៖ បែបបទយល់ព្រម..............................................................................................................................៤៤

ឧបសម្ពន្ធ ២៖ គំនូសតាង.......................................................................................................................................៤៥

ឧបសម្ពន្ធ ៣៖ បែបបទនៃឯកសារស្ដីពីអំពើហឹង្សាទៅលើស្ដ្រី និងកុមារ.........................................................៤៦

ឧបសម្ពន្ធ ៤ ធនធានសហគមន៍..............................................................................................................................៥០

បញ្ជីរាយឈ្មោះឯកសារពាក់ព័ន្ធ..............................................................................................................................៥១

# អារម្ភកថា

អំពើហឹង្សាទៅលើស្ត្រី និងកុមារគឺជាក្តីកង្វល់ផ្នែកសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរ និងជាការរំលោភសិទ្ធិមនុស្សដែលបង្កឱ្យមានផលប៉ះពាល់ដល់ជីវិតមនុស្សជាពិសេសស្ត្រី និងកុមារ។ អំពើហឹង្សាទៅលើស្ត្រី និងកុមារបង្កការរំខានដល់ដំណើរការប្រយុទ្ធប្រឆាំងលើមេរោគអេដស៍/ជំងឺអេដស៍ និងការកែលម្អសុខភាពបន្តពូជនិងសុខភាពកុមារ។ ស្ថានភាពនេះទាមទារឱ្យមានការឆ្លើយតបដ៏គ្រប់ជ្រុងជ្រោយពីវិស័យសុខាភិបាល។ គោលការណ៍ណែនាំនេះ រៀបចំឡើងដើម្បីគាំទ្រដល់អ្នកផ្តល់សេវាថែទាំសុខភាព សំដៅបង្ការនិងការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលទៅនឹងអំពើហឹង្សាលើស្ត្រីនិងកុមារ។

ការរៀបចំសេចក្តីណែនាំថ្នាក់ជាតិ ក្នុងវិស័យសុខាភិបាល សម្រាប់គ្រប់គ្រងអំពើហឹង្សាទៅលើស្ត្រី និងកុមារត្រូវបានអនុវត្តស្របទៅតាមផែនការយុទ្ធសាស្ត្រ របស់ក្រសួងសុខាភិបាលឆ្នាំ ២០០៨-២០១៥ យុទ្ធសាស្ត្រជាតិសម្រាប់សុខភាពបន្តពូជនិងផ្លូវភេទឆ្នាំ២០១៣-២០១៥ គំនិតផ្តួចផ្តើមសម្រាប់ពន្លឿនការកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារកទើបកើតរបស់ក្រសួងសុខាភិបាលឆ្នាំ ២០១០-២០១៥ ផែនការសកម្មភាពជាតិសម្រាប់ទប់ស្កាត់អំពើហឹង្សាលើស្ត្រីឆ្នាំ ២០១៤-២០១៨។ គោលការណ៍ណែនាំទាំងនេះ ក៏ត្រូវបានអនុលោមស្របតាមការអនុវត្តល្អបំផុត នៅក្នុងសហគមន៍អន្តរជាតិដូចជា *គោលការណ៍ណែនាំស្តីពីវេជ្ជសាស្ត្រ និងគោលនយោបាយ សម្រាប់ឆ្លើយតបទៅនឹងអំពើហឹង្សារបស់ដៃគូស្និទ្ធស្នាល និងអំពើហឹង្សាខាងផ្លូវភេទលើស្ត្រី របស់អង្គការសុខភាពពិភពលោក និងការគ្រប់គ្រងវេជ្ជសាស្ត្រទៅលើកុមារនិងមនុស្សពេញវ័យដែលធ្លាប់ទទួលរងអំពើហឹង្សាផ្លូវភេទ របស់អង្គការ USAID ។*

គោលការណ៍ណែនាំនេះផ្តល់នូវបទដ្ឋានសម្រាប់ការផ្តល់សេវា និងទម្រង់ការវេជ្ជសាស្ត្រដែលមានគុណភាពខ្ពស់ និងគ្រប់ជ្រុងជ្រោយសម្រាប់ស្ត្រី និងកុមារដែលធ្លាប់រងគ្រោះដោយអំពើហឹង្សា និងលើកទឹកចិត្តដល់អ្នកផ្តល់សេវាគាំទ្រដើម្បីកំណត់ និងគៀងគររកធនធានឱ្យឆាប់រហ័សសម្រាប់ស្ត្រី និងកុមាររងគ្រោះនៅមណ្ឌលផ្តល់សេវាថែទាំសុខភាព។គោលការណ៍ណែនាំទាំងនេះផ្តល់នូវការគ្រប់គ្រងវេជ្ជសាស្ត្រការគាំទ្រដំបូង និងការបញ្ជូនទៅទទួលសេវាកម្មការពារផ្នែកសង្គម និងជំនួយផ្នែកច្បាប់សំខាន់ៗ។ ជាលទ្ធផល ការគ្រប់គ្រងគ្រប់ជ្រុងជ្រោយក្នុងប្រព័ន្ធសុខាភិបាល លើអំពើហឹង្សាទៅលើស្ត្រី និងកុមារតម្រូវឱ្យមានការសហការជិតស្និទ្ធជាមួយនឹងវិស័យផ្សេងៗ និងភ្នាក់ងារពាក់ព័ន្ធសំខាន់ៗ ព្រមទាំងប្រព័ន្ធមួយដើម្បីត្រួតពិនិត្យការគ្រប់គ្រងគុណភាព។

គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងគឺជាឧបករណ៍ដែលមានតម្លៃសម្រាប់ប្រធានផ្នែកសុខាភិបាល និងអ្នកផ្តល់ការថែទាំសុខភាពក្នុងមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។ គោលការណ៍ណែនាំទាំងនេះ ដើរតួជាឧបករណ៍មួយក្នុងការណែនាំបុគ្គលិកសុខាភិបាល នូវចំណុចជាច្រើនរួមមានសុខភាពបន្តពូជ និង សុខភាពកុមារ ដើម្បីបង្ការនិងការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលទៅនឹងអំពើហិង្សាលើស្ត្រីនិងកុមារ។

ភ្នំពេញ, ថ្ងៃទី១៨ ខែ[illegible] ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

# សេចក្តីថ្លែងអំណរគុណ

គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រី និងកុមារមិនអាចចងក្រងបញ្ចប់ទេ ប្រសិនបើមិនមានការគាំទ្រពីភ្នាក់ងារជាច្រើនដែលធ្វើការលើអំពើហឹង្សាលើស្ត្រី និងកុមារ។ ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែង ឆន្ទៈ និងការប្តេជ្ញាចិត្តដ៏ខ្លាំងក្លារបស់តំណាងមកពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមចំណែកក្នុងការរៀបចំគោលការណ៍ណែនាំនានា។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជនសម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស។ ក្រសួងសុខាភិបាលក៏សូមថ្លែងអំណរគុណនិងកោតសរសើរយ៉ាងជ្រាលជ្រៅផងដែរចំពោះការគាំទ្រពីអង្គការសុខភាពពិភព លោកអង្គការយូនីសេហ្វ និងដៃគូអភិវឌ្ឍន៍ទាំងអស់សម្រាប់ការគាំទ្រផ្នែកបច្ចេកទេសព្រមទាំងការណែនាំគ្រប់ដំណើរការនៃការរៀបចំដើម្បីបង្កើតគោលការណ៍ណែនាំនានា។

ក្រសួងសុខាភិបាលក៏សូមថ្លែងអំណរគុណដល់នាយកដ្ឋានការពារសុខភាពផងដែរ ចំពោះការសម្របសម្រួលដល់កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតគោលការណ៍ណែនាំទាំងនេះ និងសូមអរគុណចំពោះមន្ទីរសុខាភិបាល ព្រមទាំងបុគ្គលិកសុខាភិបាលទាំងអស់ដែលបានផ្តល់ការណែនាំផ្នែកបច្ចេកទេស និងទិន្នន័យទៅក្នុងសេចក្តីពង្រាងផងដែរ។

ជាចុងក្រោយ សូមថ្លែងអំណរគុណចំពោះទីប្រឹក្សាដែលបានពង្រាងនិងកែសម្រួលគោលការណ៍ណែនាំដោយផ្អែកលើមតិយោបល់របស់ភ្នាក់ងារពាក់ព័ន្ធនានា។

# ពាក្យកាត់

| | |
|---|---|
| AIDS | ជំងឺអេដស៍ |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ |
| DNA | ឌី អិន អេ (អាស៊ីតដេអ៊ុកស៊ីរីបូនុយក្លេអ៊ិច) |
| DoWA | មន្ទីរកិច្ចការនារីខេត្ត |
| DoH | មន្ទីរសុខាភិបាលខេត្ត |
| EC | ការការពារកំណើតបន្ទាន់ |
| GBV | អំពើហឹង្សាផ្អែកលើយេនឌ័រ |
| FP | ជនបង្គោល |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្ស |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoWA | ក្រសួងកិច្ចការនារី |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា |
| OVC | កុមារកំព្រា និងកុមារងាយរងគ្រោះ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| PEP | វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ |
| PLHIV | អ្នកផ្ទុកមេរោគអេដស៍ |
| PMTCT | ការបង្ការការឆ្លងមេរោគអេដស៍ពីម្ដាយទៅកូន |
| RH | សុខភាពបន្តពូជ |
| RTI | ការឆ្លងជំងឺតាមផ្លូវបន្តពូជ |
| STI | ជំងឺកាមរោគ |
| UN | អង្គការសហប្រជាជាតិ |
| UNFPA | មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជន |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| VAC | អំពើហឹង្សាទៅលើកុមារ |
| VAW | អំពើហឹង្សាទៅលើស្ត្រី |
| VAW/C | អំពើហឹង្សាទៅលើស្ត្រីនិងកុមារ |
| WHO | អង្គការសុខភាពពិភពលោក |

# សទ្ទានុក្រម

**ការរំលោភបំពាន៖**ការប្រើប្រាស់អំណាចមិនសមរម្យដែលមានចារីណាម្នាក់ប្រើដើម្បីទទួលបានការគ្រប់គ្រង ឬបានអត្ថប្រយោជន៍ពីការរំលោភបំពានហើយបង្កគ្រោះថ្នាក់ដល់រាងកាយ ផ្លូវចិត្ត ភេទ សេដ្ឋកិច្ចឬបង្កឱ្យមានការភ័យខ្លាច។ ការរំលោភបំពានរារាំងមនុស្សម្នាក់ៗមិនឱ្យសម្រេចចិត្តដោយសេរី និងបង្ខំពួកគេឱ្យប្រព្រឹត្តផ្ទុយពីឆន្ទៈរបស់ពួកគេ។

**ការបង្ខិតបង្ខំ៖**ការបង្ខំ ឬព្យាយាមបង្ខំបុគ្គលម្នាក់ផ្សេងទៀតក្នុងអាកប្បកិរិយាផ្ទុយនឹងឆន្ទៈរបស់បុគ្គលម្នាក់នោះដោយគំរាមកំហែង ជំរុញដោយពាក្យសម្ដី បញ្ឆោ បញ្ឆោត ការធ្វើតាមសាសនា ទំនៀមទំលាប់ជនជាតិឬអំណាចសេដ្ឋកិច្ច។

**ការយល់ព្រម៖**ធ្វើការជ្រើសរើសដោយផ្ដល់ដំណឹងដោយសេរី និងដោយស្ម័គ្រចិត្តក្នុងការធ្វើអ្វីមួយ។ គេមិនចាត់ទុកថាមានការយល់ព្រមទេ នៅពេលដែលមានការយល់ព្រមនោះកើតឡើងដោយការគំរាមកំហែង បង្ខិតបង្ខំ ឬទម្រង់ណាមួយនៃការបង្ខិតបង្ខំ ការចាប់ជំរិត ការបន្លំ ការបញ្ឆោត ឬការថ្លែងបោកប្រាស់។

**កុមារ៖** បុគ្គលណាដែលមានអាយុក្រោម ១៨ ឆ្នាំ។

**អំពើហឹង្សាក្នុងគ្រួសារ៖**អំពើហឹង្សាក្នុងគ្រួសារដែលបានកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួមមានអំពើហឹង្សាទៅលើប្ដីឬប្រពន្ធ កូនក្នុងបន្ទុក ឬបុគ្គលដែលរស់នៅក្រោមដំបូលផ្ទះតែមួយ និងអ្នកដែលនៅក្នុងបន្ទុកគ្រួសារ។

**អំពើហឹង្សាទៅលើដៃគូស្នេហា៖**សំដៅលើអាកប្បកិរិយារបស់ដៃគូស្នេហា ឬអតីតដៃគូស្នេហាដែលបង្កឱ្យគ្រោះថ្នាក់ដល់រាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ដូចជា ការរំលោភលើរាងកាយ ការបង្ខិតបង្ខំខាងផ្លូវភេទ និងការរំលោភបំពានខាងផ្លូវចិត្ត ផ្នែកសេដ្ឋកិច្ចនិងអាកប្បកិរិយាដែលត្រួតត្រាអ្នកដទៃ។

**ការគាំទ្រដំបូង៖**ការគាំទ្រដំបូងនេះសំដៅលើកម្រិតអប្បបរមានៃការគាំទ្រ (ការគាំទ្រដំបូង) និងភាពត្រឹមត្រូវនៃបទពិសោធន៍ពួកគេដែលគួរតែទទួលដោយស្ត្រីទាំងអស់ដែលប្រាប់អំពីអំពើហឹង្សា ឱ្យអ្នកថែទាំសុខភាពបានដឹង។

**អ្នកផ្ដល់ការថែទាំសុខភាព៖**សំដៅលើគិលានុបដ្ឋាក-យិកា ឆ្មប វេជ្ជបណ្ឌិត ឬបុគ្គលផ្សេងទៀតដែលធ្វើការនៅក្នុងមន្ទីរពេទ្យ គ្លីនិក ឬគ្លីនិកថែទាំសុខភាពបឋម ឬកន្លែងផ្ដល់សេវាកម្មថែទាំសុខភាពផ្សេងទៀត។

**ចារី៖**បុគ្គល ក្រុម ឬស្ថាប័នដែលបង្កភាពឈឺចាប់ និងប្រើអំពើហឹង្សាដោយបង្ខិតបង្ខំ ឬរំលោភបំពានក្នុងករណីផ្សេងៗទៅលើបុគ្គល ឬក្រុមមនុស្សដោយផ្ទាល់ ឬមិនផ្ទាល់។

**អំពើហឹង្សាលើផ្លូវភេទ៖**ជាសកម្មភាពទាក់ទងនឹងផ្លូវភេទ ការប៉ុនប៉ងធ្វើសកម្មភាពទាក់ទងនឹងផ្លូវភេទ ពាក្យសំដីឬកាយវិការដែលអ្នកដទៃមិនចង់បាន ឬសកម្មភាពជួញដូរ ឬអំពើបៀតបៀនកេរ្តិ៍ខ្មាស់និងប្រទូស្សកេរ្តិ៍ចំពោះនរណាម្នាក់ដោយបង្ខិតបង្ខំ ទោះទំនាក់ទំនងរបស់ពួកគេជាមួយនឹងជនរងគ្រោះជាអ្វីក៏ដោយ នៅទីកន្លែងណាក៏ដោយ ដូចជានៅផ្ទះ ឬកន្លែងធ្វើការជាដើម។

**ការរំលោភសេពសន្ថវៈ៖** ជាប្រភេទមួយទៀតនៃអំពើហឹង្សាលើផ្លូវភេទ ដែលតែងរួមមានការប្រើប្រាស់កម្លាំងកាយ ឬការបង្ខំដើម្បីទទួលបាន ឬបញ្ចូលអង្គជាតិឬឧបករណ៏ផ្លូវភេទ។ វាមានដូចជាការរំលោភសេពសន្ថវៈ ដែលត្រូវបានកំណត់ថា ជាការបង្ខំផ្ទៃករាងកាយ ឬការស៊កលិង្គចូលយោនី ឬរន្ធគូទ ឬផ្នែកផ្សេងទៀតនៃរាងកាយដោយបង្ខំ។

**ជនរងគ្រោះ៖** បុគ្គលដែលត្រូវបានគេបំពានលើផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្តនិង/ឬសេដ្ឋកិច្ច។

**អំពើហឹង្សាលើស្រ្តី៖** សកម្មភាពអំពើហឹង្សាទាក់ទងនឹងយេនឌ័របណ្តាលឱ្យ ឬអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ផ្លូវភេទ ឬផ្លូវចិត្តឬសេដ្ឋកិច្ច ឬការឈឺចាប់ចំពោះស្រ្តី ដូចជាការគំរាមកំហែង ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពដោយបំពានទាំងនៅទីសាធារណៈ ឬក្នុងជីវិតឯកជន។

**អំពើហឹង្សាលើកុមារ៖** សំដៅលើការប្រើកម្លាំង ឬអំណាច ការគំរាមកំហែង ឬសកម្មភាពផ្សេងៗដោយចេតនាលើកុមារដែលប្រព្រឹត្តដោយបុគ្គល ឬក្រុមមនុស្សដែលបង្កឱ្យគ្រោះថ្នាក់ខ្លាំងឬជាក់ស្តែងចំពោះសុខភាព ការរស់រាន ការលូតលាស់ ឬសេចក្តីថ្លៃថ្នូររបស់កុមារ។ នេះរួមមានគ្រប់ទម្រង់នៃការប្រព្រឹត្តមិនត្រឹមត្រូវលើផ្លូវកាយ ផ្លូវចិត្ត និង/ឬសេដ្ឋកិច្ច ការបៀតបៀនកេរ្តិ៍ខ្មាស់និងប្រទូស្សកេរ្តិ៍ ការមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ចផ្សេងៗដែលកើតឡើងក្នុងបរិបទនៃទំនាក់ទំនងក្នុងការទទួលខុសត្រូវ ការជឿទុកចិត្ត ឬអំណាច។

# ១- សេចក្ដីផ្ដើម

## ១.១ ហេតុអ្វីត្រូវមានគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្ដីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រីនិងកុមារ?

មណ្ឌលថែទាំសុខភាព និងអ្នកផ្ដល់ការថែទាំសុខភាពជាកន្លែងដំបូង ឬកន្លែងតែមួយក្រៅពីផ្ទះដែលស្ត្រីនិងកុមារដែលធ្លាប់ទទួលរងការរំលោភបំពាន ឬអំពើហឹង្សាអាចទាក់ទងបាន។ អ្នកផ្ដល់ការថែទាំសុខភាពមានតួនាទីយ៉ាងសំខាន់ដើម្បីផ្ដល់ព័ត៌មាន និងលើកកម្ពស់ការយល់ដឹងសង្គមស្ដីពីអំពើហឹង្សាចំពោះស្ត្រីនិងកុមារដែលជាបញ្ហាសុខភាពសាធារណៈប្រឹក្សាយោបល់ និងបញ្ជូនជនរងគ្រោះនិងគ្រួសាររបស់ពួកគេ បន្តទៅរកការព្យាបាលបន្ថែម។ អ្នកផ្ដល់ការថែទាំសុខភាពដែលមិនការយល់ដឹងច្បាស់លាស់ ឬមិនបានត្រៀមខ្លួនរួចរាល់អាចធ្វើឱ្យជនរងគ្រោះកាន់តែមានហានិភ័យនៃអំពើហឹង្សាឬអាចផ្ដល់ការថែទាំមិនត្រឹមត្រូវ។ ការមិនដោះស្រាយបញ្ហាអំពើហឹង្សាលើស្ត្រីនិងកុមារគឺជាការមិនដោះស្រាយបញ្ហាដ៏សំខាន់នៃសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។

គោលការណ៍ណែនាំថ្នាក់ជាតិ សម្រាប់ប្រព័ន្ធសុខាភិបាលស្ដីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រី និងកុមារនឹងជួយគាំទ្រអ្នកផ្ដល់ការថែទាំសុខភាពក្នុងការផ្ដល់សេវាថែទាំដ៏គ្រប់ជ្រុងជ្រោយនិងមានគុណភាពខ្ពស់ដល់ជនរងគ្រោះជាស្ត្រីនិងកុមារ ព្រមទាំងសហគមន៍ទាំងមូល។ គោលការណ៍ណែនាំនេះជួយឱ្យអ្នកផ្ដល់សេវាផ្នែកវេជ្ជសាស្ត្រនូវនីតិវិធីក្នុងការគ្រប់គ្រងជនរងគ្រោះពីអំពើហឹង្សា និងបញ្ជូនបន្តជនរងគ្រោះទៅសេវាសមរម្យផ្សេងទៀតនៅគ្រប់កម្រិតនិងធនធានសហគមន៍។ដើម្បីគាំទ្រការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិទាំងនេះ យើងនឹងមានសម្ភារបណ្ដុះបណ្ដាលបន្ថែមនឹងបរិយាយយ៉ាងល្អិតល្អន់អំពីចំណេះដឹង និងជំនាញចាំបាច់ក្នុងការអនុវត្តគោលការណ៍ណែនាំនេះ។

## ១.២ គោលបំណងនៃគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្ដីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រីនិងកុមារ

គោលការណ៍ណែនាំនេះមានគោលបំណងធានាថាស្ត្រី និងកុមារដែលធ្លាប់ទទួលរងអំពើហឹង្សាឬការរំលោភបំពានទទួលបានការឆ្លើយតបពេញលេញ មានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយពីប្រព័ន្ធសុខាភិបាល និងបញ្ជូនបន្តទៅទទួលសេវាថែទាំសុខភាពសមរម្យ រួមទាំងធនធានរបស់សហគមន៍ផងដែរ។ គោលបំណងគឺៈ

១.ណែនាំអំពីការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលទៅនឹងអំពើហឹង្សាទៅលើស្ត្រីនិងកុមារ ដូចជាការផ្ដល់ការគាំទ្រដំបូង ការទទួលបានការយល់ព្រមដោយការជូនដំណឹងស្ដីពីទម្រង់វេជ្ជសាស្ត្រ និងការធ្វើកោសល្យវិច័យដែលបានជ្រើសរើស ការរក្សាឯកជនភាពនិងការសម្ងាត់ ការគ្រប់គ្រងរបួស និងការព្យាបាលនិងបញ្ជូនអ្នកជំងឺដើម្បីទទួលការថែទាំបន្ថែមនិងសេវាកម្មផ្សេងទៀតដែលមិនមានលក្ខណៈវេជ្ជសស្ត្រ។

២.ធានានូវការគ្រប់គ្រងដែលមានលក្ខណៈស្តង់ដារសម្រាប់ស្ត្រីនិងកុមារដែលទទួលរងដោយអំពើហឹង្សា ដូចជាការការប្រមូល ការរក្សាភស្តុតាង និងការធ្វើកោសល្យវិច័យ(ដោយមានការយល់ព្រមពីជនរងគ្រោះ) ក្រោមកិច្ចសហការពហុវិស័យជាមួយដៃគូសំខាន់ៗ។

៣.ពង្រឹងចំណងទាក់ទងរវាងកន្លែងព្យាបាលសុខភាពនិងសហគមន៍ដើម្បីបង្កើនការប្រើប្រាស់សេវាដែលមានប្រសិទ្ធភាព និងទាន់ពេលវេលាដើម្បីគាំទ្រពេលមានអំពើហឹង្សាទៅលើស្ត្រី និងកុមារ។

៤. កសាងសមត្ថភាព និងបណ្តុះបណ្តាលអ្នកផ្តល់ការថែទាំសុខភាពដើម្បីឱ្យពួកគេអាចចូលរួមបង្ការអំពើហឹង្សាទៅលើស្ត្រី និងកុមារ និងផ្តល់សេវាឆ្លើយតបដ៏មានប្រសិទ្ធភាពផ្សេងៗទៀត។
៥. បង្កើនការយល់ដឹងក្នុងចំណោមអ្នកផ្តល់សេវាថែទាំសុខភាពអំពីអំពើហឹង្សាលើស្ត្រីឱ្យកាន់តែយល់ច្បាស់អំពីតម្រូវការនៃការឆ្លើយតបផ្នែកសុខាភិបាលដ៏ត្រឹមត្រូវ។
៦. ណែនាំអំពីទម្រង់ការសម្រាប់ការធានាគុណភាពសម្រាប់សេវាគ្រប់ជ្រុងជ្រោយដែលទាក់ទងនឹងអំពើហឹង្សាទៅលើស្ត្រីនិងកុមារ។

## ១.៣ រចនាសម្ព័ន្ធនៃគោលការណ៍ណែនាំ

- គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រីនិងកុមារមានដូចជា៖

- សេចក្តីផ្តើម គោលបំណង និងទិដ្ឋភាពទូទៅនៃស្ថានភាពអំពើហឹង្សាលើស្ត្រី និងកុមារ
- បទដ្ឋានអប្បបរមា និងគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រីនិងកុមារ។
- បទដ្ឋានអប្បបរមា និងគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហឹង្សាលើកុមារ
- ទម្រង់ការធានាគុណភាព

## ១.៤ តើអំពើហឹង្សាទៅលើស្ត្រីនិងកុមារជាអ្វី?

គោលការណ៍ណែនាំទាំងនេះផ្តោតលើអំពើហឹង្សាពីដៃគូស្និទ្ធស្នាល និងអំពើហឹង្សាខាងផ្លូវភេទលើស្ត្រី និងអំពើហឹង្សាលើកុមារដូចបានកំណត់ក្នុងសន្ទានុក្រមខាងលើ។

### ១.៤.១ ស្ថិតិថ្មីៗស្តីពីអំពើហឹង្សាទៅលើស្ត្រីនិងកុមារក្នុងប្រទេសកម្ពុជា

*ទិន្នន័យត្រូវបានកំណត់នៅលើប្រេវ៉ាឡង់ និងអត្រាកើតមានអំពើហឹង្សាទៅលើស្ត្រីក្នុងប្រទេសកម្ពុជា។ ការសិក្សាថ្មីៗមួយចំនួន បានបង្ហាញថា៖*

- យោងតាមការលទ្ធផលនៃការស្រាវជ្រាវស្តីពីប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០៥ ស្ត្រីដែលធ្លាប់រៀបការចំនួន ២២.៣%បាននិយាយថា ពួកគេធ្លាប់ទទួលរងអំពើហឹង្សាផ្លូវចិត្ត រាងកាយ និង/ឬផ្លូវភេទពីប្តីរបស់ពួកគេ។[1]
- ការសិក្សាមួយបានធ្វើឡើងដោយ**ដៃគូសម្រាប់ការបង្ការ**បានរកឃើញថា បុរសធ្លាប់មានដៃគូពីមុន ១ នាក់ក្នុងចំណោម ៣ នាក់ (៣៦ %) បាននិយាយថា បានប្រព្រឹត្តអំពើហឹង្សាលើរាងកាយ និង/ឬផ្លូវភេទទៅលើដៃគូស្និទ្ធស្នាលម្នាក់ក្នុងឆាកជីវិតរបស់នាង ហើយ ៨% នៃបុរសទាំងអស់បាននិយាយថាពួកគេធ្លាប់ប្រព្រឹត្តការបៀតបៀនកេរ្តិ៍ខ្មាស់និងប្រទូស្សកេរ្តិ៍ទៅលើស្ត្រី ឬកុមារីដែលមិនមែនដៃគូរបស់ពួកគេ។ ចំនួន ៥ %នៃបុរសទាំងអស់បាននិយាយថា ពួកគេធ្លាប់ចូលរួមក្នុងការរំលោភច្រើននាក់។[2]

---

[1](វិទ្យាស្ថានស្ថិតិជាតិឆ្នាំ ២០០៥)
[2](Fulu, et al. 2013, 11)

- ក្នុងការសិក្សាដដែលនេះ មានស្ត្រី ៤៣៦ នាក់បានទទួលសម្ភាស។ ស្ត្រីធ្លាប់មានដៃគូពីមុន ១ នាក់ក្នុងចំណោម ១០ នាក់ បាននិយាយថា ក្នុងជីវិតរបស់ពួកគេ ពួកគេធ្លាប់ទទួលរងអំពើហឹង្សាពីដៃគូរួមភេទ ឬការចាប់រំលោភក្នុងឆាកជីវិតរបស់ពួកគេ។[3]
- ការសិក្សាមួយបានធ្វើឡើងដោយមូលនិធិ CARE បានរកឃើញថា ៥៤%នៃបុគ្គលិកស្ត្រីផ្សព្វផ្សាយស្រាបៀរបាននិយាយអំពី ការបៀតបៀនកេរ្តិ៍ខ្មាស់និងប្រទូស្សកេរ្តិ៍និងការបំពានលើរាងកាយ។[4]
- ការសិក្សាមួយបានធ្វើឡើងដោយ អង្គការពលកម្មអន្តរជាតិ បានរកឃើញថា កម្មកររោងចក្រកាត់ដេរ ១ នាក់ក្នុងចំណោម ៥ នាក់បាននិយាយអំពី ការបៀតបៀនកេរ្តិ៍ខ្មាស់និងប្រទូស្សកេរ្តិ៍ឬការចំអន់បៀតបៀនផ្លូវភេទ ដែលបង្កនូវការគំរាមកំហែងចំពោះបរិយាកាសការងារ។[5]
- ការសិក្សាមួយបានធ្វើឡើងដោយ អង្គការ AusAID បានរកឃើញថា ស្ត្រីពិការ២៤.៤%ធ្លាប់ទទួលរងអំពើហឹង្សាលើផ្លូវភេទក្នុងឆាកជីវិតរបស់ពួកគេ។[6]
- ការអង្កេតលើអំពើហឹង្សាទៅលើកុមារកម្ពុជាបង្ហាញថា កុមារានិងកុមារី ៦ នាក់ក្នុងចំណោម ១០ នាក់ ធ្លាប់ទទួលរងអំពើហឹង្សាយ៉ាងតិចមួយទម្រង់កាលពីនៅតូច។ អំពើហឹង្សាលើរាងកាយច្រើនកើតមានជាទម្រង់នៃការបំពាន ហើយភាគច្រើន មានការរាយការណ៍ យ៉ាងតិចចំនួនមួយដង។[7]
- ការរួមភេទដោយបង្ខំលើកទី១ នៅវ័យកុមារកើតមាន១ភាគ៤លើស្ត្រី និងបុរស១ភាគ១០លើបុរស។[8]
- ស្ត្រីនិងកុមារភាគច្រើនធ្លាប់ទទួលរងអំពើហឹង្សានឹងមិនប្រាប់អ្នកដទៃឱ្យដឹងទេ ហើយមានមនុស្សតិចតួចដែលស្វែងរកជំនួយបន្ទាប់ពីមានការរំលោភបំពានលើផ្លូវភេទ ឬអំពើហឹង្សាលើរាងកាយរួច។[9]

### ១.៤.២ ផលវិបាកផ្នែកសុខភាពរបស់ស្ត្រីនិងកុមាររងគ្រោះ

អំពើហឹង្សាទៅលើដៃគូស្និទ្ធស្នាលនិងអំពើហឹង្សាផ្លូវភេទទៅលើស្ត្រីបង្កឱ្យមានផលវិបាកលើផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទចំពោះជនរងគ្រោះឱ្យមានបញ្ហាសុខភាពបន្តពូជ ហើយចំពោះកុមារវិញបណ្តាលឱ្យមានការចំណាយខ្ពស់ខាងផ្នែកសង្គម និងសេដ្ឋកិច្ច។

- អំពើហឹង្សាទៅលើស្ត្រី និងកុមារអាចនាំមកនូវលទ្ធផលអាក្រក់ដូចជា ឃាតកម្ម ឬអត្តឃាត។
- វាអាចបណ្តាលឱ្យរបួសហើយស្ត្រី៤២%ដែលធ្លាប់ទទួលរងអំពើហឹង្សាពីដៃគូស្និទ្ធស្នាលបាននិយាយថារបួសគឺបណ្តាលមកពីផលវិបាកនៃអំពើហឹង្សា។
- អំពើហឹង្សាពីដៃគូស្និទ្ធស្នាលនិងអំពើហឹង្សាខាងផ្លូវភេទទៅលើស្ត្រីនិងកុមារីអាចបណ្តាលឱ្យមានផ្ទៃពោះដោយចៃដន្យ មានការរំលូតកូន រោគស្ត្រី ជំងឺកាមរោគ និងជំងឺអេដស៍។

---

[3](Fulu, et al. 2013)
[4](CARE 2005)
[5](ILO 2012)
[6](Astbury and Walji 2013)
[7](MoWA, et al. 2014)
[8](MoWA, et al. 2014)
[9](MoWA, et al. 2014)

- អំពើហឹង្សាទៅលើដៃគូស្និទ្ធស្នាល នៅពេលមានផ្ទៃពោះអាចបង្កើនអត្រារលូតកូន កូនស្លាប់ក្នុងផ្ទៃ ការសម្រាលកូនមុនពេលកំណត់ និងទារកខ្វះទម្ងន់។
- ទម្រង់នៃអំពើហឹង្សាទាំងនេះអាចនាំឱ្យបាក់ទឹកចិត្ត មានជំងឺបាក់ស្បាតពិបាកគេង បញ្ហាបរិភោគ ឈឺចាប់ផ្លូវចិត្ត និងការប៉ុនប៉ងធ្វើអត្តឃាត។
- អំពើហឹង្សាលើរាងកាយ និងផ្លូវភេទនាំឱ្យកុមារមានការចុះខ្សោយសុខុមាលភាពសង្គម ផ្លូវចិត្ត និងផ្លូវបញ្ញាស្មារតី[10] និងបង្កើនឥរិយាបថដែលមានហានិភ័យចំពោះសុខភាព ដូចជាការសេពគ្រឿងញៀន ការឆាប់ចាប់ផ្តើមរួមភេទ និងការជក់បារីដែលបណ្តាលឱ្យមានជំងឺ ងាយរងរបួស និងមានបញ្ហាសង្គម[11]

## ១.៥ ច្បាប់ និងគោលនយោបាយក្នុងការដោះស្រាយអំពើហឹង្សាលើស្ត្រីនិងកុមារនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានបោះជំហានយ៉ាងធំ ដើម្បីបង្កើតគោលនយោបាយជាតិនិងក្របខ័ណ្ឌគតិយុត្តិក្នុងការដោះស្រាយអំពើហឹង្សាទៅលើស្ត្រីនិងកុមារ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីច្បាប់និងគោលនយោបាយ។

**អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី(CEDAW)៖** ប្រទេសកម្ពុជាបានធ្វើសច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី កាលពីឆ្នាំ ១៩៩២ និងពិធីសារបន្ថែមក្នុងឆ្នាំ២០១០។ក្នុងនាមជាហត្ថលេខីនៃអនុសញ្ញានេះនិងស្របតាមស្មារតីនៃក្របខណ្ឌសកម្មភាពទីក្រុងប៉េកាំងប្រទេសកម្ពុជាបានបង្ហាញឆន្ទៈយ៉ាងមោះមុតក្នុងការអនុម័តច្បាប់និងគោលនយោបាយដែលអាចដោះស្រាយ និងការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលនឹងអំពើហឹង្សាទៅលើស្ត្រី។

**អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)៖** កាលពីឆ្នាំ ១៩៩២ ប្រទេសកម្ពុជាបានធ្វើសច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមដែលចែងពីសិទ្ធិមនុស្សជាមូលដ្ឋានថា កុមារានិងកុមារីទាំងអស់មានសិទ្ធិទទួលបានការការពារពីរាល់ទម្រង់នៃអំពើហឹង្សាលើផ្លូវកាយ ផ្លូវចិត្ត ការរងរបួស ឬការរំលោភបំពាន ការធ្វេសប្រហែស ឬការមិនយកចិត្តទុកដាក់ ការធ្វើបាប ឬការកេងប្រវ័ញ្ច រួមទាំង ការបៀតបៀនកេរ្តិ៍ខ្មាស់និងប្រទូស្សកេរ្តិ៍ផងដែរ (មាត្រា ១៩)។

**រដ្ឋធម្មនុញ្ញ (១៩៩៣)** ការពារសិទ្ធិប្រជាពលរដ្ឋកម្ពុជា សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន (មាត្រា ៣២) ហើយធានាថានឹងមិនមានការរំលោភបំពានលើរាងកាយចំពោះបុគ្គលណាម្នាក់ឡើយ (មាត្រា ៣៨)។

**ច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ (២០០៥)(ច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ)** បង្កើតការទទួលខុសត្រូវរបស់អាជ្ញាធរក្នុងមូលដ្ឋានក្នុងការអន្តរាគមន៍ចំពោះករណីអំពើហឹង្សាក្នុងគ្រួសារ និងផ្តល់បទបញ្ញត្តិការពារដែលចេញដោយតុលាការដើម្បីការពារជនរងគ្រោះពីអំពើហឹង្សានានា។

**ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ (២០០៨)** បង្កើតច្បាប់ប្រឆាំងនឹងការចាប់ជំរិតមនុស្សសម្រាប់ពលកម្ម ឬការកេងប្រវ័ញ្ចផ្លូវភេទ និងមាត្រា ៣១ ស្តីពីការគ្រប់គ្រងបនពេស្យាចារខុសច្បាប់។ **មាត្រា ៣៤-៣៦** ការរួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ ឆ្នាំគឺខុសច្បាប់ ហើយការរួមភេទ ឬការប៉ះពាល់អនីតិជនលើសពីអាយុ១៥ ឆ្នាំដោយសន្យាផ្តល់នូវវត្ថុមានតម្លៃ ឬអូសទាញកុមារឱ្យប្រព្រឹត្តអំពើពេស្យាចារត្រូវជាប់ពន្ធនាគារ។

[10](Perry 2001)
[11](V J Feleti 1998)
[12](CDC, 2006) )

**ក្រមព្រហ្មទណ្ឌ** ចែងអំពីសកម្មភាពអំពើហឹង្សាក្នុងគ្រួសារថា ជាបទល្មើសដែលអាចត្រូវបានដាក់ទោសឱ្យជាប់ពន្ធនាគារ ទៅតាមបទល្មើសផ្សេងៗគ្នានៅក្នុងក្រម ដូចជាអំពើហឹង្សាដោយចេតនាទៅលើសហព័ទ្ធ ឬទៅលើកុមារដោយចេតនា។[12]ក្រមព្រហ្មទណ្ឌចែងថាអាយុស្របច្បាប់ក្នុងការរួមភេទគឺអាយុ ១៥ ឆ្នាំ។[13] ក្រមព្រហ្មទណ្ឌក៏មានការដាក់ទណ្ឌកម្មឱ្យជាប់ពន្ធនាគារចំពោះការចាប់រំលោភផងដែរ។[14]

**ក្រមរដ្ឋប្បវេណី** (២០០៧)ចែងថាសមាជិកក្នុងគ្រួសារត្រូវគោរពសិទ្ធិ និងសេរីភាពគ្នា និងហាមប្រព្រឹត្តអំពើហឹង្សាក្នុងគ្រួសារ។[15]មាត្រា ១០៤៥ នៃក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យដាក់ទណ្ឌកម្មទៅលើកុមារដោយអាណាព្យាបាលក្នុងករណីចាំបាច់។ក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យតុលាការបញ្ជាឱ្យមានការដកហូត ឬព្យួរអំណាចរបស់អាណាព្យាបាលដែលរំលោភបំពានសិទ្ធិទាំងនោះ បន្ទាប់ពីមានពាក្យប្ដឹងពីសាច់ញាតិរបស់កុមារទៅអាជ្ញាធរ ទៅដល់បួនកម្រិតដូចជា មេឃុំ *ឬសង្កាត់*ប្រធានស្ថាប័នកិច្ចការកុមារសាធារណៈ ឬព្រះរាជអាជ្ញាសាធារណៈ។ [16]

**ស្ថិតក្រោមមាត្រា ១៧២ នៃច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា**[17] **(១៩៩៧)និងក្រមព្រហ្មទណ្ឌ (២០១០)** ការបៀតបៀនផ្លូវភេទ និងអាកប្បកិរិយាបៀតបៀនកេរ្ដិ៍ខ្មាស់នៅកន្លែងធ្វើការត្រូវបានហាមឃាត់។

**គោលនយោបាយភូមិ ឃុំ សុវត្ថិភាព (២០១០)** ចេញដោយក្រសួងមហាផ្ទៃស្ដីពីការរំលោភបំពាន អំពើហឹង្សាក្នុងគ្រួសារ និងការប្រឆាំងការជួញដូរមនុស្សដែលជាវិស័យអាទិភាពសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ រាជធានី/ខេត្តដើម្បីដោះស្រាយ។ គោលនយោបាយនេះជំរុញឱ្យមានការសហការរវាងអាជ្ញាធរក្នុងមូលដ្ឋាន និងវិស័យទាំងអស់ដូចជាគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងប្រជាពលរដ្ឋក្នុងការកសាងកម្លាំង សកម្មភាព និងវិធានការដើម្បីអនុវត្តគោលនយោបាយ។

***ប្រកាស*ស្ដីពីការថែទាំជំនួស** បញ្ជាឱ្យគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ទៅសួរសុខទុក្ខដល់ផ្ទះកុមារដែលជាជនរងគ្រោះ ឬងាយរងគ្រោះដោយអំពើហឹង្សា ការរំលោភបំពានរាងកាយឬផ្លូវភេទ ឬការកេងប្រវ័ញ្ចពីសមាជិកគ្រួសាររបស់កុមារ។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវសម្ភាសដើម្បីវាយតម្លៃស្ថានភាពហានិភ័យ និងគ្រោះថ្នាក់ខ្លាំងចំពោះសុវត្ថិភាពកុមារ ដើម្បីយកមនុស្សពេញវ័យ ឬកុមារដែលស្ថិតក្នុងគ្រោះថ្នាក់នោះចេញពីផ្ទះ ដោយសហការជាមួយអាជ្ញាធរក្នុងមូលដ្ឋាន។[18]

---

[12] ក្រមព្រហ្មទណ្ឌ មាត្រា ២២២

[13] ក្រមព្រហ្មទណ្ឌ មាត្រា 239

[14] ក្រមព្រហ្មទណ្ឌ មាត្រា 239

[15] ក្រមរដ្ឋប្បវេណី មាត្រា ៩៤៣

[16] ក្រមរដ្ឋប្បវេណី មាត្រា ១០៤៨។

[17] មាត្រា ១៧២ ៖ បុគ្គលិក និងអ្នកគ្រប់គ្រងគ្រឹះស្ថានអាជីវកម្មដែលមានកុមារធ្វើការងារ ឬបុគ្គលិកហាត់ការអាយុតិចជាងដប់ប្រាំបីឆ្នាំ ឬមានស្ត្រីធ្វើការងារ ត្រូវសង្កេតមើលអាកប្បកិរិយាពួកគេ និងរក្សាសុភាវធម៌របស់ពួកគេនៅចំពោះមុខសាធារណៈ។ គ្រប់ទម្រង់នៃការរំលោភបំពានផ្លូវភេទ (ការបៀតបៀន) គឺត្រូវបានហាមឃាត់ជាដាច់ខាត។

[18] *ប្រកាស* ស្ដីពីនីតិវិធីថែទាំផ្សេងៗ មាត្រា១៤-១៥ ។

## ២- ការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលទៅនឹងអំពើហឹង្សាលើស្ត្រី

ការគ្រប់គ្រងមានលក្ខណៈទូលំទូលាយក្នុងប្រព័ន្ធសុខាភិបាលសម្រាប់ជនរងគ្រោះដោយសារអំពើហឹង្សាមានកម្រិតខុសៗគ្នា និងត្រូវការបទដ្ឋានអប្បបរមាសម្រាប់ការជ្រើសរើសបុគ្គលិក ការកំណត់ទីកន្លែងនៃព្យាបាល សម្ភារ ឧបករណ៍ ថ្នាំពេទ្យ សម្ភារវេជ្ជសាស្ត្រ និងសម្ភាររដ្ឋបាល។

### ២.១ គោលការណ៍ណែនាំ

គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រីគឺផ្អែកលើគោលការណ៍ដូចខាងក្រោម៖

***ធានាសុវត្ថិភាព៖*** វិធានការទាំងអស់ដែលបានធ្វើឡើងសម្រាប់ជួយស្ត្រីរងគ្រោះត្រូវផ្តោតលើការស្តារឡើងវិញ និងការរក្សាសុវត្ថិភាព សុខភាព និងមិនបង្កឱ្យជនរងគ្រោះស្ថិតនៅក្នុងហានិភ័យនៃអំពើហឹង្សាកាន់តែខ្លាំង។

***ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរសម្រាប់ជនរងគ្រោះ៖*** ត្រូវស្តាប់ និងគោរពគំនិតយោបល់របស់ជនរងគ្រោះ។ ត្រូវគោរព និងមិនត្រូវ "ស្តីបន្ទោសជនរងគ្រោះ" ឡើយ ។ ស្ត្រីរងគ្រោះដោយសារអំពើហឹង្សាណាមួយឬការរំលោភបំពានដោយដៃគូស្និទ្ធស្នាល ឬការរំលោភសេពសន្ថវៈគួរទទួលបានការគាំទ្រភ្លាមៗ។

***ភាពឯកជន និងការសម្ងាត់៖*** ត្រូវគោរពភាពឯកជន និងការសម្ងាត់របស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេគ្រប់ពេលវេលា។ សេវាថែទាំសុខភាពត្រូវផ្តល់ក្នុងបន្ទប់ដាច់ដោយឡែក ងាយស្រួលចេញចូល និងស្ងប់ស្ងាត់។ ព័ត៌មានអំពីជនរងគ្រោះត្រូវប្រមូលទុក ប្រើប្រាស់ និងរក្សាជាការសម្ងាត់។ នៅក្នុងមណ្ឌលព្យាបាលសុខភាពតូចៗ ឬមណ្ឌលដែលទីកន្លែងមានកំរិត អ្នកផ្តល់ការថែទាំសុខភាព ត្រូវបង្កើតកន្លែងដាច់ដោយឡែកដើម្បីធានាភាពឯកជន និងរក្សាការសម្ងាត់។

ហាមចែករំលែកព័ត៌មាន ឬពិភាក្សាអំពីអត្តសញ្ញាណរបស់ស្ត្រីរងគ្រោះដោយអំពើហឹង្សានៅក្នុងការប្រជុំខាងក្នុង ឬខាងក្រៅកន្លែងព្យាបាលសុខភាពដោយគ្មានការអនុញ្ញាតពីជនរងគ្រោះ។នេះមានន័យថា ចែករំលែកតែព័ត៌មានចាំបាច់ដែលបានយល់ព្រមពីជនរងគ្រោះជាមួយអ្នកដែលបានចូលរួមក្នុងការផ្តល់ជំនួយវេជ្ជសាស្ត្រប៉ុណ្ណោះ។ រាល់ការពិភាក្សាអំពីបញ្ហាសុខភាព មិនត្រូវបង្ហាញអត្តសញ្ញាណរបស់បុគ្គលឡើយ។ ការបញ្ចេញព័ត៌មានសុខភាពអាចធ្វើបាន ប្រសិនបើមានការយល់ព្រមពីជនរងគ្រោះ សម្រាប់អ្នកពាក់ព័ន្ធដូចជា៖

- អ្នកផ្តល់ការព្យាបាលផ្សេងដែលចូលរួមក្នុងការថែទាំជនរងគ្រោះ
- បុគ្គលទទួលបន្ទុកនៅតុលាការ ឬប៉ូលិសដោយមានការយល់ព្រមពីជនរងគ្រោះ និង
- មនុស្សផ្សេងទៀតដែលបានស្នើសុំដោយជនរងគ្រោះ។

***ការមិនរើសអើង៖*** ជនរងគ្រោះទាំងអស់មានសិទ្ធិស្មើគ្នា និងទទួលបានការព្យាបាលដូចគ្នា និងមានសិទ្ធិស្មើគ្នាក្នុងទទួលសេវាថែទាំសុខភាព។ មិនត្រូវមានការរើសអើង ឬផ្តល់ការព្យាបាលខុសពីអ្នកដទៃសម្រាប់ជនរងគ្រោះដោយសារតែយេនឌ័រ ជាតិពន្ធ សាសនា ឋានៈក្នុងសង្គម ពិការភាព ឬកត្តាផ្សេងៗឡើយ។

***ការយល់ព្រម៖*** ត្រូវទទួលបានការយល់ព្រមសម្រាប់ទម្រង់ការ និងសេវាថែទាំសុខភាពជាក់លាក់។ ត្រូវពន្យល់ពីជម្រើសនានាសម្រាប់ការយល់ព្រមទៅជនរងគ្រោះ និងត្រូវគោរពការសម្រេចចិត្តរបស់ជនរងគ្រោះចំពោះការយល់ព្រមលើចំណុច ក ខ ឬ គ ។

ក).មានតែការពិនិត្យ និងការព្យាបាលរាងកាយប៉ុណ្ណោះ

ខ).ការពិនិត្យរាងកាយ ការព្យាបាល និងការធ្វើកោសល្យវិច័យ។

គ).ការពិនិត្យរាងកាយ ការព្យាបាល និងធ្វើកោសល្យវិច័យ ការស៊ើបអង្កេតរបស់នគបាលនិងការអនុវត្តច្បាប់។

## ២.២ សមាហរណកម្មសេវាថែទាំសុខភាពស្ត្រីរងគ្រោះក្នុងសេវាថែទាំសុខភាពដែលមានស្រាប់

### ២.២.១ ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលជាតិ

**ក្រសួងសុខាភិបាល** ទទួលខុសត្រូវចំពោះគោលនយោបាយ និងការរៀបចំផែនការសុខភាព ព្រមទាំងជួយសម្របសម្រួលពីពហុវិស័យ និងជំនួយខាងក្រៅ។

**មន្ទីរសុខាភិបាលខេត្ត** មានភារកិច្ចភ្ជាប់ទំនាក់ទំនងរវាងក្រសួងសុខាភិបាលទៅស្រុកប្រតិបត្តិការតាមរយៈការអនុវត្តគោលនយោបាយនៅក្នុងផែនការសុខាភិបាលប្រចាំឆ្នាំ។

**ស្រុកប្រតិបត្តិ**ត្រូវបានរៀបចំឱ្យគ្រប់គ្រងទៅតាមចំនួនប្រជាជន ពី ១០០.០០០ ទៅ ២០០.០០០ នាក់ និងមានមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព នៅក្រោមចំណុះ។ ស្រុកប្រតិបត្តិមានតួនាទីយ៉ាងសំខាន់ក្នុងប្រព័ន្ធព្យាបាលជូនប្រជាជននិងបែងចែកសម្រាប់ការផ្តល់សេវាថែទាំសុខភាព។

**មណ្ឌលសុខភាព**ត្រូវបានកំណត់ទីតាំងដើម្បីបម្រើសេវាជូនដល់តំបន់ដែលមានប្រជាជនពី ៨.០០០ ទៅ ១២.០០០ នាក់។ សេវាកម្មទាំងនេះរួមមានការពិគ្រោះជំងឺ និងការធ្វើរោគវិនិច្ឆ័យបឋម ការសង្គ្រោះបឋម ការថែទាំជំងឺរ៉ាំរ៉ៃ ការថែទាំសុខភាពមាតានិងទារក (រួមទាំងការសម្រាលកូនធម្មតា) សេវាពន្យារកំណើត ការចាក់ថ្នាំបង្ការរោគ ការអប់រំសុខភាព និងការបញ្ជូនទៅមន្ទីរពេទ្យបង្អែក។

**មន្ទីរពេទ្យបង្អែក**មាននៅកម្រិតថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ។ មន្ទីរពេទ្យបង្អែកមានភារកិច្ចគាំទ្រដល់ការថែទាំបឋម ហើយមានធនធាននិងអ្នកជំនាញសម្រាប់ជួយដល់មណ្ឌលសុខភាពនានា។ មានកញ្ចប់សកម្មភាពបន្ថែម ៣ កម្រិតថែមទៀតនៅមន្ទីរពេទ្យបង្អែកគឺកម្រិត ១ កម្រិត ២ និងកម្រិត ៣(CPA1, CPA2 និង CPA3)។ CPA 1 មិនមានសមត្ថភាពវះកាត់ធំទេ ប៉ុន្តែមានសេវាផ្នែកសម្ភពបឋម។CPA2 មានសមត្ថភាពថែទាំសង្គ្រោះបន្ទាន់ និងអាចវះកាត់ធំបាន។CPA3 មានសមត្ថភាពផ្តល់សេវា CPA 1 និង CPA2និងមានសេវាឯកទេសបន្ថែមទៀតដូចជា ការបញ្ចូលឈាម ការព្យាបាលត្រចៀក ច្រមុះ និងបំពង់ក និងសេវាថែទាំសុខភាពផ្សេងៗទៀត។

### ២.២.២ កន្លែងថែទាំសុខភាពសំខាន់ៗសម្រាប់ស្ត្រីរងគ្រោះដោយសារអំពើហឹង្សាមាន៖

កន្លែងចូលថែទាំសុខភាពសំខាន់ៗរបស់ប្រព័ន្ធសុខាភិបាលសម្រាប់ស្ត្រីរងគ្រោះគឺ៖

- ផ្នែកសង្គ្រោះបន្ទាន់
- សេវាផែនការគ្រួសារ
- សេវាថែទាំជំងឺឆ្លងតាមផ្លូវបន្តពូជ
- សេវាពិនិត្យផ្ទៃពោះ
- សេវាថែទាំទារកទើបកើត
- សេវាថែទាំសុខភាពក្រោយពេលសម្រាល
- សេវាសម្ភពសង្គ្រោះបន្ទាន់ និងការថែទាំទារក

- សេវាកម្មចាក់ថ្នាំបង្ការដល់កុមារ
- សេវាកម្មរំលូតកូនដោយសុវត្ថិភាព
- សេវាប្រឹក្សាយោបល់ ដោយសម្ងាត់ និងស្ម័គ្រចិត្ត
- ការបង្ការជំងឺឆ្លងពីម្តាយទៅកូន

*ការពិនិត្យទាំងស្រុងលើជនរងគ្រោះដោយអំពើហិង្សា មិនត្រូវបានណែនាំឱ្យធ្វើទេ ប៉ុន្តែអ្នកផ្តល់ការថែទាំសុខភាពគួរពិភាក្សាអំពីប្រធានបទនេះជាមួយស្ត្រី ឬកុមារដែលសង្ស័យថាបានរងរបួសដោយអំពើហិង្សា។*

## ២.៣ បទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងស្ត្រីរងគ្រោះដោយអំពើហិង្សា

### ២.៣.១ កញ្ចប់សេវាថែទាំសុខភាពអប្បបរមា

កញ្ចប់អប្បបរមាសម្រាប់សេវាថែទាំសុខភាពនៅកន្លែងព្យាបាលគួរផ្តល់មាន៖

- កន្លែងទទួលភ្ញៀវ និងការគាំទ្រដំបូង
- ធានាការសម្ងាត់ និងទទួលបានការយល់ព្រមដោយមានការជូនដំណឹងជាមុនស្តីពីទម្រង់ការព្យាបាល និងវិធីធ្វើកោសល្យវិច័យដែលបានជ្រើសរើស។
- ការគ្រប់គ្រងគ្លីនិក (កត់ត្រាប្រវត្តិជំងឺ ការពិនិត្យរាងកាយ) ការព្យាបាលរបួសទាំងអស់នៅកន្លែងផ្តល់សេវាសុខភាពដែលមានសមត្ថភាពព្យាបាល។
- ការផ្តល់ ឬការបញ្ជូនបន្តទៅរកសេវាបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ( PEP ក្នុងរយៈពេល ៧២ ម៉ោង) (ក្នុងករណីមានអំពើហិង្សាផ្លូវភេទ)
- ការផ្តល់ឬការបញ្ជូនបន្តសម្រាប់ការព្យាបាលនិងការពារការឆ្លងមេរោគពេលប៉ះពាល់ផ្លូវភេទ (ក្នុងករណីមានអំពើហិង្សាផ្លូវភេទ)
- ការផ្តល់ ឬការបញ្ជូនបន្តសម្រាប់ការការពារកំណើតបន្ទាន់(ក្នុងករណីមានអំពើហិង្សាផ្លូវភេទ)
- ការផ្តល់ ឬការបញ្ជូនបន្តសម្រាប់ការធ្វើកោសល្យវិច័យភ្លាមៗ (អាស្រ័យលើការយល់ព្រមពីជនរងគ្រោះ)
- ការបញ្ជូនជនរងគ្រោះទៅកន្លែងព្យាបាលសុខភាពកម្រិតខ្ពស់សម្រាប់ការថែទាំផ្នែកវេជ្ជសាស្ត្របន្ថែម និង
- ការបញ្ជូនទៅសេវាផ្សេងសម្រាប់អំពើហិង្សាលើស្ត្រីនិងកុមារដូចជាការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម មណ្ឌលស្នាក់នៅដែលមានសុវត្ថិភាព ជំនួយផ្នែកច្បាប់ ការថែទាំក្រោយពេលរងគ្រោះ ឬការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងសេវាកម្មផ្សេងៗទៀត។

#### *២.៣.៣.១ សមត្ថភាពឆ្លើយតបនៅតាមកន្លែងព្យាបាល*

| សមត្ថភាពព្យាបាល | មណ្ឌលសុខភាព | មន្ទីរពេទ្យបង្អែក CPA1 | មន្ទីរពេទ្យបង្អែក CPA2 | មន្ទីរពេទ្យបង្អែកជាតិ និងខេត្ត CPA3 |
|---|---|---|---|---|
| ទទួល និងបែងចែកការថែទាំសមស្រប | √ | √ | √ | √ |
| ផ្តល់ការគាំទ្រដំបូងដែលធានានូវការសម្ងាត់ | √ | √ | √ | √ |
| សួរប្រវត្តិជំងឺ ទទួលបានការយល់ព្រម និងធ្វើការពិនិត្យ | | √ | √ | √ |
| គ្រប់គ្រងនិងព្យាបាលរបួសស្រាល | √ | √ | √ | √ |
| គ្រប់គ្រងនិងព្យាបាលរបួសធ្ងន់ៗ | | | √ | √ |
| ផ្តល់វិធីបង្ការក្រោយពេលប៉ះពាល់(PEP) | | | | √ |

| | | | | |
|---|---|---|---|---|
| ផ្តល់ការការពារកំណើតបន្ទាន់ | √ | √ | √ | √ |
| ផ្តល់ថ្នាំបង្ការជំងឺតេតាណូស | √ | √ | √ | √ |
| ព្យាបាលជំងឺកាមរោគ | √ | √ | √ | √ |
| ***សេវាកម្មផ្នែកចិត្តសាស្ត្រសង្គម*** | | | | |
| បង្កើតទំនាក់ទំនងអន្តរបុគ្គលយ៉ាងល្អជាមួយជនរងគ្រោះ | √ | √ | √ | √ |
| ភ្ជាប់ជនរងគ្រោះជាមួយសេវាថែទាំសុខភាពនៃអំពើហឹង្សាទៅលើស្ត្រីផ្សេងទៀត | √ | √ | √ | √ |
| តាមដាន | √ | √ | √ | √ |
| ***សេវាកម្មកោសល្យវិច័យ*** | | | | |
| ប្រមូល និងចងក្រងជាឯកសារនូវលទ្ធផលនៃការពិនិត្យធ្វើកោសល្យវិច័យ | | √ | √ | √ |
| ចងក្រងជាឯកសារនូវលទ្ធផលទាក់ទងនឹងប្រវត្តិកោសល្យវិច័យ និងការពិនិត្យរាងកាយ | | √ | √ | √ |
| បំពេញបែបបទវេជ្ជសាស្ត្រកោសល្យវិច័យ | | | | √ |
| ***ការបញ្ជូន និងការទាក់ទង*** | | | | |
| បញ្ជូនជនរងគ្រោះធ្ងន់ធ្ងរទៅកន្លែងព្យាបាលកម្រិតខ្ពស់ | √ | √ | √ | √ |
| អប់រំ តម្រង់ទិស និងផ្តល់ព័ត៌មានអំពីសេវាថែទាំសុខភាពនៃអំពើហឹង្សាទៅលើស្ត្រី | √ | √ | √ | √ |

### ២.៣.២ សម្ភារវេជ្ជសាស្ត្រ និងរដ្ឋបាលអប្បរមាតាមកម្រិតសមត្ថភាពរបស់អ្នកផ្តល់ការថែទាំ

| មណ្ឌលសុខភាព | មន្ទីរពេទ្យបង្អែក |
|---|---|
| **សម្ភារវេជ្ជសាស្ត្រ និងថ្នាំពេទ្យ** | |
| - សម្ភារ និងឧបករណ៍សម្រាប់បង្ការ និងគ្រប់គ្រងការឆ្លងជំងឺ<br>-ចេសបានសម្លាប់មេរោគរួច និងកញ្ចប់រុំរបួស<br>-សម្ភារអនាម័យ<br>-កញ្ចប់តេស្តពិនិត្យផ្ទៃពោះ<br>-កញ្ចប់តេស្តរកជំងឺស្វាយ<br>-សេរ៉ូមបង្ការជំងឺ តេតាណូស<br>-ថ្នាំបំបាត់ការឈឺចាប់<br>-ថ្នាំស្អឹកសម្រាប់ដេររបួស<br>-ថ្នាំអង់ទីប៊ីយ៉ូទិក<br>-ការការពារកំណើតបន្ទាន់<br>-ការព្យាបាលជំងឺកាមរោគ | សម្ភារបន្ថែមនៅមណ្ឌលសុខភាព៖<br>-ផ្តល់វិធីបង្ការក្រោយពេលប្រឈមនឹងជំងឺនៅមន្ទីរពេទ្យបង្អែក (CPA3)<br>កញ្ចប់ពិនិត្យកោសល្យវិច័យមានដូចជា៖<br>-សឺរ៉ាំងចាក់ថ្នាំ<br>-ឧបករណ៍បើកមាត់ស្បូន<br>-ដបទទេដែលបានសម្លាប់មេរោគរួច<br>-សម្ភារកៀរទឹករំអិលមាត់ស្បូន<br>-ចង់ក្រដាសសម្រាប់ដាក់ក្រណាត់<br>-ម៉ាស៊ីនថតឌីជីថល (បើមាន)<br>-ប្រេងរំអិល<br>-ក្រណាត់ ក្រដាសអនាម័យ ឬសម្ភារជំនួយបន្ថែមផ្សេងទៀត |
| **សម្ភាររដ្ឋបាល** | |
| បែបបទយល់ព្រម<br>បែបបទព្យាបាលស្ត្រីនិងកុមាររងគ្រោះដោយអំពើហឹង្សា | បែបបទយល់ព្រម<br>បែបបទព្យាបាលស្ត្រីនិងកុមាររងគ្រោះដោយសារអំពើហឹង្សា<br>ឯកសារនិងព័ត៌មានបញ្ជូនជនរងគ្រោះ |

### ២.៣.៣ ការបណ្តុះបណ្តាលអប្បបរមាសម្រាប់បុគ្គលិកសុខាភិបាល

កន្លែងព្យាបាលសុខភាពទាំងអស់ត្រូវផ្តល់ការបណ្តុះបណ្តាលជំនាញជាអប្បបរមាស្តីពី៖

- ច្បាប់ដែលពាក់ព័ន្ធនឹងអំពើហឹង្សាទៅលើស្ត្រី
- ថាមវន្តនៃអំពើហឹង្សាទៅលើដៃគូស្និទ្ធស្នាល អំពើហឹង្សាលើផ្លូវភេទ និងការរំលោភបំពាន
- សញ្ញា និងរោគសញ្ញានៃអំពើហឹង្សាទៅលើស្ត្រី
- ទាក់ទងជនរងគ្រោះ ហើយផ្តល់ការគាំទ្រដំបូង
- ការប្រើប្រាស់ពិធីសារព្យាបាលដូចជាការផ្តល់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ការបង្ការកំណើតក្រោយពេលរួមភេទ និងសេវាថែទាំសុខភាពផ្សេងទៀតតាមការចាំបាច់
- ការយល់ដឹង និងការធ្វើកោសល្យវិច័យ (នៅកម្រិតមន្ទីរពេទ្យបង្អែក)
- ចំណេះដឹង និងការបញ្ជូនទៅធនធានសហគមន៍
- ប្រើវិធីសាស្ត្រស្ត្រីមជ្ឈមណ្ឌល និង
- ប្រធានបទផ្សេងៗដែលសមស្រប។

***បុរសនិងអំពើហិង្សាលើផ្លូវភេទ***

បុរសក៏អាចជាជនរងគ្រោះនៃអំពើហិង្សាពីដៃគូ និងការរំលោភសេពសន្ថវៈផងដែរ។ ប៉ុន្តែ ជាទូទៅស្ត្រីទទួលរងអំពើហិង្សាលើផ្លូវភេទ អំពើហិង្សាលើរាងកាយធ្ងន់ធ្ងរ និងអាកប្បកិរិយាត្រួតត្រាពីដៃគូបុរស ច្រើនជាងស្ត្រីធ្វើដាក់បុរស។
ទោះបីជា គោលការណ៍ណែនាំទាំងនេះបង្កើតឡើងដើម្បីផ្តោតលើអំពើហិង្សាទៅលើស្ត្រីនិងកុមារក៏ដោយ ការណែនាំជាច្រើនក៏ពាក់ព័ន្ធនឹងអំពើហិង្សាខាងផ្លូវភេទលើបុរសផងដែរ។

## ២.៤ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងស្ត្រីរងគ្រោះ ដោយសារអំពើហឹង្សាក្នុងប្រព័ន្ធសុខាភិបាល

### ២.៤.១ ការកំណត់អំពើហឹង្សាទៅលើស្ត្រី

ស្ត្រីរងគ្រោះតែងតែស្វែងរកការព្យាបាលសុខភាពទាក់ទងនឹងស្ថានភាពសតិអារម្មណ៍ រាងកាយ រួមទាំងការព្យាបាលរបួស។ ប៉ុន្តែពួកគេតែងតែមិនប្រាប់អ្នកជំនាញថែទាំសុខភាពអំពីអំពើហឹង្សាដោយសារខ្លាចត្រូវបានគេវាយតម្លៃ ឬខ្លាចដៃគូរបស់ពួកគេ។<u>វា***មិនមែន***ជាការចាំបាច់ក្នុងការណែនាំឱ្យស្ត្រីទាំងអស់ ទទួលការថែទាំសុខភាពអំពីអំពើហឹង្សាទេ</u>ប៉ុន្តែអ្នកផ្តល់ការថែទាំសុខភាពត្រូវបានលើកទឹកចិត្តធ្វើដូច្នោះ ប្រសិនបើពួកគេសង្ស័យថាមានរបួស ឬស្ថានភាពណាដែលអាចទាក់ទងនឹងអំពើហឹង្សាដើម្បីលើកប្រធានបទមកនិយាយជាមួយស្ត្រី។ ស្ត្រីអាចទទួលរងអំពើហឹង្សាពីដៃគូស្និទ្ធស្នាលឬអំពើហឹង្សាលើផ្លូវភេទ។

***ប្រសិនបើអ្នកសង្ស័យថាមានស្ត្រីទទួលរងគ្រោះដោយសារអំពើហិង្សាពីដៃគូ ឬការចាប់រំលោភ សូមសួរសំណួរ៖***

*"រោគសញ្ញារបស់អ្នកអាចពាក់ព័ន្ធនឹងភាពតានតឹង។ តើអ្នកនិងប្តីរបស់អ្នក (ដៃគូ)តែងវាយគ្នាមែនទេ? តើអ្នកធ្លាប់ឈឺចាប់ដោយសារការវាយតប់ទេ?"*

*"នៅពេលខ្ញុំឃើញរបួសរបស់អ្នក ខ្ញុំគិតថា វាកើតដោយសារមាននរណាម្នាក់វាយ។ តើវាបានកើតឡើងលើអ្នកមែនទេ?"*

*"អ្នកដឹងទេ សព្វថ្ងៃនេះវាជារឿងធម្មតាសម្រាប់មនុស្សម្នាក់ដែលរងគ្រោះខាងផ្លូវចិត្ត ផ្លូវកាយ ឬផ្លូវភេទនៅក្នុងជីវិតរបស់ពួកគេ ហើយវាអាចប៉ះពាល់ដល់សុខភាពរបស់ពួកគេនៅឆ្នាំក្រោយៗទៀត។*

*តើវាធ្លាប់កើតឡើងចំពោះអ្នកទេ?"*

*"តើអ្នកធ្លាប់ត្រូវបានគេបង្ខំឲ្យរួមភេទដែលអ្នកមិនចង់មែនទេ?"*

***អ្នកអាចសង្ស័យថា ស្ត្រីម្នាក់ទទួលរងអំពើហឹង្សា ប្រសិនបើគាត់មានលក្ខណៈដូចខាងក្រោម៖***

- របួសដដែលៗ និងមិនអាចពន្យល់មូលហេតុត្រឹមត្រូវ
- ការពន្យារពេលនៅចន្លោះពេលមានរបួស និងការស្វែងរកការព្យាបាល
- ការត្អូញត្អែរដែលមិនច្បាស់លាស់ហើយមិនមានស្លាកស្នាមជាក់ស្តែង
- ការឈឺចាប់ ឬស្ថានភាពរ៉ាំរ៉ៃដែលមិនអាចពន្យល់បាន (ឈឺត្រគាក ឬបញ្ហាផ្លូវភេទ បញ្ហាក្រពះនិងពោះវៀន ការរលាកប្លោកនោម ឬតម្រងនោម ឬឈឺក្បាល)
- ជំងឺកាមរោគដែលអាចកើតឡើងដដែលៗ
- ការមានផ្ទៃពោះដែលមិនចង់បាន
- បញ្ហាសុខភាពផ្លូវចិត្តដែលកំពុងកើតមាន ដូចជាការតានតឹងអារម្មណ៍ ការបាក់ទឹកចិត្ត ឬ ការពិបាកចិត្ត
- អាកប្បកិរិយាដែលគ្រោះថ្នាក់ ដូចជាការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន
- ដៃគូបុរសដែលយកចិត្តទុកដាក់ គ្រប់គ្រងហួសហេតុពេក ឬមិនមានបំណងចាកចេញពីស្ត្រីក្នុងពេលណាត់ជួបព្យាបាល។

> - ហាមលើកបញ្ហាអំពើហិង្សាពីដៃគូស្និទ្ធស្នាល លុះត្រាតែស្ត្រីនៅតែម្នាក់ឯង។
> - ត្រូវព្យាយាមបង្កើតភាពស្និទ្ធស្នាលជាមួយស្ត្រីមុនពេលសួរសំណួរដែលមានលក្ខណៈរសើប។
> - ហាមដាក់សម្ពាធស្ត្រីឲ្យបង្ហាញអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬអំពើហិង្សាលើផ្លូវភេទ។
> - ប្រសិនបើស្ត្រីមិននិយាយ ប៉ុន្តែអ្នកសង្ស័យថាមានអំពើហិង្សា សូមប្រាប់គាត់អំពីសេវាកម្ម និងផ្តល់ព័ត៌មានស្តីពីផលប៉ះពាល់លើសុខភាពនិងកូន។

### ២.៤.២ ការទទួលយកជនរងគ្រោះ

នៅពេលស្ត្រីបង្ហាញពីអំពើហឹង្សា អ្នកផ្តល់ការថែទាំសុខភាពត្រូវផ្តល់សេវាដោយមានសេចក្តីអាណិតអាសូរ គាំទ្រនិងបង្ហាញពីការព្រួយបារម្ភអំពីសុខុមាលភាព និងសុវត្ថិភាពរបស់ជនរងគ្រោះ។ **សូមប្រញាប់បញ្ជូនអ្នកជំងឺដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ឬស្ថិតក្នុងការគំរាមកំហែងដល់អាយុជីវិតទៅរកការព្យាបាលបន្ទាន់ភ្លាមៗ។**

> ***ជំហានសំខាន់ៗក្នុងការទទួលយកជនរងគ្រោះ***
> - ណែនាំអំពីខ្លួនអ្នកទៅជនរងគ្រោះ (ប្រសិនបើអ្នកជាអ្នកថ្មី)
> - ត្រូវប្រាកដថា បច្ចុប្បន្នជនរងគ្រោះស្ថិតនៅកន្លែងមានសុវត្ថិភាព
> - បញ្ជូនជនរងគ្រោះទៅបន្ទប់ដាច់ដោយឡែកពីអ្នកជំងឺដទៃ
> - សាកសួរជនរងគ្រោះ ប្រសិនបើគាត់ចង់ឲ្យមានអ្នកគាំទ្រជាក់លាក់ណាម្នាក់នៅជាមួយ
> - ពន្យល់ពីជំហាននៃវិធានការដែលអ្នកនឹងអនុវត្ត

### ២.៤.៣ ការគាំទ្រដំបូងសម្រាប់ដៃគូស្និទ្ធស្នាល និងអំពើហឹង្សាទៅលើស្ត្រី

#### *២.៤.៣.១ ការពិចារណាទូទៅ*

- អ្នកផ្តល់ការថែទាំសុខភាពគួរមានសមត្ថភាពផ្តល់នូវការគាំទ្រដំបូងជាមូលដ្ឋានចំពោះស្ត្រីរងគ្រោះ

- ការគាំទ្រដំបូង ផ្តល់ការថែទាំ និងការឆ្លើយតបជាក់ស្តែងចំពោះតម្រូវការរបស់ជនរងគ្រោះ
- ស្ត្រីរងគ្រោះដោយសារអំពើហឹង្សាខ្លះរងការឈឺចាប់ផ្លូវចិត្តភ្លាមៗ ឯអ្នកផ្សេងទៀតឈឺចាប់នៅពេលក្រោយ
- ត្រូវគោរពភាពឯកជន និងការសម្ងាត់របស់ជនរងគ្រោះ។

### *២.៤.៣.២ ការផ្តល់ការគាំទ្រដំបូង* [19]

**អ្នកមិនចាំបាច់៖**

- ដោះស្រាយបញ្ហារបស់គាត់
- បញ្ចុះបញ្ចូលឲ្យចេញពីទំនាក់ទំនងហិង្សា
- បញ្ចុះបញ្ចូលឲ្យទៅរក ប៉ូលិស ឬតុលាការ
- សួរពត៌មានជាក់លាក់ដែលជួយឲ្យគាត់បានធូរស្បើយ
- បង្ខំឲ្យរៀបរាប់ពីអារម្មណ៍និងប្រតិកម្មចំពោះព្រឹត្តិការណ៍

ការគាំទ្រដំបូងគឺពាក់ព័ន្ធនឹងភារកិច្ចចំនួន ៥៖ *ស្តាប់ សាកសួរអំពីតម្រូវការនិងកង្វល់បង្ហាញការយល់ចិត្ត បង្កើនសុវត្ថិភាព និងគាំទ្រ។* នេះគឺជាការថែទាំសំខាន់បំផុតដែលអ្នកអាចផ្តល់ឱ្យ។ នេះជាកិច្ចការសំខាន់បំផុត ទោះបីជាអ្នកអាចធ្វើបានតែប៉ុណ្ណឹងក៏ដោយ។ការគាំទ្រដំបូងជួយដល់អ្នកដែលបានឆ្លងកាត់ការលំបាក ភាពក្រៀមក្រំឬភាពតប់ប្រមល់ជាច្រើនប្រភេទ រួមទាំងស្ត្រីរងគ្រោះផងដែរ។ សូមចងចាំថា អ្នកគ្មានភារកិច្ចក្នុងការដោះស្រាយបញ្ហាជនរងគ្រោះទេ ជនរងគ្រោះមានសិទ្ធិសម្រេចចិត្តដោយខ្លួនឯង ហើយត្រូវគោរពភាពឯកជន និងការសម្ងាត់គ្រប់ពេលវេលា។

| | |
|---|---|
| ស្តាប់ | ស្តាប់គាត់ដោយយកចិត្តទុកដាក់ និងគ្មានការវិនិច្ឆ័យ |
| **សាកសួរអំពីតម្រូវការ និងការបារម្ភផ្សេងៗ** | វាយតម្លៃ និងឆ្លើយតបនឹងតម្រូវការ និងការបារម្ភចំពោះផ្លូវចិត្ត ផ្លូវកាយ ផ្លូវសង្គម និងការអនុវត្តផ្សេងៗ* |
| **បញ្ជាក់ថាពិត (ជឿជាក់)** | បង្ហាញថា អ្នកជឿជាក់គាត់។ ប្រាប់គាត់ថាគាត់មិនមានកំហុស។ |
| **បង្កើនសុវត្ថិភាព** | ពិភាក្សាអំពីផែនការរបស់គាត់ដើម្បីការពារគាត់ពីគ្រោះថ្នាក់ផ្សេងៗ ប្រសិនបើមានអំពើហឹង្សាកើតឡើងម្តងទៀត។ |
| **ការគាំទ្រ** | គាំទ្រដោយជួយផ្តល់ព័ត៌មាន សេវាកម្ម និងការគាំទ្រផ្នែកសង្គមទៅគាត់ |

*ចងចាំថា អ្នកមិនមានភារកិច្ចក្នុងការដោះស្រាយបញ្ហារបស់គាត់ទេ

### ២.៤.៤ ការថែទាំបន្ថែមសម្រាប់ជនរងគ្រោះដោយអំពើហឹង្សាពីដៃគូ

ក្រៅពីជំនួយដំបូង ជនរងគ្រោះដែលដែលរាយការណ៍អំពីហឹង្សាពីដៃគូស្និទ្ធស្នាលត្រូវទទួលបានការថែទាំដូចខាងក្រោម៖

### *២.៤.៤.១ ការពិនិត្យរាងកាយ ការព្យាបាលរបួស និងធ្វើឯកសារ*

ការថែទាំផ្នែកវេជ្ជសាស្ត្របន្ទាន់គួរផ្តល់ឱ្យជនរងគ្រោះដោយផ្អែកតាមរបួស។ អ្នកផ្តល់ការថែទាំសុខភាពគួរអនុវត្តតាមបទដ្ឋានសម្រាប់ការព្យាបាលរបួសរាងកាយ។ របួសផ្សេងៗត្រូវកត់ត្រាទុកក្នុងឯកសារអ្នកជំងឺនិងរក្សាទុក។ ប្រសិនបើរបួសធ្ងន់ធ្ងរ គួរបញ្ជូនស្ត្រីរងគ្រោះទៅកន្លែងព្យាបាលសុខភាពកម្រិតខ្ពស់ភ្លាមៗ។

[19] ពង្រាងសៀវភៅណែនាំវេជ្ជសាស្ត្ររបស់អង្គការសុខភាពពិភពលោកស្តីការថែទាំស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទ

*រូបភាព ១៖ បណ្តាញថែទាំជនរងគ្រោះដោយសារអំពើហិង្សាពីដៃគូស្និទ្ធស្នាល*

*ដកស្រង់ពីពង្រាងសៀវភៅណែនាំវេជ្ជសាស្ត្រស្តីពីការថែទាំស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល និងអំពើហិង្សា*




***ការវាយតម្លៃសុវត្ថិភាព និងផែនការ***

- តើអំពើហិង្សាលើរាងកាយកើតឡើងច្រើនជាងពីមុន ឬកាន់តែធ្ងន់ធ្ងរឡើងក្នុងរយៈពេល ៦ ខែចុងក្រោយ?
- តើគាត់ប្រើប្រាស់អាវុធ ឬគំរាមអ្នកដោយប្រើអាវុធដែរឬទេ?
- តើគាត់ព្យាយាមច្របាច់កអ្នកដែរឬទេ?
- តើអ្នកជឿថា គាត់នឹងសម្លាប់អ្នកដែរឬទេ?
- តើគាត់ធ្លាប់វាយអ្នក នៅពេលអ្នកមានផ្ទៃពោះដែរឬទេ?
- តើគាត់ប្រច័ណ្ឌអ្នកដោយប្រើអំពើហិង្សា និងជាប្រចាំដែរឬទេ?

*ប្រសិនបើស្ត្រីឆ្លើយថា មែន យ៉ាងតិចណាស់ ៣ សំណួរក្នុងចំណោមសំណួរទាំងនេះ គាត់អាចមិនមានសុវត្ថិភាពក្នុងការត្រឡប់ទៅផ្ទះវិញទេ។ គាត់គួរតែត្រូវបានបញ្ជូនទៅកន្លែងមានសុវត្ថិភាព ដូចជា ផ្ទះរបស់មិត្តភ័ក្តិ ឬមណ្ឌលស្នាក់នៅមានសុវត្ថិភាព*

### ២.៤.៤.២ ព័ត៌មានស្តីពីអំពើហឹង្សាពីដៃគូស្និទ្ធស្នាល រួមទាំងផលប៉ះពាល់ទៅលើស្ត្រី

ធនធានសម្ភារគួរមានដូចជាផ្ទាំងក្រដាស ឬកូនសៀវភៅព័ត៌មានបរិយាយអំពីផលប៉ះពាល់របស់អំពើហឹង្សាពីដៃគូស្និទ្ធស្នាល។ ការប្រុងប្រយ័ត្នចម្បង គឺជាសុវត្ថិភាពរបស់ជនរងគ្រោះដែលគួរពិចារណាពេលដែលបញ្ជូនព័ត៌មានផ្សេងៗចេញពីកន្លែងព្យាបាលសុខភាព ព្រោះករណីនេះធ្វើឱ្យគាត់ប្រឈមមុខនឹងហានិភ័យខ្ពស់ពីអំពើហឹង្សារបស់ដៃគូ (ឧទាហរណ៍ ប្រសិនបើដៃគូសង្ស័យចំពោះស្ត្រីដែលបាននិយាយប្រាប់អំពីអំពើហឹង្សា)។

### ២.២.៤.៣ ផែនការគ្រួសារ និងការបង្ការការមានផ្ទៃពោះ

ជនរងគ្រោះភាគច្រើនមានដៃគូស្និទ្ធស្នាលមិនបានបំពេញតម្រូវការនៃការការពារកំណើតទេ។ ជារឿយៗពួកគេមានដៃគូស្និទ្ធស្នាល ហើយគឺស្ថិតក្រោមហានិភ័យនៃការមានផ្ទៃពោះដោយចៃដន្យ ដោយមិនបានគ្រោងទុក ឬដែលខុសពេលវេលា។ហេតុនេះ មណ្ឌលសុខភាពគួរតែអនុវត្តដូចខាងក្រោម៖

- ស្វែងយល់អំពីស្ថានភាពនៃការរៀបចំផែនការគ្រួសារពេលបច្ចុប្បន្ន រួមមានមធ្យោបាយពន្យារកំណើត បច្ចុប្បន្នដែលបានប្រើប្រាស់ និងថាតើជនរងគ្រោះត្រូវការប្អអត់។
- ផ្តល់ប្រឹក្សាអំពីផែនការគ្រួសារ និងមធ្យោបាយពន្យារកំណើត។ បញ្ជូនទៅមន្ទីរពេទ្យ ប្រសិនបើកន្លែង ព្យាបាលសុខភាពមិនអាចផ្តល់វិធីសាស្ត្ររៀបចំផែនការគ្រួសារដែលបានជ្រើសរើស។

### *២.២.៤.៤ បញ្ជូនទៅធនធានសហគមន៍*

អ្នកផ្តល់ការថែទាំសុខភាពអាចជាជនទំនាក់ទំនងដ៏សំខាន់ក្នុងការបញ្ជូនជនរងគ្រោះដោយសារអំពើហឹង្សាពីដៃគូទៅរកជំនួយផ្នែកច្បាប់ នគរបាល ឬធនធានសហគមន៍។ ចំណុចសំខាន់គឺដើម្បីធានាសុវត្ថិភាពរបស់គាត់និងរបស់កូនគាត់។ គួរតែបញ្ជូនទៅមន្ទីរពេទ្យ ប៉ុន្តែត្រូវគោរពសិទ្ធិជនរងគ្រោះ ប្រសិនបើគេមិនទទួល។

សូមមើលចំណុច ២.៨ ខាងក្រោមសម្រាប់ឯកសារស្តីពីការបញ្ជូនជនរងគ្រោះទៅមន្ទីពេទ្យ។

### ២.៤.៥ ការថែទាំបន្ថែមសម្រាប់ជនរងគ្រោះពេញវ័យ ដោយសារការចាប់រំលោភឬអំពើហឹង្សាលើផ្លូវភេទ

បន្ថែមលើការគាំទ្រដំបូង ជនរងគ្រោះដោយសារការចាប់រំលោភ ឬអំពើហឹង្សាលើផ្លូវភេទគួរតែទទួលបាននូវសេវាដូចខាងក្រោម៖

- ពត៌មានអំពីការពិនិត្យសុខភាព ការពិនិត្យកោសល្យវិច័យ និងការរាយការណ៍ទៅនគរបាល
- ទទួលបានការយល់ព្រមជាមុនពីជនរងគ្រោះ បន្ទាប់មកទើបសួរប្រវត្តិជំងឺ
- ធ្វើការពិនិត្យរាងកាយអោយបានត្រឹមត្រូវ និង គ្រប់ជ្រុងជ្រោយ
- ព្យាបាលរាល់របួសលើរាងកាយ




*រូបភាព ២ **បណ្តាញសម្រាប់ការថែទាំលើកដំបូង បន្ទាប់ពីរំលោភលើផ្លូវភេទ** ដកស្រង់ពីពង្រាង សៀវភៅណែនាំវេជ្ជសាស្ត្រស្តីពីការថែទាំស្ត្រីរងគ្រោះដោយសារអំពើហិង្សាពីដៃគូស្នេហា និង អំពើហិង្សាលើផ្លូវភេទ ។*

- *ផ្តល់ប្រឹក្សាអំពីហានិភ័យនៃជំងឺកាមរោគ និងមេរោគអេដស៍ និងផ្តល់ការធ្វើតេស្ត និងព្យាបាលបង្ការ* រួមមាន ការ ការពារកំណើតបន្ទាន់ ការព្យាបាល (ការឆ្លងជំងឺ) ជំងឺកាមរោគ និងវិធីបង្ការក្រោយពេលប្រឈមនឹងការឆ្លងមេរោគអេដស៍
- ការបញ្ជូនទៅទទួលសេវានានា
- ផ្តល់ឯកសារ និងព័ត៌មាន

### *២.៤.៥.១ ការយល់ព្រមដោយមានការផ្តល់ព័ត៌មានជាមុន*[21]

មុនពេលធ្វើការពិនិត្យសុខភាពទាំងមូលរបស់ជនរងគ្រោះ ជាការសំខាន់ដែលទទួលបានការយល់ព្រមដោយការជូនដំណឹងជាមុន។ តាមការអនុវត្តជាក់ស្តែង ការទទួលបានការយល់ព្រមដោយមានការជូនដំណឹងពេញលេញគឺជាការពន្យល់រាល់ទិដ្ឋភាពនៃការថែទាំជនរងគ្រោះ។ អ្នកជំងឺត្រូវយល់អំពីជម្រើសបើកទូលាយសម្រាប់ខ្លួនគាត់ ហើយគាត់ត្រូវទទួលព័ត៌មានគ្រប់គ្រាន់ដើម្បីសម្រេចចិត្តលើការព្យាបាល។ អ្នកថែទាំសុខភាពត្រូវជូនដំណឹងដល់ជនរងគ្រោះដោយសារការចាប់រំលោភ ឬដោយសារអំពើហិង្សា ថាគាត់អាចបដិសេធផ្នែកណាមួយនៃការពិនិត្យ ឬការព្យាបាល បាន។

ក្នុងដំណើរការនៃការយល់ព្រម អ្នកផ្តល់ការថែទាំសុខភាពត្រូវ៖

- ផ្តល់ពត៌មានស្តីពីផលវិបាកនៃការព្យាបាលដែលទាក់ទងនឹងការចាប់រំលោភឬអំពើហិង្សាលើផ្លូវភេទរួមមានការប្រឈមមុខនឹងការឆ្លងនៃជំងឺកាមរោគ មេរោគអេដស៍ និងការមានផ្ទៃពោះ
- ផ្តល់ពត៌មានស្តីពីលទ្ធភាពនៃការការពារកំណើតបន្ទាន់ និងការធ្វើតេស្តឈាមរកមេរោគអេដស៍
- ពន្យល់ជនរងគ្រោះពីតួនាទីក្នុងការព្យាបាលរបស់អ្នកផ្តល់ការថែទាំសុខភាព និងសារសំខាន់នៃការចងក្រងឯកសារអំពីការពិនិត្យសុខភាពសម្រាប់កំណត់ត្រារបស់ជនរងគ្រោះ
- ពន្យល់ពីទម្រង់ការសម្រាប់ការប្រមូលភស្តុតាងកោសល្យវិច័យ ហើយភស្តុតាងដែលបានប្រមូលអាចត្រូវបានប្រើប្រាស់ដើម្បីផ្តល់ភស្តុតាងនៅក្នុងតុលាការ
- ពន្យល់ឱ្យបានគ្រប់គ្រាន់អំពីទិដ្ឋភាពនៃការព្យាបាលក្រោយមានអំពើហិង្សាទៅលើស្ត្រី
- ផលវិបាកផ្សេងៗនៃអំពើហិង្សាទៅលើស្ត្រីនឹងត្រូវបានពន្យល់ដោយប៉ូលីស ជនបង្គោលនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ប៉ូលីសយុត្តិធម៌របស់ក្រសួងកិច្ចការនារីនិងប្រព័ន្ធច្បាប់

ប្រសិនបើការចាប់រំលោភ ឬអំពើហិង្សាលើផ្លូវភេទត្រូវបានប្រព្រឹត្តលើជនរងគ្រោះ វិធីល្អបំផុតគឺត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកភ្លាមៗដើម្បីព្យាបាលឱ្យបានគ្រប់ជ្រុងជ្រោយនិង *ថែទាំបង្ការ* ទោះបីអ្នកជំងឺមិនព្រមទទួលយកការពិនិត្យតាមលក្ខណៈវេជ្ជសាស្ត្រកោសល្យវិច័យក៏ដោយ។ *ទោះជាយ៉ាងណា អ្នកជំងឺពេញវ័យមានសិទ្ធិបដិសេធ។*

---

[21]ឧបសម្ពន្ធ១ ៖ បែបបទយល់ព្រម

ត្រូវគោរពការសម្រេចចិត្តរបស់ជនរងគ្រោះ ទោះជម្រើសគឺជាចំណុច ក ខ ឬ គ ៖

| **កម្រិតនៃការយល់ព្រម (ការថែទាំ)** | **ទីតាំងនៃសេវាថែទាំសុខភាព** |
|---|---|
| ក). មានតែការពិនិត្យរាងកាយប៉ុណ្ណោះ (រួមមាន ការពិនិត្យសុខភាព និងការពិនិត្យអាងត្រគាក) | -មន្ទីរពេទ្យបង្អែកដែលមាន CPA 1, CPA 2ឬ CPA 3<br>-មណ្ឌលសុខភាពអាចផ្តល់ការព្យាបាលសម្រាប់របួសស្រាល ការព្យាបាលបង្ការមួយចំនួន ហើយបញ្ជូនទៅសេវាថែទាំសុខភាពតាមសហគមន៍តែប៉ុណ្ណោះ |
| ខ). ការពិនិត្យរាងកាយ រួមមានការប្រមូលភស្តុតាង (ការពិនិត្យវេជ្ជសាស្ត្រកោសល្យវិច័យ) | មន្ទីរពេទ្យបង្អែក<br>***បញ្ជូនទៅមន្ទីរពេទ្យបង្អែកមួយដែលមានផ្តល់ការពិនិត្យកោសល្យវិច័យភ្លាមៗ***<br>(ប្រសិនបើត្រូវការរក្សាលំនឹងរបួស) |
| គ). ការពិនិត្យរាងកាយ រួមមានការប្រមូលភស្តុតាង (ការពិនិត្យវេជ្ជសាស្ត្រកោសល្យវិច័យ) និងការប្រគល់ភស្តុតាងទៅនគរបាល | មន្ទីរពេទ្យបង្អែក<br>***បញ្ជូនទៅមន្ទីរពេទ្យបង្អែកមួយដែលមានផ្តល់ការពិនិត្យកោសល្យវិច័យភ្លាមៗ***<br>និង ***បញ្ជូនទៅនគរបាល***<br>(ប្រសិនបើត្រូវការរក្សាលំនឹងរបួស) |

**ការពិនិត្យវេជ្ជសាស្ត្រកោសល្យវិច័យត្រូវធ្វើនៅមន្ទីរពេទ្យបង្អែកឱ្យរួចរាល់ដោយហេតុថាមន្ទីរពេទ្យបង្អែកមានសិទ្ធិចេញលិខិតបញ្ជាក់ការធ្វើ កោសល្យវិច័យវេជ្ជសាស្ត្រ។**

ហាមបង្ខំស្ត្រីឲ្យនិយាយអំពីការរំលោភ ប្រសិនបើគាត់មិនចង់និយាយ។រាល់ករណីទាំងអស់ត្រូវកំណត់សំណួរចាំបាច់សម្រាប់ការថែទាំសុខភាព។ ប៉ុន្តែ ប្រសិនបើស្ត្រីចង់និយាយអំពីអ្វីដែលបានកើតឡើង សូមស្តាប់ដោយក្តីអាណិតអាសូរ ហើយអនុញ្ញាតឲ្យគាត់និយាយ។

### ***២.៤.៥.២ ការយកប្រវត្តិជនរងគ្រោះ***[22]

#### **២.៤.៥.២.១ ព័ត៌មានទូទៅ**

- ឈ្មោះ អាស័យដ្ឋាន កន្លែងស្នាក់នៅ លេខទូរស័ព្ទ ភេទ ថ្ងៃខែឆ្នាំកំណើត (ឬអាយុ)
- សុខភាពទូទៅ
  - សូមប្រាប់ខ្ញុំអំពីសុខភាពទូទៅរបស់អ្នក?
  - តើថ្មីៗនេះអ្នកធ្លាប់មកជួបវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកាឬទេ?
  - តើអ្នកធ្លាប់ធ្វើរោគវិនិច្ឆ័យជំងឺណាមួយទេ?
  - តើអ្នកធ្លាប់វះកាត់ពីមុនទេ?
  - តើអ្នកមានជំងឺឆ្លងអ្វីដែរទេ?

[22]ឧបសម្ព័ន្ធ២ ៖ បែបបទនៃឯកសារអំពើហឹង្សាទៅលើស្ត្រី និងកុមារ

- តើអ្នកមានអាលែកហ្ស៊ី/ប្រតិកម្មដែរទេ?
- តើសព្វថ្ងៃអ្នកពិសាថ្នាំអ្វីដែរទេ?

ជនរងគ្រោះអាចស្នើ ឬមិនស្នើឱ្យមានសាច់ញាតិនៅក្បែរនៅពេលសួរប្រវត្តិ និងពិនិត្យ។ ត្រូវគោរពរាល់ការសម្រេចចិត្តទាំងអស់របស់ជនរងគ្រោះ។រាល់វត្តមានបុគ្គលិកណាម្នាក់ត្រូវតែមានការយល់ព្រមពីជនរងគ្រោះ។

### ២.៤.៥.២.២ ការបរិយាយអំពីហេតុការណ៍

ជាការសំខាន់ណាស់ដែលអ្នកផ្តល់ការថែទាំសុខភាពយល់ពីពត៌មានលម្អិតអំពីអ្វីដែលបានកើតឡើងដើម្បី ពិនិត្យរករបួសដែលអាចមាន៖

- បរិយាយអំពីអ្វីដែលបានកើតឡើង ហើយកត់ត្រាកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង។
- ទទួលពត៌មានអំពីចារី (ប្រុស ស្រី អាយុ ទីកន្លែង)?
- តើការបំពានកើតឡើងនៅពេលណា?
- តើមានការស៊កបញ្ចូលដែរទេ (មាត់ យោនី ឬរន្ធគូទ)
- តើអ្នកបំពានបានបង្ខំខាងរាងកាយ ឬផ្លូវចិត្តឬទេ?
- តើអ្នកបំពានបានប្រើវត្ថុអ្វីដែរទេ? តើមានអ្នកបំពានប៉ុន្មាននាក់នៅទីនោះ?
- តើវាជាការបំពានតែម្តង ឬបន្តមាននៅប៉ុន្មានម៉ោងក្រោយ ឬប៉ុន្មានថ្ងៃក្រោយទៀត?
- តើជនរងគ្រោះបានបាត់បង់ស្មារតីដែរឬទេ ហើយតើគាត់ស្គាល់អ្នកបំពានដែរទេ?
- តើជនរងគ្រោះធ្វើអ្វីបន្ទាប់ពីហេតុការណ៍បានកើតឡើង?
  សួរថាតើជនរងគ្រោះបានងូតទឹក បត់ជើងតូច ក្អួត ។ល។ ចាប់តាំងពីជួបហេតុការណ៍មកដែរឬទេ។ វាអាចប៉ះពាល់ដល់ការប្រមូលភស្តុតាងកោសល្យវិច័យ។

> ពន្យល់ថាការសិក្សាអំពីអ្វីដែលបានកើតឡើងនឹងជួយអ្នកឲ្យផ្តល់ការព្យាបាលដ៏ល្អបំផុត។ ធានាជូនជនរងគ្រោះថាអ្នកនឹងរក្សាការសម្ងាត់នូវអ្វីដែលគាត់បាននិយាយ លុះត្រាតែគាត់ចង់ឲ្យប៉ូលីសពិនិត្យសំណុំរឿងរបស់គាត់។
>
> ជៀសវាងការស្តីបន្ទោសជនរងគ្រោះដោយសំណួរ "តើអ្នកធ្វើអ្វីនៅទីនោះម្នាក់ឯង ឬហេតុអ្វីបានជាអ្នក...?"

### ២.៤.៥.២.៣ ប្រវត្តិរោគស្ត្រី

- កត់ត្រាកាលបរិច្ឆេទនៃថ្ងៃដំបូងនៃការមករដូវចុងក្រោយបង្អស់។
- សួរប្រវត្តិរួមភេទកាលពីពេលកន្លងមក និងថាតើពួកគេបានព្រមព្រៀងគ្នាដែរទេ។ សួរថាតើជនរងគ្រោះធ្លាប់មានដៃគូរួមភេទដែរទេ។
- សួរអំពីពេលដែលជនរងគ្រោះបានរួមភេទចុងក្រោយ មុនពេលហេតុការណ៍កើតឡើង។
- សួរជនរងគ្រោះថាតើធ្លាប់មានជំងឺកាមរោគកាលពីមុន និងបានព្យាបាលដែរទេ។
- សួរជនរងគ្រោះថាតើធ្លាប់ធ្វើតេស្តរកមេរោគអេដស៍ដែរទេ ហើយស្ថានភាពមេរោគអេដស៍យ៉ាងណាដែរ។
- សួរជនរងគ្រោះថាតើធ្លាប់មានផ្ទៃពោះដែរទេ។ ប្រសិនបើមាន តើមានលទ្ធផលអ្វី។

- សួរជនរងគ្រោះថាតើធ្លាប់ពន្យារកំណើតដែរទេ។ ប្រសិនបើមាន សួរថាតើពួកគាត់ប្រើប្រាស់មធ្យោបាយពន្យារកំណើតប្រភេទអ្វី ប្រើប្រាស់តាំងពីពេលណា និងបានប្រើទៀងទាត់ដែរទេ។

### *២.៤.៥.៣ ការពិនិត្យរាងកាយ*[23]

#### ២.៤.៥.៣.១ ការពិចារណាទូទៅសម្រាប់ការពិនិត្យរាងកាយ

- បើមានតែការយល់ព្រមសម្រាប់តែការពិនិត្យរាងកាយ និងមិនសម្រាប់ការប្រមូលភស្តុតាងកោសល្យវិច័យ កិច្ចការខ្លះនឹងមិនចាំបាច់ធ្វើទេ។
- នៅជំហាននៃការពិនិត្យនីមួយៗ សូមពន្យល់អំពីអ្វីដែលនឹងកើតឡើង និងសួរថាតើគាត់មានសំណួរដែរទេ។ គ្រូពេទ្យត្រូវពិនិត្យជនរងគ្រោះតាមលំដាប់លំដោយ។
- ត្រូវប្រាប់ជនរងគ្រោះថាក្នុងអំឡុងពេលពិនិត្យសុខភាព គាត់អាចសុំអ្នកផ្តល់សេវាឱ្យឈប់បាន។
- ការពិនិត្យត្រូវធ្វើឡើងចាប់ពីក្បាលដល់ចុងជើង ដោយផ្តោតជាពិសេសលើមុខ អវយវៈខាងលើ ក សុដន់ ភ្លៅ និងយោនី។

> មុនពេលចាប់ផ្តើមជំហាននៃការពិនិត្យនីមួយៗ សូមពន្យល់អំពីអ្វីដែលអ្នកកំពុងធ្វើ និងអ្វីដែលនឹងកើតឡើង។

- ជនរងគ្រោះត្រូវទទួលបានការព្យាបាលរបួសរាងកាយ។
- ជនរងគ្រោះត្រូវទទួលបាននូវការការពារកំណើតបន្ទាន់ បើគាត់ស្ថិតក្នុងអាយុដែលអាចបង្កកំណើតបាន។
- ជនរងគ្រោះត្រូវទទួលវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ បើស្ថិតក្នុងពេលប្រឈមនឹងការឆ្លងមេរោគអេដស៍។ ជនរងគ្រោះដែលស្ថិតក្នុងពេលប្រឈមនឹងការឆ្លងមេរោគអេដស៍ត្រូវបានអនុវត្តតាមផ្នែក ២.៧.៣ ។

#### *ការពិចារណាបន្ថែមប្រសិនបើភស្តុតាងត្រូវបានប្រមូលសម្រាប់ការធ្វើកោសល្យវិច័យ*

- សំណាកដែលត្រូវបានប្រមូលសម្រាប់ការធ្វើកោសល្យវិច័យត្រូវដាក់ក្នុងថង់ក្រដាស។ ប្រសិនបើជនរងគ្រោះត្រូវដោះសំលៀកបំពាក់ចេញ គាត់អាចធ្វើដូចនេះបានលើក្រដាសមួយផ្ទាំងធំដើម្បីប្រមូលកំទេចកំទី ដូចជារុក្ខជាតិ សត្វល្អិត ធូលីដី មួកសក់ដែលមានព័ត៌មានទាក់ទងនឹងការបំពាន ឬអំពើហិង្សា។
- ការពិនិត្យត្រូវបានធ្វើឡើងបានយ៉ាងល្អបំផុតនៅក្រោមពន្លឺធម្មជាតិ។ ប៉ុន្តែ មានអំពូលភ្លើងពិសេសដែលអាចមើលឃើញរបួសកាន់តែច្បាស់ ដូចជាអំពូលស្ពេនពណ៌ស្វាយ ឬអំពូលស្វាយអ៊ុលត្រា។
- ទន្ទឹមនេះ ត្រូវផ្តិតយកផ្នែកខាងលើនៃស្បែក ទឹកមាត់ ទឹករំអិល ផ្នែកខាងក្រៅនិងខាងក្នុងយោនី និងរន្ធគូទ ហើយក៏ត្រូវយកសំណាកទឹកនោម និងឈាមតាមលំដាប់លំដោយផងដែរ។

---

[23] ឧបសម្ពន្ធ៣ ៖ គំនូសតាង

- ប្រសិនបើសំណាកត្រូវបានប្រមូល (ទឹកនោម ទឹកកាម និងភស្តុតាងដទៃទៀត) ត្រូវទុកសំណាកឱ្យបានត្រឹមត្រូវ និងមានហត្ថលេខា និងបញ្ជូនទៅកាន់មន្ទីរពិសោធន៍ដោយបុគ្គលិកដែលបានបញ្ជាក់ត្រឹមត្រូវដើម្បីរក្សាភស្តុតាង។
- លទ្ធផលទាំងអស់ត្រូវកត់ត្រាលើបែបបទវេជ្ជសាស្ត្រកោសល្យវិច័យ។

**២.៤.៥.៣.២ ការពិនិត្យពីក្បាលដល់ចុងជើង**

- កត់ត្រាលក្ខណសម្បត្តិខាងក្រៅទូទៅរបស់ជនរងគ្រោះ
- ពិនិត្យសញ្ញាជីវិត
- ពិនិត្យអវយវៈខាងលើដើម្បីរកសញ្ញានៃរបួសនានា
- ពិនិត្យមើលមុខ ភ្នែក ត្រចៀក
- ពិនិត្យស្បែកលលាដ៍ក្បាលដើម្បីរកមើលរបួស ឬសញ្ញានៃការរលាក។
- ពិនិត្យកដើម្បីរកមើលស្នាមជាំ និងការបំពានដែលគ្រោះថ្នាក់ដល់ជីវិត
- ពិនិត្យសុដន់ និងតួខ្លួនដើម្បីរកមើលស្នាមខាំ ឬរបួសផ្សេងៗ
- ពិនិត្យផ្ទៃពោះ និងដើមទ្រូងរកមើលរបួសខាងក្នុង ឬការមានគភ៌
- ពិនិត្យអវយវៈខាងក្រោមឱ្យបានម៉ត់ចត់
- *ប្រសិនបើធ្វើកោសល្យវិច័យ សូមប្រមូលសំណាកដែលអ្នកបានពិនិត្យជនរងគ្រោះដូចរៀបរាប់ខាងលើ*

**២.៤.៥.៣.៣ ការពិនិត្យប្រដាប់បន្តពូជ និងរន្ធគូទ**

ពន្យល់អំពីទម្រង់ការទៅជនរងគ្រោះ ដោយផ្តល់ព័ត៌មានលម្អិតនៃជំហាននីមួយៗ។

- ពិនិត្យប្រដាប់បន្តពូជខាងក្រៅ
- ពិនិត្យបបូរមាត់យោនី និងអវយវៈផ្សេងទៀត

***បន្ថែមទម្រង់ការ ប្រសិនបើភស្តុតាងត្រូវបានប្រមូលសម្រាប់ការធ្វើកោសល្យវិច័យ***

- ប្រើប្រាស់សម្ភារកៀរទឹករំអិលមាត់ ទាំងអស់ តាមលំដាប់ខាងក្រោម ខាងក្រៅយោនី ខាងក្នុងយោនីផ្នែកជ្រៅក្នុងយោនី និងសម្ភារជូតរន្ធគូទ។ សម្ភារកៀរទឹករំអិលផ្សេងទៀតគឺប្រើសម្រាប់កន្លែងមានទឹករំអិល ក្នុងករណីដែលមានការរួមភេទតាមមាត់និងនៅលើស្បែក នៅពេលមានស្នាមប្រឡាក់សង្ស័យថាជាទឹកកាមនៅលើស្បែក។
- ពិនិត្យដោយប្រើប្រាស់ឧបករណ៍បើកមាត់ស្បូន និងឌីជីថល (មិនត្រូវពិនិត្យនៅមុនពេលយកសំណាក ទោះក្នុងកាលៈទេសៈណាក៏ដោយ)។
- យករោមប្រដាប់ភេទ និងផ្នែកនៃភស្តុតាងរាងកាយណាមួយដែលអាចមើលឃើញនៅក្នុងប្រដាប់បន្តពូជ
- កត់ត្រាស្នាមរបួសដោយផ្តល់ទីតាំង ទំហំ ប្រភេទ (ស្នាមជាំ របួសដោយសារការចាក់ របួសដោយសារការមុត ឬការរលាត់ស្បែក)

***២.៤.៥.៤ ការអង្កេតក្នុងបន្ទប់ពិសោធន៍***

ការធ្វើតេស្តក្នុងបន្ទប់ពិសោធន៍ធម្មតាទូទៅសម្រាប់ជនរងគ្រោះដោយសារការបំពានផ្លូវភេទអាចរួមមានការធ្វើតេស្ត និងផ្តល់យោបល់ដោយរក្សាការសម្ងាត់ដោយស្ម័គ្រចិត្តអំពីមេរោគអេដស៍ ការពិសោធន៍មើលផ្ទៃពោះ ការពិ

និត្យ និងការវិភាគទឹកនោម និងជំងឺកាមរោគ ប៉ុន្តែការធ្វើតេស្តបន្ថែមអាចធ្វើបានអាស្រ័យលើគំនិតរបស់គ្រូពេទ្យ និងទម្រង់ការសម្រាប់កន្លែងព្យាបាលសុខភាព។

### ២.៤.៦ ការព្យាបាលស្ត្រីរងគ្រោះដោយសារអំពើហឹង្សា

#### *២.៤.៦.១ ការពិចារណាទូទៅ*

ជនរងគ្រោះដោយសារអំពើហឹង្សាទៅលើស្ត្រីត្រូវព្យាបាលជាបន្ទាន់ និងមិនត្រូវឱ្យពួកគាត់រង់ចាំទេ។

#### *២.៤.៦.២ របួសរាងកាយ*

- បញ្ជូនជនរងគ្រោះដែលមានស្ថានភាពធ្ងន់ធ្ងរទៅសង្គ្រោះបន្ទាន់
- ព្យាបាលជនរងគ្រោះដែលមានរបួសរាងកាយតិចតួចអាស្រ័យតាមពិធីការលក្ខណៈស្តង់ដារ

ចំពោះជនរងគ្រោះដែលមានរបួសរាងកាយធ្ងន់ធ្ងរដែលបណ្តាលឱ្យមានការរលាត់ស្បែក និងស្បែកដែលចេញខ្លាញ់ត្រូវចាក់ថ្នាំតេតាណូសតុកសូអ៊ីតចំនួន ០,៥ មីលីលីត្រអាស្រ័យតាមកាលវិភាគនៅក្នុងតារាងខាងក្រោម។

| កម្រិតថ្នាំដែលត្រូវប្រើ | កាលវិភាគលេបថ្នាំ | រយៈពេលនៃការស៊ាំនឹងមេរោគ |
|---|---|---|
| កាលវិភាគកម្រិតថ្នាំដែលត្រូវប្រើ | កាលវិភាគនៃការចាក់ | មិនមាន |
| កំរិតថ្នាំបង្ការជំងឺតេតាណូស លើកទី១ | ការចាក់លើកដំបូង | ចាប់ពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ |
| កំរិតថ្នាំបង្ការជំងឺតេតាណូស លើកទី២ | មួយខែបន្ទាប់ពីការចាក់លើកដំបូង | ៥ ឆ្នាំ |
| កំរិតថ្នាំបង្ការជំងឺតេតាណូស លើកទី៣ | មួយខែបន្ទាប់ពីការចាក់លើកទី២ | ១០ ឆ្នាំ |
| កំរិតថ្នាំបង្ការជំងឺតេតាណូស លើកទី៤ | មួយឆ្នាំបន្ទាប់ពីការចាក់លើកទី៣ | ២០ ឆ្នាំ |

ថ្នាំបង្ការការពារជំងឺតេតាណូសគួរផ្តល់ជូនជនរងគ្រោះដោយអំពើហឹង្សាផ្លូវភេទទាំងអស់ (គ្រប់ភេទ និងអាយុ) ប្រសិនបើមានកន្លែងរបួសកើតមានលើស្បែក និង/ឬភ្នាសរំអិល។

#### *២.៤.៦.៣ ការព្យាបាលបង្ការ*

##### ២.៤.៦.៣.១ គោលការណ៍ណែនាំសម្រាប់ការការពារមេរោគអេដស៍

វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ គឺដើម្បីការពារមេរោគអេដស៍គួរចាប់ផ្តើមភ្លាមក្នុងរយៈពេល ៧២ ម៉ោង បន្ទាប់ពីប៉ះពាល់មេរោគអេដស៍។ វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ត្រូវបានណែនាំសម្រាប់ស្ត្រី និងកុមារដែលប្រឈមនឹងការឆ្លងមេរោគអេដស៍។ និយាយជាមួយស្ត្រី ឬកុមារ (ឪពុកម្តាយ/អាណាព្យាបាល) ថាតើវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ស័ក្តិសមនឹងស្ថានភាពរបស់ពួកគាត់ឬទេ។ អ្នកគួរពិចារណាអំពីវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ប្រសិនបើ៖

- ចារីគឺជាអ្នកដែលបានឆ្លងមេរោគអេដស៍ ឬមិនស្គាល់ស្ថានភាពសុខភាព
- ស្ត្រីមិនបានដឹងអំពីលទ្ធផលមេរោគអេដស៍វិជ្ជមាន
- ស្ត្រីដែលបានប៉ះពាល់ឈាម ឬទឹកកាម
- ស្ត្រីដែលធ្លាប់បានរួមភេទតាមមាត់ ទ្វារមាស និង/ឬតាមរន្ធគូទ

ការណែនាំពីវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍គួរផ្អែកលើការណែនាំពីមេរោគអេដស៍ និងការគ្រប់គ្រងមេរោគអេដស៍ជាតិបច្ចុប្បន្ន។ ចងចាំថា ប្រសិនបើចាប់ផ្តើមធ្វើការការពារមេរោគអេដស៍កាន់តែយូរ នោះប្រសិទ្ធភាពនៃទម្រង់ការកាន់តែថយចុះ។

- វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍គួរចាប់ផ្តើមអនុវត្តក្នុងអំឡុងពេល ៧២ ម៉ោង។
- ការពិគ្រោះមុន និងក្រោយការធ្វើតេស្តមេរោគអេដស៍គួរតែចាប់ផ្តើមធ្វើមុន និងក្រោយការធ្វើតេស្តរកមេរោគអេដស៍បានបញ្ចប់ជាបន្តបន្ទាប់។
- បើលទ្ធផលនៃការធ្វើតេស្តបង្ហាញថាអវិជ្ជមាន សូមផ្តល់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ក្នុងរយៈពេល ២៨ ថ្ងៃ ផ្តល់ការប្រឹក្សាយោបល់អំពីការគោរពតាមវិធី មុនពេលប្រើប្រាស់ថ្នាំ សូមប្រាប់ជនរងគ្រោះអំពីវិធីការពាររបៀបកាត់បន្ថយការឆ្លងមេរោគអេដស៍ ប្រាប់ជនរងគ្រោះអំពីផលប៉ះពាល់ចម្បងរបៀបដោះស្រាយ រួមទាំងការថយចុះនៃផលប៉ះពាល់តាមពេលវេលា។
- ប្រសិនបើលទ្ធផលបង្ហាញថាវិជ្ជមានឈប់បន្តវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ដែលនេះបង្ហាញថា ស្ត្រីរងគ្រោះដែលមានផ្ទុកមេរោគអេដស៍ ហើយត្រូវបញ្ជូនទៅព្យាបាលបន្តឱ្យសមស្រប។
- ត្រូវបានពិនិត្យមើល អេម៉ូគ្លូប៊ីន អាឡានីន អាមីណូ ត្រង់ហ្វេរ៉ាស និងស្ពារ៉ាត អាមីណូ ត្រង់ហ្វេរ៉ាស។

## ២.៤.៦.៣.២ ការណែនាំសម្រាប់ការបង្ការការមានផ្ទៃពោះ

ស្ត្រី ឬកុមារអាយុក្រោម ១៨ ឆ្នាំ ចាប់ផ្តើមមានរដូវដែលត្រូវបានចាប់រំលោភ ទំនងជាអាចមានផ្ទៃពោះ។ អ្នកផ្តល់ការថែទាំសុខភាពគួរសួរថា តើអ្នកជំងឺធ្លាប់បានប្រើមធ្យោបាយពន្យារកំណើតដែលមានប្រសិទ្ធភាពឬទេ ដូចជា ថ្នាំលេប ថ្នាំចាក់ កងដាក់ដៃ កងដាក់ក្នុងស្បូន ឬវិធីបញ្ឈប់កំណើតរបស់ស្ត្រី។ បើបានការពារនោះគាត់ប្រហែលមិនមានផ្ទៃពោះទេ។ ប្រសិនបើគាត់មិនបានប្រើប្រាស់ការគ្រប់គ្រងកំណើតឱ្យមានប្រសិទ្ធភាពទេការការពារកំណើតបន្ទាន់គួរត្រូវបានផ្តល់ទៅអ្នកមិនទាន់មានផ្ទៃពោះនិងស្ត្រីដែលស្ថិតនៅវ័យអាចមានផ្ទៃពោះ។

- ការធ្វើតេស្តរកមើលការមានផ្ទៃពោះគួរធ្វើឡើងពីដំបូង និងមិនអាចយឺតយ៉ាវ កម្រិតថ្នាំតាមដែលត្រូវប្រើតាមវិធីការការពារកំណើតដោយការរំលោភ
- ការការពារកំណើតក្រោយពេលរួមភេទមានប្រសិទ្ធភាពខ្ពស់នៅពេលត្រូវបានផ្តល់ក្នុងរយៈពេល ១២០ ម៉ោង (៥ ថ្ងៃ) បន្ទាប់ពីការរំលោភសេពសន្ថវៈ។
- ការធ្វើតេស្តរកការមានផ្ទៃពោះមួយផ្សេងទៀតគួរធ្វើឡើង ៦ សប្តាហ៍ បន្ទាប់ពីការចាប់រំលោភនៅពេលណាត់ជួបលើកក្រោយ សួរថាតើពួកគេមានប្រើប្រាស់មធ្យោបាយការពារកំណើតបន្ទាន់ បន្ទាប់ពីការចាប់រំលោភដែរឬទេ។

**កម្រិតនិងរបបថ្នាំការពារកំណើតបន្ទាន់**

| | | |
|---|---|---|
| គ្រាប់ថ្នាំ Progestinតែមួយមុខ | Prostinor 2 | ១ គ្រាប់ ១២ ម៉ោង ផ្សេងពីគ្នា (សរុប ២ គ្រាប់) ឬ ២ គ្រាប់ក្នុងពេលតែមួយ |
| គ្រាប់ថ្នាំ Progestinតែមួយមុខ (1.5mg Levonorgestrel) | Norlevo | ១គ្រាប់ (លេបតែម្តង) |
| ថ្នាំគ្រាប់ដែលមានអ័រម៉ូនលាយបញ្ចូលគ្នារួមជាមួយនឹងអ័រម៉ូន អឺស្ត្រូសែនដែលមានកំរិតខ្ពស់(៥០ μg) | Euginon | ២គ្រាប់ ១២ ម៉ោង ផ្សេងពីគ្នា (សរុប ៤គ្រាប់) |
| ថ្នាំគ្រាប់ដែលមានអ័រម៉ូនលាយបញ្ចូលគ្នារួមជាមួយនឹង អ័រម៉ូន អឺស្ត្រូសែនដែលមានកំរិតទាប (៣០ μg) | Nordette Microginon | ៤គ្រាប់ ១២ ម៉ោង ផ្សេងពីគ្នា (សរុប ៨ គ្រាប់) |

ចំណាំ៖ ជនរងគ្រោះអាចជ្រើសរើសយកវិធីណាមួយក្នុងចំណោម៣វិធីខាងលើ។

### ២.៤.៦.៣.៣ ការការពារជំងឺកាមរោគ

ស្ត្រីដែលរងការរំលោភសេពសន្ថវៈ គួរទទួលបានថ្នាំអង់ទីប៊ីយ៉ូទិក និងព្យាបាលជំងឺកាមរោគ – សិរមាន់ ជំងឺប្រមេះទឹកបាយ ប្រមេះថ្លា និងជំងឺស្វាយ។

- ផ្តល់ការព្យាបាលភ្លាមៗ
- មិនចាំបាច់ធ្វើតេស្តជំងឺកាមរោគមុនពេលព្យាបាលទេ
- ផ្តល់ការព្យាបាលបង្ការតាមរយៈថ្នាំអង់ទីប៊ីយ៉ូទិកចំពោះជំងឺកាមរោគ

### ថ្នាំប្រើប្រាស់សម្រាប់ការពារជំងឺកាមរោគ

| | | |
|---|---|---|
| ស្ត្រីពេញវ័យដែលគ្មានផ្ទៃពោះ | Norfloxacin | ៨០០ mg Stat |
| | Doxycycline | ១០០ MG BD ក្នុងមួយសប្តាហ៍ |
| ស្ត្រីមានផ្ទៃពោះ | Spectimonycin | ២ g Stat |
| | Amoxycillin + Probenicid | ៣ g Stat<br>១ g Stat |
| | Erythromycin | ៥០០mg QDS ក្នុងមួយសប្តាហ៍ |
| កុមារ | Amoxycillin | ១៥ mg/kg TDS ក្នុងមួយសប្តាហ៍ |
| | Erythomycin | ១០ mg/kg QDS ក្នុងមួយសប្តាហ៍ |

## ២.៤.៧ ការថែទាំតាមដាន និងការបញ្ជូន

### *២.៤.៧.១ ការថែទាំតាមដាន*

អ្នកផ្ដល់ការថែទាំសុខភាពគួរប្រើប្រាស់គោលការណ៍ណែនាំសម្រាប់ការព្យាបាលនីមួយៗ ដើម្បីធ្វើផែនការតាមដាន បន្ទាប់ពីការពិនិត្យ និងការព្យាបាល។ ពេលវេលានៃការទទួលការព្យាបាលគួរត្រូវបានអនុវត្តទៅតាមកាលវិភាគនៃការព្យាបាល។

ជនរងគ្រោះគួរបញ្ជូនទៅផ្នែកវេជ្ជសាស្ត្រនិងផ្នែកច្បាប់បន្ថែមដោយផ្អែកលើផែនការព្យាបាលជនរងគ្រោះម្នាក់ៗ។ជនរងគ្រោះគួរតែយល់ដឹងពីសេវានានាអាស្រ័យលើតម្រូវការរបស់ជនរងគ្រោះ
ម្នាក់។

*ព័ត៌មានជំនួយសម្រាប់ការបញ្ជូន*

ត្រូវប្រាកដថា ការបញ្ជូនបំពេញតាមសេចក្ដីត្រូវការ និងការបារម្ភដ៏សំខាន់របស់គាត់

ប្រសិនបើគាត់ប្រាប់ថាមានបញ្ហាទាក់ទងនឹងការជួយគាត់ក្នុងការពិចារណាអំពីវិធីនានាដើម្បីដោះស្រាយបញ្ហាទាំងនោះ

ប្រសិនបើគាត់ទទួលយកការបញ្ជូនទៅមន្ទីរពេទ្យ សូមផ្ដល់ភាពងាយស្រួលដល់គាត់

ប្រាប់គាត់ពីទីកន្លែងដែលត្រូវទៅ អាសយដ្ឋាន មធ្យោបាយដែលអាចទៅដល់ទីនោះ និងនរណាដែលគាត់នឹងជួប

ស្នើការណាត់ជួបឲ្យគាត់

### *២.៤.៧.២ ការបញ្ជូនជនរងគ្រោះទៅរកសេវាអន្តរាគមន៍ផ្នែកច្បាប់ និងពហុវិស័យ*

ជាធម្មតាវាមិនអាចទៅរួចទេដែលអ្នកផ្ដល់ការថែទាំសុខភាពអាចឆ្លើយតបរាល់តម្រូវការរបស់ជនរងគ្រោះនោះ។ គាត់អាចត្រូវការពេលវេលាដើម្បីសម្រេចចិត្ត។ រាល់ការបញ្ជូនទៅសេវាផ្នែកច្បាប់ ឬសហគមន៍ និងការគាំទ្រទាំងអស់គួរធ្វើដោយស្ម័គ្រចិត្ត និងមានការយល់ព្រមពីជនរងគ្រោះពេញវ័យ។

### *២.៤.៧.៣ ការឆ្លើយតបផ្នែកច្បាប់*

គួរតែគោរពសិទ្ធិនៃការស្នើសុំការអន្តរាគមន៍ផ្នែកច្បាប់របស់ជនរងគ្រោះ។ ប្រសិនបើជនរងគ្រោះជ្រើសរើសយកការរាយការណ៍បទល្មើស និងស្វែងរកការអន្តរាគមន៍ផ្នែកច្បាប់ ជម្រើសសម្រាប់ការរាយការណ៍គឺ៖

- នគរបាលឃុំ
- នគរបាលប្រឆាំងការជួញដូរមនុស្សថ្នាក់ស្រុក
- កងរាជអាវុធហត្ថស្រុក
- មេភូមិ មេឃុំ
- មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី
- ព្រះរាជអាជ្ញាតុលាការខេត្ត

### *២.៤.៧.៤ សេវា និងការគាំទ្រផ្សេងទៀតរបស់សហគមន៍សម្រាប់ស្ត្រីរងគ្រោះដោយសារអំពើហិង្សា*

អ្នកជំនាញបានរកឃើញថាស្ត្រីនិងកុមាររងគ្រោះត្រូវការធនធាន និងការគាំទ្រជាច្រើនផ្អែកទៅលើស្ថានភាពរបស់ពួកគេ និងប្រភេទអំពើហិង្សាដែលបានជួបប្រទះ។ សេវាកម្មទាំងនេះរួមមានសេវាដោះស្រាយវិបត្តិ គាំទ្រខាងផ្លូវចិត្តផ្នែកសង្គម និងការផ្ដល់យោបល់បន្ទាប់ពីបានទទួលការថែទាំសុខភាព និងការស្តារនីតិសម្បទានិងសមាហរណកម្ម។ សេវាមួយចំនួនត្រូវបានផ្ដល់ដោយរដ្ឋាភិបាល និងមួយចំនួនត្រូវបានផ្ដល់ដោយអង្គការមិនមែនរដ្ឋាភិបាល។ មណ្ឌលថែទាំសុខភាពត្រូវប្រមូលធនធានដែលមាននៅក្នុងខេត្ត ស្រុក ឃុំដែលពាក់ព័ន្ធនឹងការបញ្ជូន។ វាជាការល្អ

បំផុតដែលមានការយល់ព្រមបញ្ជូនទៅជាផ្លូវការជាមួយនឹងអ្នកផ្តល់សេវាថែទាំ និងជាមួយប្រព័ន្ធពីរបៀបដែលជនរងគ្រោះទទួលសេវាថែទាំសុខភាព។

ឧទាហរណ៍ខ្លះៗនៃសេវាកម្មទាំងនេះមានដូចជាៈ

**ជនបង្គោលនៃគណៈកម្មការឃុំសម្រាប់កិច្ចការនារីនិងកុមារៈ** ជនបង្គោលសម្រាប់ស្ត្រី និងកុមារមានតួនាទីឆ្លើយតប និងបញ្ជូនស្ត្រី និងកុមាររងគ្រោះទៅរដ្ឋាភិបាល ឬធនធានសហគមន៍។

**ការិយាល័យសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាស្រុកៈ**មន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក អាចជួយបញ្ជូនស្ត្រីទៅក្នុងសហគមន៍វិញ ប្រសិនបើគាត់ធ្លាប់រស់នៅក្នុងមណ្ឌលស្នាក់នៅដែលមានសុវត្ថិភាព។

**ការិយាល័យកិច្ចការនារីៈ** បុគ្គលិកការិយាល័យកិច្ចការនារីអាចជួយបញ្ជូនស្ត្រីរងគ្រោះទៅកាន់សេវាផ្សេង ដូចជាប៉ូលិសយុត្តិធម៌សម្រាប់ការគាំពារស្របច្បាប់នៅមន្ទីរកិច្ចការនារី។

**មណ្ឌលសុវត្ថិភាពៈ** អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផ្តល់មណ្ឌលស្នាក់នៅមានសុវត្ថិភាពសម្រាប់ស្ត្រី និងកុមាររងគ្រោះ។ មណ្ឌលស្នាក់នៅភាគច្រើនគឺស្ថិតនៅទីប្រជុំជន ហើយជនរងគ្រោះអាចស្នាក់នៅរយៈពេលយូរបាន។ ជាទូទៅ មណ្ឌលស្នាក់នៅផ្តល់សេវាគាំទ្រផ្សេងទៀត ដូចជាការផ្តល់យោបល់ ព័ត៌មានស្តីពីជំនួយផ្នែកច្បាប់ ការគាំទ្រ និងការគាំពារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម។

**ពត៌មានស្របច្បាប់ ការគាំទ្រ និងការគាំពារៈ**ព័ត៌មានស្របច្បាប់ ការគាំទ្រ និងការគាំពារត្រូវបានផ្តល់ដោយភ្នាក់ងារនគរបាលយុត្តិធម៌របស់មន្ទីរកិច្ចការនារី (ថ្នាក់ខេត្ត) និងអ្នកផ្តល់សេវាអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ នេះអាចជាទម្រង់នៃព័ត៌មាន តំណាង ឬការគាំពារ និងការគាំទ្រនៅពេលជនរងគ្រោះស្ថិតក្នុងដំណើរការផ្នែកច្បាប់។

**ការពិគ្រោះផ្នែកចិត្តសាស្ត្រសង្គមនិងការគាំទ្រផ្លូវអារម្មណ៍ៈ**ការពិគ្រោះផ្នែកចិត្តសាស្ត្រសង្គម និងការគាំទ្រផ្លូវអារម្មណ៍ជាច្រើនត្រូវបានផ្តល់។អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនមានជំនាញក្នុងការពិគ្រោះផ្នែកចិត្តសាស្ត្រសង្គមជាច្រើនប្រភេទ ដូចជាការពិគ្រោះជាបុគ្គល ឬក្រុម និងជាសេវាផ្សេងទៀតដែលជាផ្នែកមួយនៃសេវាកម្ម។

**ការពង្រឹងអំណាចផ្នែកសេដ្ឋកិច្ចៈ**ទាំងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងរបស់រដ្ឋាភិបាល ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារីផ្តល់ការបណ្តុះបណ្តាលសម្រាប់ស្ត្រីរងគ្រោះក្នុងគោលបំណងលើកកម្ពស់ការពង្រឹងអំណាចផ្នែកសេដ្ឋកិច្ច។ សេវាមួយចំនួនផ្តល់ជូននៅក្នុងមណ្ឌលស្នាក់នៅរបស់អង្គការមិនមែនរដ្ឋាភិបាល ហើយសេវាមួយចំនួនទៀតគឺជាសេវាដាច់ដោយឡែក។

**សមាហរណកម្មៈ** ស្ត្រី និងកុមារដែលធ្លាប់រស់នៅក្នុងមណ្ឌលស្នាក់នៅ ឬមណ្ឌលស្នាក់នៅមានសុវត្ថិភាព អង្គការមិនមែនរដ្ឋាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាផ្តល់សេវាក្នុងការជួយជនរងគ្រោះឱ្យរួបរួមជាមួយសហគមន៍របស់ពួកគេវិញ ឬជាមួយសហគមន៍ផ្សេងទៀត។

### ២.៤.៨ ការចងក្រងឯកសារ

អ្នកផ្តល់ការថែទាំសុខភាពត្រូវៈ

- បំពេញក្រដាសការងារដែលចាំបាច់ ដូចជាបែបបទឯកសារស្តីពីអំពើហឹង្សាទៅលើស្ត្រី

- អ្នកផ្តល់ការថែទាំសុខភាពត្រូវទទួលខុសត្រូវលើការរក្សាទុកបែបបទឯកសារ កំណត់ត្រាវេជ្ជសាស្ត្រ និង សំណាកកោសល្យវិច័យ និង
- អ្នកផ្តល់ការថែទាំសុខភាពគួរតែរក្សាទុកឯកសារនិងទុកកំណត់ត្រាវេជ្ជសាស្ត្រឱ្យត្រឹមត្រូវ និងមានសុវត្ថិភាព សម្រាប់គោលបំណងសុវត្ថិភាព និងការប្រើប្រាស់នៅពេលអនាគត។

## ៣-ការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលទៅនឹងអំពើហឹង្សាទៅលើកុមារ

### ៣.១ គោលការណ៍ណែនាំ

***ធានាសុវត្ថិភាព៖*** រាល់វិធានការដែលត្រូវប្រកាន់យកចំពោះកុមាររងគ្រោះដោយសារអំពើហឹង្សាត្រូវផ្តោតលើការធ្វើឱ្យប្រសើរឡើង ឬថែទាំសុខភាព និងសុវត្ថិភាព និងការមិនទុកឱ្យកុមារស្ថិតក្នុងហានិភ័យខ្ពស់នៃអំពើហឹង្សា។

***ការគោរព និងសេចក្តីថ្លៃថ្នូរចំពោះជនរងគ្រោះ៖*** មតិ ការគិត គំនិតរបស់កុមាររងគ្រោះដោយសារអំពើហឹង្សាគួរត្រូវបានស្តាប់និងទទួលបានការគោរពដោយមិនគិតពីអាយុរបស់ពួកគេ។ គួរគោរព និងមិន "ស្តីបន្ទោសជនរងគ្រោះ" ទេ។ កុមារ និងវ័យជំទង់មានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេផ្អែកលើកម្រិតភាពចាស់ទុំនិងអាយុរបស់ពួកគេ។

***ភាពឯកជន និងការរក្សាការសម្ងាត់៖*** ត្រូវគោរពភាពជាឯកជន និងរក្សាការសម្ងាត់របស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេគ្រប់ពេលវេលា។ សេវាកម្មគួរតែផ្តល់នៅក្នុងបន្ទប់ដាច់ដោយឡែកសមរម្យដែលងាយស្រួលចូលហើយនៅក្បែរបន្ទប់ទឹក។ ពត៌មានអំពីជនរងគ្រោះគួរតែត្រូវបានប្រមូលទុក ប្រើប្រាស់ និងរក្សាជាការសម្ងាត់។ នៅក្នុងកន្លែងព្យាបាលសុខភាពតូចៗ ឬកន្លែងដែលមានកំណត់ អ្នកផ្តល់ការថែទាំសុខភាព ត្រូវមានកន្លែងពិនិត្យដើម្បីធានាបាននូវឯកជនភាព និងរក្សាការសម្ងាត់។ អត្តសញ្ញាណរបស់កុមាររងគ្រោះមិនត្រូវបង្ហាញ ឬពិភាក្សាក្នុងកិច្ចប្រជុំនៅក្នុង ឬនៅក្រៅអាគារដោយគ្មានការអនុញ្ញាតពីជនរងគ្រោះទេ។ នេះមានន័យថា ចែករំលែកតែព័ត៌មានចាំបាច់ដែលយល់ព្រមពីជនរងគ្រោះជាមួយនឹងអ្នកដែលបានចូលរួមក្នុងការផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រប៉ុណ្ណោះ។

រាល់ការពិភាក្សាអំពីបញ្ហាសុខភាព មិនត្រូវបង្ហាញអត្តសញ្ញាណរបស់បុគ្គលឡើយ។ ការបញ្ចេញព័ត៌មានសុខភាព អាចត្រូវបានអនុញ្ញាតដោយមានការយល់ព្រមពីជនរងគ្រោះដូចជា៖

- អ្នកផ្តល់ការព្យាបាលផ្សេងដែលបានចូលរួមក្នុងការថែទាំជនរងគ្រោះ
- បុគ្គលដែលទទួលបន្ទុកនៅមុខតុលាការ ឬមន្ត្រីនគរបាល ប្រសិនបើជនរងគ្រោះស្នើ
- មនុស្សផ្សេងទៀតដែលបានស្នើសុំដោយជនរងគ្រោះ។

ប្រសិនបើការធ្វើរបាយការណ៍ចាំបាច់សម្រាប់សំណុំរឿងនៃអំពើហឹង្សាទៅលើកុមារស្ថិតក្រោមច្បាប់ក្នុងស្រុក ត្រូវជូនដំណឹងដល់កុមារ និងអ្នកផ្តល់ការថែទាំព្យាបាលភ្លាមៗ។

***មិនមានការរើសអើង៖*** ជនរងគ្រោះទាំងអស់មានសិទ្ធិស្មើគ្នា និងទទួលបានការព្យាបាលដូចគ្នា និងមានសិទ្ធិស្មើគ្នាក្នុងទទួលសេវាថែទាំសុខភាព។ មិនត្រូវមានការរើសអើង ឬការព្យាបាលខុសគ្នាសម្រាប់កុមាររងគ្រោះដោយសារអំពើហឹង្សាដោយអាស្រ័យលើ ភេទ ពូជសាសន៍ សាសនា ពិការភាព ឋានៈ ឬកត្តាផ្សេងទៀតឡើយ។
***ការយល់ព្រម៖*** ត្រូវទទួលបានការយល់ព្រមសម្រាប់ទម្រង់ការ និងសេវាថែទាំសុខភាពជាក់លាក់។ ជម្រើសនានាសម្រាប់ការយល់ព្រមនឹងត្រូវពន្យល់ទៅកាន់ឪពុកម្តាយ ឬអាណាព្យាបាលដែលមិនប្រព្រឹត្តអំពើរំលោភបំពាន និងកុមាររងគ្រោះដោយសារអំពើហឹង្សាដោយអាស្រ័យលើអាយុ និងកម្រិតភាពចាស់ទុំ (សូមអានអំពីការយល់ព្រម និងការពិនិត្យប្រវត្តិជំងឺ)។ ការសម្រេចចិត្តរបស់ឪពុកម្តាយ ឬអាណាព្យាបាលដែលមិនប្រព្រឹត្តអំពើរំលោភបំពានដើម្បីយល់ព្រមចំពោះចំណុច ក ខ ឬ គ នឹងត្រូវបានគោរព។
ឃ)មានតែការពិនិត្យ និងការព្យាបាលរាងកាយប៉ុណ្ណោះ
ង) ការពិនិត្យរាងកាយ ការព្យាបាល និងការពិនិត្យកោសល្យវិច័យ។
ច) ការពិនិត្យរាងកាយ ការព្យាបាល និងការពិនិត្យកោសល្យវិច័យ ការអង្កេតរបស់ប៉ូលិស និងយុត្តិធម៌ផ្នែកច្បាប់

## ៣.២ សមាហរណកម្មសេវាថែទាំកុមាររងគ្រោះដោយអំពើហឹង្សាក្នុងសេវាថែទាំសុខភាពដែលមានស្រាប់

ការគ្រប់គ្រងដ៏គ្រប់ជ្រុងជ្រោយចំពោះកុមាររងគ្រោះដោយសារអំពើហឹង្សានៅប្រព័ន្ធសុខាភិបាលផ្សេងៗគ្នា ត្រូវមានស្តង់ដារអប្បបរមាសម្រាប់តម្រូវការបុគ្គលិកកន្លែងថែទាំព្យាបាលសុខភាព សម្ភារ ឧបករណ៍ ថ្នាំពេទ្យ សម្ភារវេជ្ជសាស្ត្រ និងសម្ភាររដ្ឋបាល។

### ៣.២.១ ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលជាតិ

**ក្រសួងសុខាភិបាល** ទទួលខុសត្រូវចំពោះគោលនយោបាយ និងការរៀបចំផែនការសុខភាព ទោះបីជាមានការជួយសម្រួលដល់ការសម្របសម្រួលពីពហុវិស័យ និងជំនួយពីខាងក្រៅក៏ដោយ។ **មន្ទីរសុខាភិបាល**មានភារកិច្ចភ្ជាប់ទំនាក់ទំនងក្រសួងសុខាភិបាលទៅនឹងស្រុកប្រតិបត្តិតាមរយៈការអនុវត្តគោលនយោបាយនៅក្នុងផែនការនៃវិស័យសុខាភិបាលតាមផែនការប្រតិបត្តិប្រចាំឆ្នាំ។ ***ស្រុកប្រតិបត្តិ*** អាស្រ័យទៅលើចំនួនប្រជាជន ហើយគ្របដណ្តប់ប្រជាពលជនចំនួន ១០០.០០០ ដល់ ២០០.០០០ នាក់ និងប្រមូលផ្តុំមន្ទីរពេទ្យបង្អែក និងបណ្តាញមណ្ឌលសុខភាព។ ស្រុកប្រតិបត្តិមានតួនាទីសម្របសម្រួលនិងគ្រប់គ្រងរវាងមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកក្នុងការផ្តល់សេវាថែទាំសុខភាពរបស់ពួកគេ ។ ***មណ្ឌលសុខភាព***ត្រូវបានកំណត់ទីតាំងដើម្បីបម្រើតំបន់ដែលមានប្រជាពលជនចំនួនពី ៨.០០០ ទៅ ១២.០០០ នាក់។ សេវាកម្មទាំងនេះរួមមានការពិគ្រោះជំងឺជំហានដំបូង និងរោគវិនិច្ឆ័យបឋម ការផ្តល់ជំនួយសង្គ្រោះបឋម ការថែទាំជំងឺរ៉ាំរ៉ៃ ការថែទាំសុខភាពមាតានិងទារក (រួមទាំងការសម្រាលកូនធម្មតា) សេវាពន្យារកំណើត ការចាក់ថ្នាំបង្ការ ការអប់រំសុខភាព និងការបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែក។ ***មន្ទីរពេទ្យ***ត្រូវបាន

កំណត់ឱ្យស្ថិតនៅកម្រិតថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ។ មន្ទីរពេទ្យបង្អែកត្រូវបានរំពឹងទុកថាជួយគាំទ្រដល់ការថែទាំបឋមហើយមានធនធាននិងអ្នកជំនាញដែលអាចជួយដល់មណ្ឌលសុខភាពនានា។ នៅមន្ទីរពេទ្យបង្អែកមានសំណុំ សកម្មភាពបង្គ្រប់ចំនួន ៣ កំរិតCPA1, CPA2 និង CPA3 ។ CPA 1 នៃមន្ទីរពេទ្យបង្អែកមិនមានការវះកាត់ខ្នាតធំទេ ប៉ុន្តែមានសេវាផ្នែកសម្ភពមូលដ្ឋាន CPA2 មានសេវាសង្គ្រោះបន្ទាន់ និងការវះកាត់ធំ និង CPA3 មានសេវា CPA 1 និង CPA 2 ទាំងអស់ ហើយមានសេវាឯកទេស ដូចជាធនាគារឈាម សេវាព្យាបាលត្រចៀក ច្រមុះ និងបំពង់ក និងសេវាថែទាំសុខភាពផ្សេងៗទៀត។

### ៣.២.២ កន្លែងសំខាន់សម្រាប់កុមាររងគ្រោះដោយសារអំពើហឹង្សា

កន្លែងសំខាន់សម្រាប់កុមាររងគ្រោះនៅក្នុងប្រព័ន្ធសុខាភិបាលមានដូចជា៖

- ផ្នែកសង្គ្រោះបន្ទាន់
- សេវាថែទាំមុនពេលសម្រាល ការថែទាំសុខភាពពេលសម្រាល និងការថែទាំសុខភាពក្រោយពេលសម្រាល
- សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងការថែទាំទារកទើបនឹងកើត
- សេវាកម្មចាក់ថ្នាំបង្ការដល់កុមារ
- កម្មវិធីអាហារូបត្ថម្ភកុមារ
- ការរក្សាការសម្ងាត់ ការប្រឹក្សាយោបល់ និងការធ្វើតេស្តដោយស្ម័គ្រចិត្ត
- ការបង្ការការឆ្លងជំងឺមេរោគអេសដ៍ពីម្តាយទៅកូន

## ៣.៣ ស្តង់ដារអប្បបរមាសម្រាប់ការគ្រប់គ្រងកុមាររងគ្រោះដោយសារអំពើហឹង្សា

### ៣.៣.១ កញ្ចប់សេវាថែទាំសុខភាពអប្បបរមា

កញ្ចប់សេវាថែទាំសុខភាពអប្បបរមាដែលមានកន្លែងព្យាបាលសុខភាពគួរផ្តល់នូវ៖

- កន្លែងទទួលភ្ញៀវ និងការគាំទ្រដំបូង
- ធានារក្សាការសម្ងាត់ និងទទួលបានការយល់ព្រមដោយមានការផ្តល់ព័ត៌មានជាមុនសម្រាប់ទម្រង់ការព្យាបាល និងការធ្វើកោសល្យវិច័យដែលបានជ្រើសរើស។
- ការគ្រប់គ្រងការព្យាបាលភ្លាមៗ (ការពិនិត្យប្រវត្តិជំងឺ ការពិនិត្យរាងកាយ) ការព្យាបាលរបួសទាំងអស់ដែលកន្លែងព្យាបាលសុខភាពមានលទ្ធភាពព្យាបាល
- ការផ្តល់ឬការបញ្ជូនភ្លាមៗសម្រាប់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍(វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ក្នុងរយៈពេល ៧២ ម៉ោង) (ករណីអំពើហឹង្សាលើផ្លូវភេទ)
- ការផ្តល់ ឬការបញ្ជូនភ្លាមៗសម្រាប់ការពិនិត្យ និងការព្យាបាលជំងឺកាមរោគ (ករណីអំពើហឹង្សាលើផ្លូវភេទ)
- ការផ្តល់ ឬការបញ្ជូនភ្លាមៗសម្រាប់ការការពារកំណើតបន្ទាន់ (ករណីអំពើហឹង្សាលើផ្លូវភេទ)
- ការផ្តល់ ឬការបញ្ជូនភ្លាមៗសម្រាប់ការពិនិត្យកោសល្យវិច័យ (អាស្រ័យលើការយល់ព្រមពីជនរងគ្រោះ និងពីឪពុកម្តាយ ឬអាណាព្យាបាលដែលមិនប្រព្រឹត្តអំពើរំលោភបំពាន)
- ការបញ្ជូនជនរងគ្រោះទៅកន្លែងព្យាបាលសុខភាពកម្រិតខ្ពស់សម្រាប់ការព្យាបាលបន្ថែម និង

- ការបញ្ជូនទៅសេវាផ្សេងៗដែលមានស្រាប់សម្រាប់កុមាររងគ្រោះ ដូចជាការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម មណ្ឌលស្នាក់នៅដែលមានសុវត្ថិភាពជំនួយផ្នែកច្បាប់ ការថែទាំក្រោយពេលរងគ្រោះ ឬការស្តារនីតិសម្បទា សមាហរណកម្ម និងសេវាកម្មផ្សេងៗទៀត។

### ៣.៣.៣.១ ការឆ្លើយតបអាចរកបាននៅកម្រិតនៃអ្នកផ្តល់ការថែទាំសុខភាពខុសៗគ្នា

| ការឆ្លើយតប | មណ្ឌលសុខភាព | មន្ទីរពេទ្យបង្អែក CPA1 | មន្ទីរពេទ្យបង្អែក CPA2 | មន្ទីរពេទ្យជាតិ និងខេត្តCPA3 |
|---|---|---|---|---|
| ទទួលយក និងជ្រើសរើសការថែទាំសមស្រប | √ | √ | √ | √ |
| ផ្តល់ការគាំទ្រជួរមុខដែលធានានូវការរក្សាការសម្ងាត់ | √ | √ | √ | √ |
| ពិនិត្យប្រវត្តិជំងឺ ទទួលបានការយល់ព្រម និងធ្វើការពិនិត្យដោយប្រើប្រាស់បែបបទនានា | | √ | √ | √ |
| គ្រប់គ្រងរបួសស្រាល | √ | √ | √ | √ |
| គ្រប់គ្រងរបួសធ្ងន់ធ្ងរ | | | √ | √ |
| ការផ្តល់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ | | | | √ |
| ផ្តល់ការការពារកំណើតបន្ទាន់ | √ | √ | √ | √ |
| ផ្តល់វ៉ាក់សាំងតេតាណូសតុកសូអ៊ីត | √ | √ | √ | √ |
| ព្យាបាលជំងឺកាមរោគ | √ | √ | √ | √ |
| *សេវាកម្មចិត្តសាស្ត្រសង្គម* | | | | |
| បង្កើតទំនាក់ទំនងអន្តរបុគ្គលយ៉ាងល្អជាមួយជនរងគ្រោះ | √ | √ | √ | √ |
| ភ្ជាប់ជនរងគ្រោះជាមួយសេវាថែទាំសុខភាពនៃអំពើហិង្សាទៅលើកុមារផ្សេងទៀត | √ | √ | √ | √ |
| តាមដាន | √ | √ | √ | √ |
| *សេវាកោសល្យវិច័យ* | | | | |
| ប្រមូល និងចងក្រងជាឯកសារនូវលទ្ធផលបានមកពីការត្រួតពិនិត្យធ្វើកោសល្យវិច័យ | | √ | √ | √ |
| ចងក្រងជាឯកសារនូវលទ្ធផលទាក់ទងនឹងប្រវត្តិកោសល្យវិច័យ និងការពិនិត្យរាងកាយ | | √ | √ | √ |
| បំពេញបែបបទវេជ្ជសាស្ត្រកោសល្យវិច័យ | | √ | √ | √ |
| *ការបញ្ជូន និងចំណងទាក់ទង* | | | | |
| បញ្ជូនជនរងគ្រោះធ្ងន់ធ្ងរទៅកន្លែងព្យាបាលសុខភាពកម្រិតខ្ពស់ | √ | √ | √ | √ |
| អបរំ តម្រង់ទិស និងផ្តល់ព័ត៌មានអំពីសេវាថែទាំសុខភាពនៃអំពើហិង្សាទៅលើកុមារ | √ | √ | √ | √ |

## ៣.៣.២ សម្ភារវេជ្ជសាស្ត្រ និងរដ្ឋបាលអប្បបរមាតាមកម្រិតសមត្ថភាពរបស់អ្នកផ្តល់ការថែទាំ

| មណ្ឌលសុខភាព | មន្ទីរពេទ្យបង្អែក |
|---|---|
| *សម្ភារវេជ្ជសាស្ត្រ និងថ្នាំពេទ្យ* | |
| -សម្ភារ និងបរិក្ខារសម្រាប់ការបង្ការ និងការគ្រប់គ្រងការឆ្លងជំងឺ<br>-ចេសបានសម្លាប់មេរោគរួច និងថាសដាក់បង់រុំ<br>-សម្ភារអនាម័យ<br>-កញ្ចប់តេស្តរកការមានផ្ទៃពោះ | សម្ភារបន្ថែមនៅមណ្ឌលសុខភាព<br>-វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍(PEP) (CPA 3)<br><br>សម្រាប់ការពិនិត្យកោសល្យវិច័យ |

| | |
|---|---|
| -កញ្ចប់តេស្តរកជំងឺស្វាយ<br>-តេតាណូសតុកសូអ៊ីត<br>-ថ្នាំស្ពឹក<br>-ថ្នាំស្ពឹកសម្រាប់ដេររបួស<br>-ថ្នាំអង់ទីប៊ីយ៉ូទីក<br>-ការការពារកំណើតបន្ទាន់<br>-ការព្យាបាលជំងឺកាមរោគ | *កញ្ចប់ពិនិត្យកោសល្យវិច័យរួមមាន៖*<br>-សឺរាំងចាក់ថ្នាំ<br>-ឧបករណ៍បើកមាត់ស្បូន<br>-ដបទទេដែលបានសម្លាប់មេរោគរួច<br>-សម្ភារកៀរសម្អាតស្បូន<br>-ថង់ក្រដាសសម្រាប់ដាក់ក្រណាត់<br>-ម៉ាស៊ីនថតឌីជីថល (បើមាន)<br>-ប្រេងរំអិល<br>-ក្រណាត់ ក្រដាស់អនាម័យ ឬសម្ភារជំនួយបន្ថែមផ្សេងទៀត<br>-សម្ភារដែលលេងជាមួយកុមារ រួមមានតុក្កតា ប្រដាប់ក្មេងលេង ក្រដាស និងខ្មៅដៃផាត់ពណ៌ |
| **សម្ភាររដ្ឋបាល** | |
| បែបបទយល់ព្រម<br>បែបបទព្យាបាលស្ត្រីនិងកុមាររងគ្រោះដោយសារអំពើហឹង្សា<br>ឯកសារនិងព័ត៌មានបញ្ជូនជនរងគ្រោះ | បែបបទយល់ព្រម<br>បែបបទព្យាបាលស្ត្រីនិងកុមាររងគ្រោះ<br>ឯកសារនិងព័ត៌មានបញ្ជូនជនរងគ្រោះ<br>បំពេញបែបបទវេជ្ជសាស្ត្រកោសល្យវិច័យ |

### ៣.៣.៣ ការបណ្តុះបណ្តាលអប្បបរមាសម្រាប់បុគ្គលិកសុខាភិបាល

កន្លែងព្យាបាលសុខភាពគួរតែផ្តល់កញ្ចប់សេវាថែទាំសុខភាពអប្បបរមាសម្រាប់កុមាររងគ្រោះដោយសារអំពើហឹង្សា ។ ដើម្បីផ្តល់កញ្ចប់សេវាថែទាំសុខភាពអប្បបរមា អ្នកផ្តល់ការថែទាំសុខភាពគួរតែទទួលបានការបណ្តុះបណ្តាលជំនាញខាងក្រោម៖

- ច្បាប់ដែលពាក់ព័ន្ធនឹងអំពើហឹង្សាទៅលើកុមារ
- ថាមវន្ត(Dynamic)នៃអំពើហឹង្សាទៅលើកុមារ និងបញ្ហាប្រឈមជាមួយនឹងការបញ្ចេញព័ត៌មាន
- សញ្ញា និងរោគសញ្ញានៃអំពើហឹង្សា
- ការចូលរួមជាមួយជនរងគ្រោះ និងការផ្តល់ការគាំទ្រដំបូង
- ការប្រើប្រាស់វិធីព្យាបាល រួមមានការផ្តល់វិធីបង្ការក្រោយពេលប្រឈមនឹងការឆ្លងមេរោគអេដស៍ ការការពារកំណើតបន្ទាន់និងសេវាថែទាំសុខភាពតាមការចាំបាច់
- ការយល់ដឹង និងការពិនិត្យកោសល្យវិច័យ និងតម្រូវការឯកសារផ្នែកច្បាប់ (នៅកម្រិតមន្ទីរពេទ្យបង្អែក)
- ការយល់ដឹង និងការបញ្ជូនទៅធនធានសហគមន៍
- ការប្រើប្រាស់វិធីសាស្ត្រកុមារមេត្រី
- ប្រធានបទផ្សេងៗដែលត្រឹមត្រូវ។

***ការធ្វើបទសម្ភាសជាមួយមនុស្សពេញវ័យ*** ប្រសិនបើអ្នកសង្ស័យបុគ្គលដែលបាននាំកុមារទៅមន្ទីរព្យាបាលសុខភាពគឺជាជនរំលោភបំពាន មិនត្រូវអនុញ្ញាតឲ្យបុគ្គលនោះចូលរួមក្នុងការសម្ភាសន៍ និងការពិនិត្យឡើយ។

## ៣.៤ គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងកុមាររងគ្រោះដោយសារអំពើហឹង្សាស្ត្រី និងកុមារ

### ៣.៤.១ ការកំណត់អត្តសញ្ញាណនៃអំពើហឹង្សាទៅលើកុមារ

- កុមាររងគ្រោះ ជួនកាលត្រូវបានកំណត់អត្តសញ្ញាណតាមរយៈការបង្ហាញការស្មុគ្រស្មាញចិត្តពីកុមារ តាមរយៈរបាយការណ៍ពីភាគីទីបីដែលធ្វើសាក្សី ឬសង្ស័យលើការរំលោភបំពាន។ មិនមានច្បាប់ដែលមានលក្ខណៈ

ជាសាកលស្តីពីការរាយការណ៍អំពីករណីហឹង្សាទៅលើកុមារឡើយ ទោះជាយ៉ាងណា ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យរាយការណ៍អំពីបទល្មើសទៅអាជ្ញាធរពាក់ព័ន្ធ។

- ករណីភាគច្រើន ការអនុញ្ញាតឱ្យចូលសម្រាកនៅមន្ទីរពេទ្យត្រូវបានណែនាំសម្រាប់ពេលសមស្រប ដោយអាស្រ័យលើស្ថានភាពជនរងគ្រោះ ដើម្បីធ្វើការវាយតម្លៃសុខភាពលម្អិត និងរៀបចំកន្លែង បើចាំបាច់។
- កុមាររងគ្រោះគួរត្រូវបានវាយតម្លៃក្នុងបន្ទប់ដាច់ដោយឡែកពីគ្នានៅក្នុងបរិយាកាសស្ងប់ស្ងាត់ស្និទ្ធស្នាលជាមួយកុមារ។
- ការចូលរួមពីសំណាក់បុគ្គលិកសង្គមកិច្ចនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា និងនគរបាលគឺមានសារៈសំខាន់ណាស់ក្នុងពេលកុមារកំពុងស្ថិតនៅមណ្ឌលស្នាក់នៅមានសុវត្ថិភាព។

កុមាររងគ្រោះខ្លះ អាចមិនមានរបួសរាងកាយ ឬសញ្ញានៃការប៉ះទង្គិច។ កុមារដទៃទៀតអាចមានរោគសញ្ញាផ្នែកអារម្មណ៍ និងឥរិយាបថដែលបានកត់សម្គាល់ដំបូងដោយគ្រូបង្រៀន សាច់ញាតិ ឬមាតាបិតា។ កត្តាដ៏សំខាន់បំផុតសម្រាប់កំណត់ការរំលោភបំពានគឺអ្នកប្រាប់ដំណើររឿងនៃឧបទ្ទវហេតុរបស់កុមារ (ឬសាក្សី)

***អ្នកអាចសង្ស័យកុមារដែលធ្លាប់ទទួលរងអំពើហឹង្សា ប្រសិនបើគាត់មានលក្ខណៈដូចខាងក្រោម៖***

| ប្រភេទនៃអំពើហឹង្សា | សញ្ញាលើរាងកាយ | សញ្ញាផ្នែកឥរិយាបថ |
|---|---|---|
| ***អំពើហឹង្សាលើរាងកាយ***រួមមានទម្រង់ជាច្រើន ដូចជាការក្តិច ការច្រាន ការទាត់ ការបង្ខំ ការធ្វើសកម្មភាពពិន័យលើរាងកាយកុមារ (ការងារពិបាក ការលុតជង្គង់ "លំហាត់") ការវាយដោយដៃ ឬប្រើវត្ថុដូចជាឈើច្រត់ ឬរំពាត់ ធ្វើឱ្យរលាក ឬគំរាមកំហែងដោយប្រើអាវុធ។ | - ស្នាមជាំ មុត រលាក ឬបាក់ឆ្អឹងដែលមិនអាចពន្យល់បាន<br>- ការព្យាបាលរបួសយឺតយ៉ាវ | - មិនចូលផ្ទះ<br>- ការពន្យល់ពីរបួសមិនត្រឹមត្រូវ<br>- ការប្រុងប្រយ័ត្នចំពោះទំនាក់ទំនងរបស់មនុស្សពេញវ័យ |
| ***អំពើហឹង្សាលើផ្លូវភេទ***មានចាប់ពីការរំលោភ ការប៉ះដោយអចេតនា ការព្យាយាមមានទំនាក់ទំនងផ្លូវភេទ និងការរំលោភបំពានដែលមិនប៉ះពាល់ផ្លូវភេទ រួមមានការគំរាមកំហែង ការលួងលោម និងការប្រើល្បិចដើម្បីមានទំនាក់ទំនងផ្លូវភេទ ការបៀតបៀនកេរ្តិ៍ខ្មាស់ ការយាយីដោយពាក្យសំដី។ អំពើហឹង្សាខាងផ្លូវភេទទៅលើកុមារក៏ពាក់ព័ន្ធនឹងការបង្ខំឱ្យចូលទៅក្នុងសកម្មភាពកេងប្រវ័ញ្ច ជាពិសេសពេស្យាចារ និងការថតរូបអាសអាភាសផងដែរ។ ការបង្ខិតបង្ខំ ដូចជាកុមារទទួលអំណោយ ឬផលប្រយោជន៍ជាការដោះដូរជាមួយនឹងសកម្មភាពរួមភេទ។ | - របួសនៅលើប្រដាប់បន្តពូជដែលមិនអាចពន្យល់បាន<br>- ការធ្លាក់សតាមយោនី ឬតាមលិង្គ<br>- ពិបាកដើរ ឬអង្គុយ<br>- ការឈឺចាប់ពេលបត់ជើងតូច<br>- ការរលាកផ្លូវទឹកនោម<br>- ការត្អូញត្អែរពាក់ព័ន្ធនឹងរន្ធគូទ ដូចជាឈឺចាប់ ការហូរឈាម<br>- ការមានទឹកកាម<br>- ការមានផ្ទៃពោះ | - អាកប្បកិរិយាវិលត្រឡប់មកដូចដើមវិញ<br>- បញ្ហានៅក្នុងសាលារៀន<br>- ឥរិយាបទរួមភេទមិនសមរម្យ<br>- ការសម្តែងអាកប្បកិរិយាចេញមកក្រៅ<br>- ការប្រើប្រាស់គ្រឿងញៀន<br>- ការប៉ុនប៉ងសម្លាប់ខ្លួន<br>- ការគំរាមកំហែងតាមរយៈការប៉ះពាល់រាងកាយ<br>- ការបាក់ទឹកចិត្ត<br>- ការឱ្យតម្លៃតិចតួចលើខ្លួនឯង |
| ***អំពើហឹង្សា***ឬការរំលោភបំពានលើផ្លូវចិត្តជាឥរិយាបទណាមួយដែលត្រូវបានរៀបចំដើម្បីគ្រប់គ្រង និងបង្ក្រាបបុគ្គលមួយផ្សេងទៀតតាមរយៈការបំភ័យ ការធ្វើឱ្យអាប់កិត្តិយស ឬការបំពានលើរាងកាយ។ វាអាចរួមបញ្ចូលអំពើណាមួយមកពីការរំលោភបំពានដោយពាក្យសម្តី និងការរិះគន់ជាប្រចាំ ឬការបំភិតបំភ័យ ការបញ្ជា | - កម្រ | - អាកប្បកិរិយាលួងលោមខ្លួនឯង ដូចជា លេបទឹកមាត់ ការយោលជើង ឬការខាំមាត់<br>- អាកប្បកិរិយាធ្វើឱ្យរបួសខ្លួនឯងដូចជាការធ្វើឱ្យមុតឬដាច់រលាត់<br>- អាកប្បកិរិយាប្រឆាំងសង្គម និងបំផ្លិចបំផ្លាញ<br>- ការសេពគ្រឿងញៀន |

| | | |
|---|---|---|
| | | - ការអភិវឌ្ឍន៍យឺតយ៉ាវ |
| ***ការមិនយកចិត្តទុកដាក់***គឺអសមត្ថភាពក្នុងការផ្តល់តម្រូវការមូលដ្ឋានរបស់កូន។ ការមិនយកចិត្តទុកដាក់អាចជាចេតនា ឬមកពីការកង្វះធនធានក្នុងការព្យាបាលកុមារ។ | - តែងតែឃ្លាន<br>- ស្លៀកពាក់មិនសមរម្យ<br>- អនាម័យមិនល្អ<br>- ការមិនបំពេញតាមតម្រូវការវេជ្ជសាស្ត្រ ឬអប់រំ<br>- ការលូតលាស់រាងកាយយឺតយ៉ាវ | - អស់កម្លាំង ឬងងុយគេងជាប្រចាំ<br>- សុំទាន ឬលួចម្ហូបអាហារ ឬវត្ថុផ្សេងៗ ដូចជាសម្លៀកបំពាក់<br>- គេចសាលាជាញឹកញាប់<br>- តម្រូវការខ្លាំងនូវសេចក្តីស្រលាញ់<br>- ការអភិវឌ្ឍន៍យឺតយ៉ាវ |

### ៣.៤.២ ការទទួលកុមាររងគ្រោះដោយសារអំពើហឹង្សា

នៅពេលកុមារបង្ហាញពីការទទួលរងនូវអំពើហឹង្សា ពួកគេជាញឹកញាប់មានការព្រួយបារម្ភកាន់តែខ្លាំងអំពីប្រតិកម្មតបរបស់បុគ្គលដែលពួកគេកំពុងបង្ហាញច្រើនជាងរបួសរាងកាយរបស់ពួកគេ។ អ្នកផ្តល់ការថែទាំសុខភាពត្រូវផ្តល់សេវាថែទាំសុខភាពដោយសេចក្តីមេត្តា និងគាំទ្រ ព្រមទាំងបង្ហាញការបារម្ភអំពីសុខុមាលភាព និងសុវត្ថិភាពរបស់កុមារ។ ការឆ្លើយតបលើកដំបូងចំពោះកុមារដែលបង្ហាញការរំលោភបំពានជាញឹកញាប់អាចមានភាពខុសគ្នាខ្លាំង។ **បញ្ជូនអ្នកជម្ងឺរបួសធ្ងន់ធ្ងរដល់ជីវិត ឬមានស្ថានភាពធ្ងន់ធ្ងរផ្សេងទៀតទៅទទួលការព្យាបាលជាបន្ទាន់។**

### ៣.៤.៣ ការផ្តល់ការគាំទ្រដំបូងដល់កុមារ

ការគាំទ្រដំបូងសម្រាប់កុមារពាក់ព័ន្ធនឹងកិច្ចការធម្មតាមួយចំនួន៖ *ស្តាប់ ជឿជាក់ សួរសំណួរអំពីតម្រូវការ និងការព្រួយបារម្ភ ពង្រឹងសុវត្ថិភាព ធានារក្សាការសម្ងាត់ និងគាំទ្រ*[20] ។ នេះជាការថែទាំសំខាន់បំផុតដែលអ្នកអាចផ្តល់។ ទោះបីនេះជាអ្វីដែលអ្នកអាចធ្វើ អ្នកបានជួយអ្នកជំងឺយ៉ាងច្រើន។ ការគាំទ្រដំបូងជួយប្រជាពលជនដែលធ្លាប់ឆ្លងកាត់ទុក្ខលំបាក ភាពក្រៀមក្រំ ឬតប់ប្រមល់ រួមមានកុមារដែលទទួលនូវអំពើហឹង្សា។ ចងចាំថាអ្នកមិនមែនទទួលខុសត្រូវចំពោះការដោះស្រាយបញ្ហារបស់ជនរងគ្រោះ និងភាពឯកជននិងការរក្សាការសម្ងាត់របស់កុមារ គួរត្រូវបានគោរពគ្រប់ពេល។

| | |
|---|---|
| **ស្តាប់** | **ស្តាប់កុមារឱ្យជិត ដោយមានក្តីមេត្តា និងមិនវិនិច្ឆ័យ**អនុញ្ញាតឱ្យកុមារសម្តែងមតិរបស់ពួកគេផ្ទាល់នៅពេលវេលាល្អសម្រាប់ពួកគេ |
| **ជឿជាក់** | **ធ្វើឱ្យកុមារជឿទុកចិត្តថា អ្នកជឿជាក់ និងយកចិត្តទុកដាក់ពួកគេយ៉ាងពិតប្រាកដ។** ប្រាប់កុមារថាពួកគេនឹងមិនទទួលការស្តីបន្ទោសទេ។ លើកទឹកចិត្ត និងគាំទ្រដោយប្រើប្រាស់អំណះអំណាងដូចជា៖ "អ្នកក្លាហានណាស់ក្នុងការនិយាយអំពីរឿងនេះ" "ខ្ញុំរីករាយណាស់ដែលអ្នកប្រាប់ខ្ញុំអំពីរឿងនេះ" "ខ្ញុំសោកស្តាយដែលរឿងនេះកើតឡើងចំពោះរូបអ្នក" "ខ្ញុំនឹងធ្វើអ្វីៗទាំងអស់ដើម្បីជួយអ្នក" |
| **សាកសួរអំពីតម្រូវការ និង** | វាយតម្លៃ និងឆ្លើយតបចំពោះតម្រូវការ និងការព្រួយបារម្ភ អារម្មណ៍ រាងកាយ សង្គម និងការអនុវត្តផ្សេងៗ* |

[20]ដកស្រង់ដោយ UNICEF ពីគោលការណ៍ណែនាំស្តីពីជំហានដំបូង និងគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក

| | |
|---|---|
| **ការព្រួយបារម្ភផ្សេងៗ** | |
| **ពង្រឹងសុវត្ថិភាព** | ប្រសិនបើមានហានិភ័យភ្លាមៗចំពោះសុវត្ថិភាព សាកសួរកុមារតើពួកគេត្រូវការអ្វីដើម្បីឱ្យពួកគេមានអារម្មណ៍សុវត្ថិភាព។ |
| **ធានារក្សាការសម្ងាត់** | គោរពសិទ្ធិរបស់កុមារចំពោះការសម្ងាត់ ហើយមិនប្រាប់អ្នកដទៃដែលមិនចាំបាច់ដឹងនោះទេ។ សន្យាតែអ្វីដែលអ្នកអាចធ្វើបានប៉ុណ្ណោះ។ ឧទាហរណ៍ ហាមយល់ព្រមចំពោះការរក្សាអាថ៌កំបាំងដែលកុមារបានប្រាប់។ ករណីបែបនេះ ពន្យល់ថាអាថ៌កំបាំងមួយចំនួនគួរត្រូវបានចែករំលែកដើម្បីទទួលបានជំនួយ ឬដើម្បីរក្សាឱ្យមនុស្សរួចពីការឈឺចាប់។ ប្រាប់កុមារពីព័ត៌មានដែលត្រូវចែករំលែកទៅកាន់មនុស្សដែលចង់ជួយនិងការពារប៉ុណ្ណោះ។ |
| **ការគាំទ្រ** | លើកទឹកចិត្តកុមារឱ្យទទួលការគាំទ្រពីអ្នកដែលអាចជួយបាន។ គាំទ្រកុមារដោយជួយភ្ជាប់ពួកគេទៅនឹងសេវាថែទាំសុខភាព និងសេវាគាំទ្រសង្គម។ |

## ៣.៤.៤ ការយល់ព្រម និងការពិនិត្យប្រវត្តិ

### ៣.៤.៤.១ ការពិចារណាទូទៅ

គួរខំប្រឹងប្រែងដើម្បីកាត់បន្ថយចំនួនម៉ោងនៃការសម្ភាសកុមារ។ ប្រសិនបើមណ្ឌលផ្តល់សេវាសុខភាពមានបុគ្គលិកសង្គមកិច្ច ពួកគេគួរតែមានវត្តមានអំឡុងពេលសម្ភាស។

- ណែនាំខ្លួនអ្នកទៅកាន់ជនរងគ្រោះ។
- សម្រាប់មនុស្សពេញវ័យ សួរពួកគេ ប្រសិនបើពួកគេចង់នៅម្នាក់ឯង ឬនៅជាមួយមនុស្សដែលជឿទុកចិត្ត។ សួរថាតើកុមាររងគ្រោះចង់ឱ្យមានមនុស្សគាំទ្រជាក់លាក់ដែរឬទេ។
- កំណត់ចំនួនមនុស្សដែលបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់អំឡុងពេលពិនិត្យ ប្រសិនបើមានវត្តមានអ្នកដទៃនៅពន្យល់ពីតួនាទីរបស់ពួកគេ ហើយសុំការអនុញ្ញាតពីកុមាររងគ្រោះ។
- ពន្យល់ជាភាសាដែលកុមាររងគ្រោះអាចយល់ថា ពួកគេស្ថិតក្នុងកន្លែងដែលមានការគ្រប់គ្រង ពេលវេលា និងសមាសភាពនៃការពិនិត្យ។
- លើកទឹកចិត្តជនរងគ្រោះថា លទ្ធផលនៃការពិនិត្យនឹងត្រូវបានរក្សាការសម្ងាត់ (ឬតើមានអ្វីកើតឡើងចំពោះលទ្ធផលទាំងនេះ)។
- ពន្យល់ថា តើនឹងមានអ្វីកើតឡើងអំឡុងពេលពិនិត្យនៃដំណាក់កាលនីមួយៗ ហេតុអ្វីបានជាមានសារសំខាន់ តើអ្វីដែលវាគួរប្រាប់អ្នក និងរបៀបដែលវាមានឥទ្ធិពលលើការថែទាំដែលអ្នកបានផ្តល់ឱ្យ។
- ជនរងគ្រោះ/អាណាព្យាបាល/មាតាបិតាចុះហត្ថលេខាលើបែបបទយល់ព្រម។
- បន្ទាប់ពីបែបបទយល់ព្រមបានចុះហត្ថលេខារួច សូមពិនិត្យភ្លាមៗតាមដែលអាចធ្វើបាន។
- ហាមបង្ខំកុមារឱ្យធ្វើអ្វីដែលផ្ទុយនឹងឆន្ទៈរបស់ពួកគេ។
- រក្សាអត្តសញ្ញាណខ្លួនអ្នកដែលជាអ្នកជួយ។

### ៣.៤.៤.២ បែបបទយល់ព្រមសម្រាប់កុមារ

ផ្តល់អាទិភាពក្នុងការពិនិត្យរាងកាយកុមារ អ្នកថែទាំសុខភាពត្រូវពន្យល់ទៅកុមារ (និងមាតាបិតាកុមារ) អំពីដំណើរការនៃការថែទាំ និងការព្យាបាល រួមមានការសម្ភាសនិងពិនិត្យព្យាបាល។ ការយល់ព្រមសម្រាប់ផ្នែកនីមួយៗនៃការថែទាំសុខភាព និងការព្យាបាលគួរត្រូវបានទទួលគ្រប់ដំណាក់កាល។ សម្រាប់កុមាររងគ្រោះ បែបបទយល់ព្រមត្រូវចុះហត្ថលេខាដោយមាតាបិតា ឬអ្នកថែទាំរបស់កុមារ លុះត្រាតែមាតាបិតារបស់កុមារគឺជាជនរំលោភបំពានដែលបានសង្ស័យ។ បើមាតាបិតាគឺជាជនរំលោភបំពានដែលមានការសង្ស័យ បែបបទយល់ព្រមត្រូវចុះហត្ថលេខាដោយតំណាងមកពីកន្លែងព្យាបាលសុខភាព។

ទិដ្ឋភាពដ៏សំខាន់បំផុតនៅក្នុងការយល់ព្រមគឺថា ទោះបីជាកុមារមិនអាចផ្តល់ការយល់ព្រមចំពោះការពិនិត្យ និងសេវាថែទាំសុខភាពក៏ដោយ ក៏ពួកគេមិនត្រូវជំរុញ ឬបង្ខំឱ្យទទួលយកការពិនិត្យ ឬព្យាបាលឡើយ លើកលែងតែវាចាំបាច់ក្នុងការសង្គ្រោះជីវិតរបស់កុមារតែប៉ុណ្ណោះ។

- កុមារមានអាយុ ១៦ ឆ្នាំ ឬអាយុច្រើនជាងនេះ ជាទូទៅគឺមានភាពចាស់ទុំគ្រប់គ្រាន់ល្មមក្នុងការផ្តល់គំនិតសំខាន់ៗក្នុងការសម្រេចចិត្ត។
- កុមារដែលមានអាយុចន្លោះពី ១៤ ឆ្នាំ និង ១៦ ឆ្នាំអាចចាត់ទុកថាមានលក្ខណៈចាស់ទុំគ្រប់គ្រាន់ក្នុងការចូលរួមចំណែកតាមរយៈការចែករំលែកទស្សនៈរបស់ពួកគេទាក់ទងនឹងការសម្រេចចិត្ត។
- កុមារដែលមានអាយុចន្លោះពី ៨ ឆ្នាំ និង ១៤ ឆ្នាំ អាចចូលរួមក្នុងដំណើរការនៃការធ្វើការសម្រេចចិត្តយ៉ាងសំខាន់ ប៉ុន្តែភាពចាស់ទុំត្រូវតែវាយតម្លៃលើលក្ខណៈមូលដ្ឋានរបស់បុគ្គល។
- កុមារដែលមានអាយុតិចជាង ៨ ឆ្នាំមានសិទ្ធិក្នុងការផ្តល់គំនិតរបស់ពួកគេ និងស្តាប់។ ពួកគេអាចចូលរួមក្នុងកម្រិតជាក់លាក់ ប៉ុន្តែត្រូវបានណែនាំឱ្យប្រុងប្រយ័ត្នចំពោះបន្ទុកពួកគេដោយផ្តល់ឱ្យពួកគេនូវអារម្មណ៍ក្នុងការទទួលខុសត្រូវចំពោះការសម្រេចចិត្ត។
- ការសម្រេចចិត្តរបស់កុមារត្រូវតែទទួលការគោរព និងអាស្រ័យទៅតាមករណីនីមួយៗស្របតាមអាយុ កម្រិតនៃភាពចាស់ទុំ និងដំណាក់កាលអភិវឌ្ឍន៍ និងកត្តាវប្បធម៌ ប្រពៃណី និងបរិយាកាសរបស់ពួកគេ ហើយឧត្តមប្រយោជន៍របស់កុមារ គឺជាមូលដ្ឋានដ៏សំខាន់បំផុតក្នុងរាល់ការសម្រេចចិត្តទាំងអស់។

**ការណែនាំអំពីការប្រាស្រ័យទាក់ទងកុមារមេត្រី**

ចំណាយពេលដើម្បីស្វែងយល់ពីកុមារ កសាងទំនាក់ទំនងជាមួយកុមារដោយពិភាក្សាអំពីរឿងផ្សេងៗ ក្រៅពីមូលហេតុមកជួបពួកគេ (ឧ. សាលារៀន ទម្លាប់ បងប្អូនបង្កើត) សម្របយុទ្ធសាស្ត្ររបស់អ្នកឲ្យស្របនឹងអាយុ (លេងជាមួយកុមារតូចៗ គូរគំនូរ និងនិយាយជាមួយកុមារធំជាង និងមនុស្សពេញវ័យ)។
លៃតម្រូវខ្លួនរបស់អ្នកឲ្យត្រូវនឹងកម្ពស់កុមារ (អង្គុយដូច្នេះ អ្នកមិនខ្ពស់ជាងកុមារទេនៅពេលនិយាយជាមួយពួកគេ អង្គុយចុះ ហើយលេងនៅលើឥដ្ឋជាមួយកុមារតូចៗ អង្គុយនៅលើឥដ្ឋ ឬអង្គុយនៅលើកៅអីទាបជាមួយកុមារតូចៗ។ល។)
ជានិច្ចកាល ការនិយាយស្តីអាចមិនមានប្រសិទ្ធភាពចំពោះកុមារ ស្វែងរកវិធីប្រាស្រ័យទាក់ទងផ្សេង (ដូចជា ការគូរគំនូរ សម្ភារសិល្បៈ ការលេង) ស្វែងយល់ពីទម្រង់នៃការប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាពបំផុតជាមួយកុមារ។
កុមារខ្លះមានអារម្មណ៍កាន់តែមានផាសុកភាពជាមួយអ្នកថែទាំដែលមានវត្តមាននៅក្នុងបន្ទប់ រហូតដល់កុមារមានជំនឿលើអ្នក។
វាជារឿងធម្មតាសម្រាប់កុមារក្នុងការផ្តល់ព័ត៌មានបន្តិចជាមុន សិនដើម្បីឲ្យដឹងពីប្រតិកម្មរបស់មនុស្សពេញវ័យ និងផ្តល់ព័ត៌មានលម្អិតកាន់តែច្រើននៅដែលពេលពួកគេមានអារម្មណ៍សុវត្ថិភាពតែងតែនៅក្នុងមណ្ឌលជនរងគ្រោះ ហើយឲ្យកុមារសម្តែងមតិរបស់ពួកគេផ្ទាល់ហាមបង្ខំ/ប្រញាប់ជំរុញកុមារឲ្យនិយាយ។
ត្រូវផ្តល់ព័ត៌មានចាំបាច់សមស្របតាមអាយុ និងជៀសវាងការលាក់ព័ត៌មានពីកុមារ។

ការយល់ព្រមពាក់ព័ន្ធនឹងកុមារ និងមនុស្សពេញវ័យកើតឡើងមានបីកំរិត៖

ក. ការយល់ព្រមសម្រាប់ការគ្រប់គ្រងវេជ្ជសាស្ត្រតែប៉ុណ្ណោះ

ខ. ការយល់ព្រមសម្រាប់ការគ្រប់គ្រងវេជ្ជសាស្ត្រ និងការគ្រប់គ្រងកោសល្យវិច័យ

គ. ការយល់ព្រមសម្រាប់ការគ្រប់គ្រងវេជ្ជសាស្ត្រ ការគ្រប់គ្រងកោសល្យវិច័យ និងការបញ្ជូនទៅប៉ូលិស។

### *៣.៤.៤.៣ ការពិនិត្យប្រវត្តិជំងឺសម្រាប់កុមារ*

ការពិនិត្យប្រវត្តិជំងឺគឺមិនដូចនឹងការសម្ភាសកុមារអំពីការចោទប្រកាន់ទៅលើការរំលោភបំពានទេ។ការពិនិត្យប្រវត្តិជំងឺគឺដើម្បីប្រមូលព័ត៌មានសម្រាប់ការព្យាបាលវេជ្ជសាស្ត្រ និងដើម្បីប្រមូលការពិនិត្យកោសល្យវិច័យ។ ល្អបំផុត ប្រវត្តិជំងឺគួរតែទទួលបានពីអ្នកថែទាំ ឬនរណាម្នាក់ដែលស្គាល់កុមារច្បាស់ ជាជាងទទួលបានពីកុមារផ្ទាល់ ប៉ុន្តែការធ្វើបែបនេះប្រហែលជាធ្វើទៅមិនរួច។ កុមារដែលមានអាយុច្រើន ជាពិសេស មនុស្សពេញវ័យជាញឹកញាប់មានការខ្មាស់អៀន ឬអៀន នៅពេលសាកសួរឱ្យនិយាយអំពីបញ្ហានៃលក្ខណៈរួមភេទ។ យកល្អគួរសួរថា តើកុមារចង់ឱ្យមានមនុស្សធំ ឬមាតាបិតានៅជាមួយឬទេ។ មនុស្សពេញវ័យចូលចិត្តនិយាយដោយសេរីនៅពេលនៅម្នាក់ឯង។

នៅពេលប្រមូលពត៌មានពីកុមារ សូមចាប់ផ្តើមជាមួយនឹងសំណួរទូទៅដែលមិនមានការគំរាមកំហែងសិន បន្ទាប់មកអាចបន្តទៅបញ្ហាដែលអាចបង្កភាពតានតឹង។

- "តើអ្នករៀនថ្នាក់ទីប៉ុន្មាន?"
- "តើអ្នកមានបងប្អូនស្រីប្រុសប៉ុន្មាននាក់?"

បើអាច គួរតែបំពេញការពិនិត្យប្រវត្តិជំងឺលម្អិតខាងក្រោម។ ប៉ុន្តែ សំណួរអប្បបរមាដែលបានទទួលគួរតែជាសំណួរ *នៅក្នុងប្រវត្តិសុខភាពសំខាន់សម្រាប់កុមារ*

#### ៣.៤.៤.៣.១ ពត៌មានទូទៅ

- ឈ្មោះ អាស័យដ្ឋាន កន្លែងស្នាក់នៅ លេខទូរស័ព្ទ ភេទ ថ្ងៃខែឆ្នាំកំណើត (ឬអាយុ)
- សុខភាពទូទៅ
    - សូមប្រាប់ខ្ញុំអំពីសុខភាពទូទៅរបស់អ្នកបានទេ?
    - តើថ្មីៗនេះអ្នកដែលធ្លាប់មកជួបនឹងវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក-យិកាឬទេ?
    - តើអ្នកធ្លាប់ធ្វើរោគវិនិច្ឆ័យជំងឺណាមួយទេ?
    - តើអ្នកធ្លាប់វះកាត់ឬទេ?
    - តើអ្នកមានឆ្លងជំងឺអ្វីទេ?
    - តើមានអាលែកហ្ស៊ី/ប្រតិកម្មអ្វីទេ?
    - តើអ្នកថ្មីៗមានពិសារថ្នាំដែរឬទេ?

### ៣.៤.៤.៣.២ ការបរិយាយអំពីហេតុការណ៍

ជាការសំខាន់ដែលអ្នកផ្តល់ការថែទាំសុខភាពដឹងពីព័ត៌មានលម្អិតអំពីអ្វីដែលបានកើតឡើងដើម្បីពិនិត្យរករបួសដែលអាចមាន៖

- បរិយាយអំពីអ្វីដែលបានកើតឡើង ហើយកត់ត្រាកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង។
- សួរព័ត៌មានអំពីចារី (ប្រុស ស្រី អាយុ ទីកន្លែង)។
- តើការបំពានកើតឡើងនៅពេលណា?
- តើមានការស៊កបញ្ចូលដែរទេ (មាត់ទ្វារមាសឬរន្ធគូទ?)
- តើអ្នកបំពានបានបង្ខំខាងរាងកាយ ឬផ្លូវចិត្តឬទេ?
- តើអ្នកបំពានបានប្រើវត្ថុអ្វីទេ? តើមានអ្នកបំពានប៉ុន្មាននាក់នៅទីនោះ?
- តើវាជាការបំពានតែម្តង ឬបន្តមាននៅប៉ុន្មានម៉ោងក្រោយ ឬប៉ុន្មានថ្ងៃក្រោយទៀត?
- តើកុមារបានបាត់បង់ស្មារតីដែរឬទេ ហើយតើជនរងគ្រោះស្គាល់អ្នកបំពានដែរឬទេ?
- តើកុមារធ្វើអ្វីបន្ទាប់ពីហេតុការណ៍បានកើតឡើង? សួរថាតើកុមារបានងូតទឹក នោម ក្អួត។ល។ ចាប់តាំងពីមានហេតុការណ៍ដែរឬទេ។ វាអាចប៉ះពាល់ដល់ការប្រមូលភស្តុតាងកោសល្យវិច័យ។

**ប្រវត្តិសុខភាពសំខាន់សម្រាប់កុមារ**

ព័ត៌មានខាងក្រោមនេះមានសារសំខាន់សម្រាប់ប្រវត្តិសុខភាព៖

- តើរឿងនេះកើតឡើងនៅពេលណា? តើអ្នកចាំថា លើកដំបូងកើតឡើងនៅពេលណា? កុមារតូចៗមិនចងចាំពេលវេលាជាក់លាក់ទេ
- តើមានការគំរាមកំហែងចំពោះអ្នកឬ?
- តើគេប៉ះឬធ្វើឲ្យខ្លួនរបស់អ្នកឈឺត្រង់កន្លែងណា?
- តើអ្នកមានការឈឺចាប់នៅគូទ ឬកន្លែងប្រដាប់បន្តពូជរបស់អ្នកឬ?
- តើមានឈាមប្រឡាក់ខោក្នុង ឬបង្គន់ទេ?
- តើមានការលំបាក ឬឈឺចាប់មិនអាចបន្ទោរបង់ឬឈឺចាប់ពេលបន្ទោរបង់ឬទេ?
- រយៈពេលមករដូវដំបូងនិងកាលបរិច្ឆេទនៃរយៈពេលមករដូវចុងក្រោយ(សម្រាប់នារី)?
- ព័ត៌មានលម្អិតនៃសកម្មភាពរួមភេទពីមុន (ពន្យល់ពីមូលហេតុដែលអ្នកចាំបាច់ត្រូវសួរអំពីរឿងនេះ)
- ប្រវត្តិនៃការលាងសម្អាត ឬងូតទឹកតាំងពីការរំលោភបំពាន (ប្រសិនបើបានរួមភេទ)

### ៣.៤.៤.៣.២ ប្រវត្តិរោគស្ត្រី (កុមារក្រោយពេលចាប់ផ្តើមពេញវ័យ)

- កត់ត្រាកាលបរិច្ឆេទដំបូងនៃការមករដូវចុងក្រោយបង្អស់។
- សួរអំពីប្រវត្តិរួមភេទកាលពីពេលកន្លងមក និងថាតើពួកគេបានព្រមព្រៀងគ្នាដែរឬទេ។ ធ្វើការស្វែងយល់ថាតើជនរងគ្រោះធ្លាប់មានដៃគូស្និទ្ធស្នាលដែរឬទេ។
- សួរពីពេលដែលជនរងគ្រោះបានរួមភេទចុងក្រោយ និងមុនពេលហេតុការណ៍កើតឡើង។
- សួរជនរងគ្រោះថាតើធ្លាប់មានជំងឺកាមរោគកាលពីមុន និងបានព្យាបាលដែរឬទេ។
- សួរជនរងគ្រោះថាតើធ្លាប់ធ្វើតេស្តរកមេរោគអេដស៍ និងស្ថានភាពមេរោគអេដស៍ដែរឬទេ។
- សួរជនរងគ្រោះថាតើធ្លាប់មានផ្ទៃពោះដែរទេ។ បើមាន តើមានលទ្ធផលអ្វី។
- សួរប្រសិនបើកុមារប្រើប្រាស់ការការពារកំណើតឬទេ។ ប្រសិនបើដូច្នេះ ពួកគេបានប្រើប្រាស់វាចាប់តាំងពីពេលណា និងថាតើ ពួកគេបានប្រើប្រាស់វាជាប់លាប់ដែរឬទេ។

## ៣.៤.៥ ការពិនិត្យរាងកាយ

### *៣.៤.៥.១ ការពិនិត្យកុមារពីក្បាលដល់ចុងជើង*

ការពិនិត្យរាងកាយកុមារអាចធ្វើឡើងយោងតាមសេចក្តីសង្ខេបនៃទម្រង់ការសម្រាប់មនុស្សពេញវ័យក្នុងចំណុច ៣.៦.២ (ការពិនិត្យពីក្បាលដល់ចុងជើង)។

- សូមកត់ត្រាអាការៈទូទៅរបស់កុមារ
- ពិនិត្យសញ្ញាជីវិត
- កត់ត្រាកម្ពស់ និងទម្ងន់
- ពិនិត្យអវយវៈខាងលើនៅកន្លែងដែលរបួស
- ពិនិត្យមុខ ភ្នែក និងត្រចៀក
- នៅក្នុងមាត់ បំពង់កពិនិត្យមើលក្រអូមមាត់ ឬផ្នែកខាងក្រោយនៃបំពង់ក ហើយមើលថា មានការរហែកនៅភ្នាសរំអិលឬទេ។
- ចូរពិនិត្យស្នាមរបួសនៅស្បែកលលាដ៍ក្បាល និងសញ្ញារលាកផ្សេងៗ
- ពិនិត្យរកស្នាមជាំនៅលើកញ្ចឹង ក និងស្លាកស្នាមនៃការរំលោភសេពសន្ថវៈដែលគំរាមកំហែងដល់ជីវិត
- ពិនិត្យស្នាមខាំលើសុដន់ និងតួខ្លួន ឬកន្លែងរបួសផ្សេងៗ
- ចូរកត់ត្រាការអភិវឌ្ឍផ្លូវភេទរបស់កុមារ និងពិនិត្យមើលកន្លែងរបួសលើសុដន់។
- ធ្វើការពិនិត្យរបួសខាងក្នុង/ការមានផ្ទៃពោះលើផ្នែកពោះ និងទ្រូង
- ពិនិត្យអវយវៈខាងក្រោមឱ្យបានម៉ត់ចត់
- *ប្រសិនបើការធ្វើកោសល្យវិច័យផ្នែកវេជ្ជសាស្ត្រប្រមូលបានគំរូបង្ហាញដូចដែលអ្នកពិនិត្យលើជនរងគ្រោះដែលបានពិពណ៌នាខាងលើ*

### *៣.៤.៥.២ ការពិនិត្យប្រដាប់បន្តពូជ-រន្ធគូទរបស់ក្មេងស្រី (ប្រសិនបើមានការរំលោភសេពសន្ថវៈ ឬការចាប់រំលោភ)*

ចងចាំថា ក្នុងករណីភាគច្រើន ការពិនិត្យដោយឧបករណ៍បើកមាត់ស្បូន ក៏មិនអាចមើលឃើញដែរ។ វាបង្ហាញឱ្យឃើញតែពេលណាដែលមានការហូរឈាមនៅខាងក្នុងចេញពីរបួសទ្វារមាសដោយសារការស៊កបញ្ចូល។ ពន្យល់ពីទម្រង់ការដល់កុមារ ផ្តល់ព័ត៌មានលម្អិតអំពីជំហាននីមួយៗ។

- ពិនិត្យប្រដាប់បន្តពូជខាងក្រៅ
- ពិនិត្យបបូរមាត់យោនី និងរចនាសម្ពន្ធពាក់ព័ន្ធផ្សេងទៀត
- ក្នុងករណីនេះ ប្រសិនបើអាចធ្វើបាន ការប្រើឧបករណ៍បើកមាត់ស្បូន ត្រូវប្រើជាមួយថ្នាំសន្លប់
- ពិនិត្យរន្ធគូទដើម្បីរកមើលស្នាមជាំ ស្នាមដាច់រហែក ឬការហូរឈាម។ ជួយកុមារឱ្យគេងផ្ងារ ឬគេងផ្អៀងម្ខាង
- សម្រាប់ក្មេងស្រីតូចៗ ឧបករណ៍បើកមាត់ស្បូនសម្រាប់កុមារត្រូវបានណែនាំឱ្យប្រើ។

បើអាចធ្វើបាន ហាមធ្វើការពិនិត្យមាត់ស្បូនដោប្រើឧបករណ៍លើកុមារីដែលមិនទាន់ពេញវ័យ។ វាអាចឈឺចាប់ខ្លាំង និងបណ្តាលឱ្យមានរបួស។

### *៣.៤.៥.៣ ការពិនិត្យប្រដាប់បន្តពូជនិងរន្ធគូទរបស់ក្មេងប្រុស (បើមានការរំលោភសេពសន្ថវៈ ឬការចាប់រំលោភ)*

- ពិនិត្យមើលរបួសលើស្បែកដែលប៉ះជាមួយនឹងស្បែកចុងលិង្គ
- ពិនិត្យមើលទឹករំអិលនៅមាត់បំពង់បង្ហូរនោម (ចុងលិង្គ)

- សម្រាប់កុមារដែលមានអាយុច្រើន សូមទាញស្បែកនៃចុងលិង្គទៅក្រោយថ្នមៗដើម្បីពិនិត្យលិង្គ។ ហាមប្រើកម្លាំងខ្លាំង ដោយសារការធ្វើបែបនេះអាចបណ្តាលឱ្យរបួស ជាពិសេសសម្រាប់ក្មេងប្រុស
- ពិនិត្យរន្ធគូទ៖ រកមើលស្នាមជាំ ស្នាមដាច់រហែក ឬការហូរឈាម។ ជួយក្មេងប្រុសឱ្យគេងផ្ងារ ឬគេងផ្អៀងម្ខាង មិនត្រូវឱ្យក្មេងប្រុសលត់ជង្គង់ទេ ព្រោះនេះជាឥរិយាបទបំពានលើកុមារ
- ពិចារណាអំពីការពិនិត្យរន្ធគូទដោយប្រើប្រាស់ប្រព័ន្ធឌីជីថល បើជាការចាំបាច់តាមលក្ខណៈវេជ្ជសាស្ត្រ ព្រោះថាការពិនិត្យដែលមានការចាក់ទម្លុះ អាចនឹងបង្កឱ្យមានស្លាកស្នាមដូចជាការរំលោភបំពានដែរ។

### ៣.៤.៦ ការពិនិត្យរបស់មន្ទីរពិសោធន៍

ការពិនិត្យរបស់មន្ទីរពិសោធន៍ធ្វើឡើងដើម្បីជួយដោះស្រាយបញ្ហាផ្នែកវេជ្ជសាស្ត្រដែលបណ្តាលមកពីអំពើហឹង្សា និងដើម្បីប្រមូលភស្តុតាង។ ភស្តុតាងនៃការធ្វើកោសល្យវិច័យអាចប្រើប្រាស់សម្រាប់វេជ្ជសាស្ត្រ និងផ្នែកច្បាប់។

#### *៣.៤.៦.១ ការពិនិត្យរបស់មន្ទីរពិសោធន៍សម្រាប់ការគ្រប់គ្រងគ្លីនិកវេជ្ជសាស្ត្រជនរងគ្រោះ*

- **ទឹកនោម**
    - ការវិភាគទឹកនោម-ការថតឆ្លុះតាមមីក្រូទស្សន៍
    - ការធ្វើតេស្តរកការមានផ្ទៃពោះ
- **ឈាម**
    - ការធ្វើតេស្តរកមេរោគអេដស៍
    - កម្រិត អេម៉ូគ្លូប៊ីន
    - ការធ្វើតេស្តមុខងារថ្លើម
    - ពិនិត្យរកមេរោគស្វាយ (VDRL)

#### *៣.៤.៦.២ ការពិនិត្យរបស់មន្ទីរពិសោធន៍សម្រាប់ការធ្វើកោសល្យវិច័យផ្នែកវេជ្ជសាស្ត្រ*

- ការវិភាគទឹកនោមសម្រាប់មើលកោសិកាអេពីតេល្យ៉ូម
- ការត្បាល់យកសំណាកទឹកកាមនៅលើទ្វារមាសដើម្បីធ្វើជាភស្តុតាង

### ៣.៤.៧ ការព្យាបាល

#### *៣.៤.៧.១ ការព្យាបាលរបួសរាងកាយ*

- រាល់កុមាររងគ្រោះគួរត្រូវបានព្យាបាលជាបន្ទាន់ និងមិនត្រូវរង់ចាំ
    - បញ្ជូនអ្នកដែលមានស្ថានភាពធ្ងន់ធ្ងរទៅរកការព្យាបាលជាបន្ទាន់
    - ព្យាបាលរបួសដែលមិនសូវធ្ងន់ធ្ងរ យោងតាមពិធីសារបទដ្ឋាន

របួសរាងកាយខ្លះបណ្តាលឱ្យស្បែក និងភ្នាសរំអិលរហែក សូមចាក់វ៉ាក់សាំងការពារជំងឺតេតាណូស០.៥ ម.ល.យោងតាមកាលវិភាគក្នុងតារាងខាងក្រោម។

| កាលវិភាគកម្រិតថ្នាំដែលត្រូវប្រើ | កាលវិភាគនៃការចាក់ | រយៈពេលនៃការស៊ាំនឹងមេរោគ |
|---|---|---|

| | | |
|---|---|---|
| កំរិតវ៉ាក់សាំងតេតាណូសលើកទី១ | ការចាក់លើកដំបូង | មិនមាន |
| កំរិតវ៉ាក់សាំងតេតាណូសលើកទី២ | មួយខែបន្ទាប់ពីការចាក់លើកដំបូង | ចាប់ពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ |
| កំរិតវ៉ាក់សាំងតេតាណូសលើកទី៣ | មួយខែបន្ទាប់ពីការចាក់លើកទី២ | ៥ ឆ្នាំ |
| កំរិតវ៉ាក់សាំងតេតាណូសលើកទី៤ | មួយឆ្នាំបន្ទាប់ពីការចាក់លើកទី៣ | ១០ ឆ្នាំ |
| កំរិតវ៉ាក់សាំងតេតាណូសលើកទី៥ | មួយឆ្នាំបន្ទាប់ពីការចាក់លើកទី៤ | ២០ ឆ្នាំ |

ការពារជំងឺតេតាណូសគួរផ្តល់ជូនជនរងគ្រោះដោយអំពីហឹង្សាផ្លូវភេទ (គ្រប់ភេទ និងអាយុ) ប្រសិនបើមានរបួសកើតមានលើស្បែក និង/ឬភ្នាសរំអិល។

### *៣.៣.៧.២ ការព្យាបាលសុខភាពដោយការបង្ការ*

អាស្រ័យលើអាយុ បទពិសោធន៍របស់កុមារី ហើយប្រសិនបើនាងជាជនរងគ្រោះកំពុងមានរដូវ ត្រូវផ្តល់ការព្យាបាលបង្ការរបួស មេរោគអេដស៍ ជំងឺកាមរោគ និងការបង្ការការមានផ្ទៃពោះ។

### ៣.៣.៧.២.១ គោលការណ៍ណែនាំសម្រាប់ការបង្ការមេរោគអេដស៍

វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ គឺដើម្បីបង្ការមេរោគអេដស៍គួរតែចាប់ផ្តើមភ្លាមរហូតដល់ ៧២ ម៉ោង បន្ទាប់ពីបានប៉ះពាល់មេរោគអេដស៍។ វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍បានណែនាំឱ្យស្ត្រីនិងកុមារដែលប្រឈមនឹងហានិភ័យនៃការឆ្លងមេរោគអេដស៍។ និយាយជាមួយនឹងស្ត្រី ឬកុមារ (ឪពុកម្តាយ/អាណាព្យាបាល) ថាតើវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍សាកសមនឹងស្ថានភាពពួកគាត់ឬទេ។ អ្នកគួរពិចារណាអំពីវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ប្រសិនបើ៖

- ចារីគឺជាអ្នកដែលបានឆ្លងមេរោគអេដស៍ ឬមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍
- កុមារមិនបានដឹងអំពីលទ្ធផលមេរោគអេដស៍វិជ្ជមាន
- កុមារដែលបានប៉ះពាល់ឈាម ឬទឹកកាម
- កុមារដែលធ្លាប់បានរួមភេទតាមមាត់ ទ្វារមាស និង/ឬតាមរន្ធគូទ

គោលការណ៍ណែនាំសម្រាប់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍គួរផ្អែកលើគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមេរោគអេដស៍ និងជំងឺអេដស៍ថ្នាក់ជាតិបច្ចុប្បន្ន។ កុមារអាចប្រើថ្នាំដូចៗគ្នា ប៉ុន្តែត្រូវមើលតាមទម្ងន់ និង/ឬផ្ទៃរបួស។ ចងចាំថា ប្រសិនបើពន្យារពេលនៃចាប់ផ្តើមធ្វើការការពារមេរោគអេដស៍កាន់តែយូរ នោះប្រសិទ្ធភាពនៃនីតិវិធីកាន់តែថយចុះ។

- វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍គួរចាប់ផ្តើមអនុវត្តក្នុងអំឡុងពេល ៧២ ម៉ោង។
- ការពិគ្រោះអំពីមេរោគអេដស៍មុន និងក្រោយការធ្វើតេស្តគួរចាប់ផ្តើមធ្វើមុន និងក្រោយការធ្វើតេស្តរកមេរោគអេដស៍បានបញ្ចប់ជាបន្តបន្ទាប់។
- បើលទ្ធផលនៃការធ្វើតេស្តបង្ហាញថាអវិជ្ជមាន សូមផ្តល់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ក្នុងរយៈពេល ២៨ ថ្ងៃ ផ្តល់ការប្រឹក្សាយោបល់អំពីការលេបថ្នាំទៀងទាត់និងជាប់លាប់ មុនពេលប្រើប្រាស់ថ្នាំ។ សូមប្រាប់ជនរងគ្រោះថាវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍គឺគ្រាន់តែកាត់បន្ថយនូវការបំរែបំរួលមេរោគអេដស៍ ប្រាប់ជនរងគ្រោះអំពីផលរំខានចម្បងនៃថ្នាំ របៀបដោះស្រាយ រួមទាំងការថយចុះនៃផលរំខាននឹងបាត់ទៅវិញនៅពេលណាមួយ

- ប្រសិនបើលទ្ធផលបង្ហាញថាវិជ្ជមាន បញ្ឈប់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ដែលនេះបង្ហាញថាកុមាររងគ្រោះមានផ្ទុកមេរោគអេដស៍មុនពេលរងនូវការរងគ្រោះហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកដែលមានសេវាថែទាំនិងព្យាបាលមេរោគអេដស៍។
- ឈាមគួរត្រូវបានពិនិត្យមើល អេម៉ូគ្លូប៊ីន អាឡានីន អាមីណូត្រង់ហ្វេរ៉ាស(ALT) និងអាស្ពាតាតអាមីណូ ត្រង់ហ្វេរ៉ាស(AST)។

### ៣.៣.៧.២.២ គោលការណ៍ណែនាំសម្រាប់ការការពារការមានផ្ទៃពោះ

ក្មេងស្រីអាយុក្រោម ១៨ ឆ្នាំ ចាប់ផ្តើមមានរដូវដែលត្រូវបានចាប់រំលោភ ច្រើនបារម្ភថាគាត់នឹងមានផ្ទៃពោះ។ អ្នកផ្តល់ការថែទាំសុខភាពគួរសួរថា តើអ្នកជំងឺធ្លាប់បានប្រើប្រាស់មធ្យោបាយពន្យារកំណើតដែលមានប្រសិទ្ធភាពឬទេ ដូចជា ថ្នាំលេប ថ្នាំចាក់ កងដាក់ដៃ កងដាក់ក្នុងស្បូន ឬវិធីបញ្ឈប់កំណើតរបស់ស្ត្រី។ ប្រសិនបើដូច្នេះ គាត់មិនអាចមានផ្ទៃពោះទេ។ ប្រសិនបើគាត់មិនបានប្រើប្រាស់មធ្យោបាយពន្យារកំណើតឱ្យមានប្រសិទ្ធភាព នោះការការពារកំណើតបន្ទាន់គួរផ្តល់ទៅឱ្យអ្នកមិនទាន់មានផ្ទៃពោះ និងស្ត្រីដែលស្ថិតក្នុងវ័យអាចមានផ្ទៃពោះ។

- គោលការណ៍នៃការធ្វើតេស្តរកការមានផ្ទៃពោះគួរធ្វើឡើងដំបូងគេទន្ទឹមនឹងនេះគឺមិនគួរពន្យារពេលនៃផ្តល់ការការពារកំណើតបន្ទាន់ទេ
- ការការពារកំណើតមានប្រសិទ្ធភាពខ្ពស់នៅពេលដែលប្រើប្រាស់ក្នុងរយៈពេល ១២០ ម៉ោង (៥ ថ្ងៃ) នៃការរំលោភសេពសន្ថវៈ។
- ការធ្វើតេស្តការមានផ្ទៃពោះមួយផ្សេងទៀតគួរធ្វើឡើង ៦ សប្តាហ៍ បន្ទាប់ពីការចាប់រំលោភដើម្បីតាមដានថាតើពួកគេបានប្រើប្រាស់ការការពារកំណើតក្រោយពេលចាប់រំលោភដែរឬទេ។

**របបនិងកម្រិតថ្នាំផ្សេងៗទៀតសម្រាប់ការការពារកំណើតបន្ទាន់**

| | | |
|---|---|---|
| គ្រាប់ថ្នាំ Progestinតែមួយមុខ | Prostinor 2 | ១ គ្រាប់ ១២ ម៉ោង ពីគ្នា (សរុប ២ គ្រាប់) ឬ ២ គ្រាប់ក្នុងពេលតែមួយ |
| គ្រាប់ថ្នាំ Progestinតែមួយមុខ (1.5mg Levonorgestrel) | Norlevo | ១គ្រាប់ (លេបតែម្តង) |
| ថ្នាំគ្រាប់ដែលមានអ័រម៉ូនលាយបញ្ចូលគ្នារួមជាមួយនឹងអ័រម៉ូន អឺស្ត្រូសែនដែលមានកំរិតខ្ពស់(៥០ µg) | Euginonl | ២ គ្រាប់ ១២ ម៉ោង ពីគ្នា (សរុប ៤ គ្រាប់) |
| ថ្នាំគ្រាប់ដែលមានអ័រម៉ូនលាយបញ្ចូលគ្នារួមជាមួយនឹង អ័រម៉ូន អឺស្ត្រូសែនដែលមានកំរិតទាប(៣០ µg) | Nordette Microginon | ៤ គ្រាប់ ១២ ម៉ោង ពីគ្នា (សរុប ៨ គ្រាប់) |

ចំណាំ៖ ជនរងគ្រោះអាចជ្រើសរើសយករបៀបណាមួយក្នុងចំណោម៤វិធីខាងលើ។

### ៣.៣.៧.៣.៣ ការការពារជំងឺកាមរោគ

កុមារដែលរងការរំលោភសេពសន្ថវៈ គួរទទួលបានថ្នាំអង់ទីប៊ីយ៉ូទិក និងព្យាបាលជំងឺកាមរោគ សិរមាន់ ជំងឺប្រមេះទឹកបាយ ប្រមេះថ្លា និងជំងឺស្វាយ។

- ផ្តល់ការព្យាបាលភ្លាមៗ

- មិនចាំបាច់ធ្វើតេស្តជំងឺកាមរោគមុនពេលព្យាបាល
- ផ្តល់ការព្យាបាលដោយការការពារតាមរយៈថ្នាំអង់ទីប៊ីយ៉ូទិកចំពោះជំងឺកាមរោគ។

**ថ្នាំដែលប្រើប្រាស់សម្រាប់ការពារជំងឺកាមរោគ**

| | | |
|---|---|---|
| កុមារ | Amoxycillin | 15 mg/kg TDS ក្នុងមួយសប្តាហ៍ |
| | Erythomycin | 10 mg/kg QDS ក្នុងមួយសប្តាហ៍ |

## ៣.៤.៨ តាមដានការព្យាបាល និងការបញ្ជូនទៅមន្ទីរពេទ្យបង្អែក

### *៣.៤.៨.១ តាមដានការព្យាបាល*

បន្ទាប់ពីពិនិត្យ អ្នកផ្តល់សេវារោគវិនិច្ឆ័យ និងការព្យាបាលសុខភាពគួរៈ

- ធ្វើផែនការតាមដានកុមាររងគ្រោះអាស្រ័យលើការព្យាបាលដែលត្រូវធ្វើឡើងតាមពេលកំណត់។
- ធ្វើផែនការបញ្ជូនទៅមន្ទីរពេទ្យបង្អែក និងតាមដានកុមារដើម្បីទទួលសេវាពីប៉ូលិស និងផ្នែកច្បាប់។
- បញ្ជូនកុមាររងគ្រោះទៅសេវាកម្មផ្សេងទៀត។
- តាមដានភស្តុតាងវេជ្ជសាស្រ្តផ្នែកច្បាប់ និងកោសល្យវិច័យ

### *៣.៤.៨.២ ការបញ្ជូនជនរងគ្រោះសម្រាប់ការជួយអន្តរាគមន៍ផ្នែកច្បាប់ និងសេវាពហុវិស័យ*

#### ៣.៤.៨.២.១ ការឆ្លើយតបផ្នែកច្បាប់

កុមាររងគ្រោះគួរត្រូវបានរាយការណ៍ទៅអាជ្ញាធរក្នុងមូលដ្ឋាន(រក្សាការសម្ងាត់)។ ជម្រើសសម្រាប់ការរាយការណ៍បទល្មើសមានដូចជា៖

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ
- (នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់)
- នគរបាលប្រឆាំងការជួញដូរមនុស្ស
- កងរាជអាវុធហត្ថ
- ប្រធានភូមិ មេឃុំចៅសង្កាត់
- មន្ត្រីសង្គមកិច្ចនៃក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា
- ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី
- ព្រះរាជអាជ្ញាអមសាលាដំបូង រាជធានី ខេត្ត

ក្នុងករណីធ្ងន់ធ្ងរដែលសមាជិកគ្រួសារ ឬអ្នកថែទាំកុមារគឺជាជនសង្ស័យរំលោភបំពានលើកុមារ នោះគួរជៀសវាងបញ្ជូនកុមារត្រឡប់ទៅផ្ទះវិញ។ក្នុងករណីទាំងនេះដំណោះស្រាយដោយផ្អែកទៅលើក្រុមគ្រួសារគួរត្រូវបានគិតពិចារណាជាជំរើសដំបូងនិងការថែទាំលំនៅដ្ឋានគួរត្រូវបានជៀសវាង លើកលែងតែជាជម្រើសចុងក្រោយបង្អស់ និងក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។

#### ៣.៣.៨.២.២ ការគាំទ្រនិងសេវាសហគមន៍ផ្សេងទៀតសម្រាប់កុមាររងគ្រោះ

ជំនាញបានរកឃើញថាស្ត្រីនិងកុមាររងគ្រោះត្រូវការធនធាន និងការគាំទ្រជាច្រើនផ្អែកលើស្ថានភាពរបស់ពួកគេ និងប្រភេទនៃអំពើហឹង្សាដែលបានជួបប្រទះ។ សេវាទាំងនេះរួមមានសេវាដោះស្រាយវិបត្តិ គាំទ្រផ្នែកចិត្តសាស្ត្រសង្គម និងប្រឹក្សាយោបល់ ព្យាបាលសុខភាពក្រោយចេញពីកន្លែងព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម។

សេវាកម្មខ្លះត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាល និងសេវាកម្មខ្លះទៀតផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល។ កន្លែងព្យាបាលសុខភាពគួរប្រមូលធនធានដែលមាននៅក្នុងរាជធានី ខេត្ត ស្រុក ខណ្ឌ ក្រុង ឃុំ សង្កាត់ នូវធនធានព្យាបាលដែលមាន។ ជាការល្អបំផុតក្នុងការមានកិច្ចព្រមព្រៀងបញ្ជូនជាផ្លូវការជាមួយនឹងអ្នកផ្តល់សេវាថែទាំ និងប្រព័ន្ធអំពីរបៀបដែលជនរងគ្រោះទទួលយកសេវានោះ។

ឧទាហរណ៍នៃសេវាកម្មដូចជា៖

**គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ៖** ជនបង្គោលសម្រាប់ស្ត្រី និងកុមារមានតួនាទីឆ្លើយតប និងបញ្ជូនស្ត្រីនិងកុមារដែលទទួលរងអំពើហឹង្សាទៅអង្គភាពពាក់ព័ន្ធ ឬធនធានសហគមន៍។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** មន្ត្រីសង្គមកិច្ចនៃក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាអាចជួយបញ្ជូនកុមារទៅកន្លែងថែទាំផ្សេងទៀត និងបញ្ជូនទៅរស់នៅក្នុងសហគមន៍វិញ។

**មន្ទីរកិច្ចការនារី៖** មន្ត្រីនៃមន្ទីរកិច្ចការនារីអាចជួយបញ្ជូនកុមាររងគ្រោះដោយសារអំពើហឹង្សាទៅរកសេវាសង្គ្រោះមានដូចជានគរបាលយុត្តិធម៌សម្រាប់ការគាំពារស្របច្បាប់នៅមន្ទីរកិច្ចការនារីប្រចាំខេត្ត។

**មណ្ឌលស្នាក់នៅមានសុវត្ថិភាព៖** អង្គការសង្គមស៊ីវិលមួយចំនួនផ្តល់ទីជម្រកសុវត្ថិភាពសម្រាប់ស្ត្រី និងកុមាររងគ្រោះដោយសារអំពើហឹង្សា។ មណ្ឌលស្នាក់នៅភាគច្រើនស្ថិតនៅទីប្រជុំជន ហើយជនរងគ្រោះអាចបន្តស្នាក់នៅរយៈពេលយូរបាន។ ជាទូទៅ មណ្ឌលស្នាក់នៅផ្តល់សេវាគាំទ្រផ្សេងទៀតដូចជាការផ្តល់យោបល់ ព័ត៌មានស្របច្បាប់ ការគាំទ្រ និងការគាំពារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាសមារណកម្ម។

**ព័ត៌មានស្របច្បាប់ ការគាំទ្រ និងការគាំពារ៖** ព័ត៌មានស្របច្បាប់ ការគាំទ្រ និងការគាំពារផ្តល់ដោយភ្នាក់ងារនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី (ថ្នាក់ខេត្ត) និងអ្នកផ្តល់សេវារបស់អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត។ នេះអាចជាទម្រង់នៃព័ត៌មាន តំណាង ឬការគាំពារ និងការគាំទ្រនៅពេលជនរងគ្រោះស្ថិតក្នុងដំណើរការស្របច្បាប់។

**ការពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រសង្គម និងការគាំទ្រផ្លូវអារម្មណ៍៖** ការពិគ្រោះផ្នែកចិត្តសាស្ត្រសង្គម និងការគាំទ្រផ្លូវអារម្មណ៍ជាច្រើនត្រូវបានផ្តល់។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនមានជំនាញក្នុងការពិគ្រោះផ្នែកចិត្តសាស្ត្រសង្គមជាច្រើនប្រភេទ ដូចជាការពិគ្រោះជាបុគ្គល ឬក្រុម និងផ្សេងទៀតដែលជាផ្នែកមួយនៃសេវាកម្ម។

**ការពង្រឹងអំណាចផ្នែកសេដ្ឋកិច្ច៖** ទាំងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងរបស់រដ្ឋាភិបាល ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារីផ្តល់ការបណ្តុះបណ្តាលសម្រាប់ស្ត្រីរងគ្រោះ ក្នុងគោលបំណងលើកកម្ពស់ការពង្រឹងអំណាចផ្នែកសេដ្ឋកិច្ច។ សេវាខ្លះផ្តល់ជូននៅមជ្ឈមណ្ឌលរបស់អង្គការ ហើយសេវាខ្លះទៀតគឺជាសេវាដាច់ដោយឡែក។

**សមាហរណកម្ម៖**ស្ត្រីនិងកុមារដែលធ្លាប់រស់នៅក្នុងទីជម្រក ឬមណ្ឌលសុវត្ថិភាព ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាផ្តល់សេវាកម្មក្នុងការជួយជនរងគ្រោះឱ្យរួបរួមជាមួយសហគមន៍ដើម្បីត្រឡប់ទៅផ្ទះរបស់ពួកគេវិញ ឬសហគមន៍ផ្សេងទៀត។

### ៣.៤.៩ ការចងក្រងឯកសារ

អ្នកផ្តល់ការថែទាំសុខភាពត្រូវធានាថា៖

- បំពេញក្រដាសការងារដែលសំខាន់ ដូចជាបែបបទឯកសារស្តីពីអំពើហិង្សាលើស្ត្រី និងកុមារ
- អ្នកផ្តល់ការថែទាំសុខភាពត្រូវទទួលខុសត្រូវលើការរក្សាទុកបែបបទឯកសារ កំណត់ត្រាពេទ្យ និងសំណាកកោសល្យវិច័យ
- អ្នកផ្តល់ការថែទាំសុខភាពគួរតែរក្សាទុកក្រដាសឯកសារ និងទុកកំណត់ត្រាពេទ្យឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពសម្រាប់គោលបំណងសុវត្ថិភាព និងការប្រើប្រាស់នៅពេលអនាគត។

## ៤- ការធានាគុណភាព

### ៤.១ ទម្រង់ការនៃការធានាគុណភាព

ការធានាគុណភាពដើរតួយ៉ាងសំខាន់ក្នុងសេវាកម្មវេជ្ជសាស្ត្រចំពោះស្ត្រីនិងកុមាររងគ្រោះ។ គោលបំណងគឺដើម្បីធានាថាស្ត្រីនិងកុមាររងគ្រោះទទួលការឆ្លើយតបមានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ។ ការផ្តល់សេវាត្រួតពិនិត្យអំពើហិង្សាលើស្ត្រីនិងកុមារជាបន្តបន្ទាប់គឺជាការចាំបាច់។ ការគ្រប់គ្រងមណ្ឌលផ្តល់សេវាសុខភាពមានភារកិច្ចអនុវត្តទម្រង់ការធានាគុណភាព។

១) ពិនិត្យដំណើរការនិងឯកសារជាប្រចាំ៖

អ្នកផ្តល់ការថែទាំសុខភាពរួមមាន វេជ្ជបណ្ឌិត គិលានុបដ្ឋាក-យិកា និងឆ្មបដែលផ្តល់ការថែទាំ គួរតែពិនិត្យបែបបទយល់ព្រម និងឯកសាររបស់ស្ត្រីនិងកុមាររងគ្រោះម្នាក់ៗ ហើយសួរសំណួរដូចខាងក្រោម៖

- តើអ្នកផ្តល់ការថែទាំសុខភាពបានប្រើប្រាស់បែបបទដែលមានលក្ខណៈស្តង់ដារដែរឬទេ?
- តើអ្នកផ្តល់ការថែទាំសុខភាពបានបំពេញបែបបទរួចរាល់ និងត្រឹមត្រូវដែរឬទេ?
- តើអ្នកផ្តល់ការថែទាំសុខភាពបានធ្វើតេស្តតាមស្តង់ដារនីមួយៗ និងកត់ត្រាសំណាកដែលបានយកដែរឬទេ?
- តើអ្នកផ្តល់ការថែទាំសុខភាពបានធ្វើការពិនិត្យតាមស្តង់ដារនីមួយៗដែរឬទេ?
- តើអ្នកផ្តល់ការថែទាំសុខភាពបានគ្រប់គ្រងការព្យាបាលតាមស្តង់ដារនីមួយៗ (រួមមាន ការការពារកំណើតបន្ទាន់ និងវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ដែរឬទេ)?
- តើអ្នកផ្តល់ការថែទាំសុខភាពបានពិគ្រោះជំងឺតាមស្តង់ដារនីមួយៗដែរឬទេ?
- តើអ្នកផ្តល់ការថែទាំសុខភាពបានធ្វើការបញ្ជូនបន្តតាមស្តង់ដារដែរឬទេ?

- តើមានបែបបទយល់ព្រមដែលបានចុះហត្ថលេខាដោយជនរងគ្រោះ (ឬអាណាព្យាបាល) នៅក្នុងឯកសារព្យាបាលដែរឬទេ? តើមានតម្រូវការផ្សេងសម្រាប់ហត្ថលេខានៅក្នុងឯកសារ (ពីអ្នកដែលមានភស្តុតាង ឬប្រមូលឯកសារសម្រាប់ការវាយតម្លៃ ឬសម្រាប់បញ្ជូនបន្តទៅឱ្យប៉ូលិស/តុលាការដែរឬទេ?
- តើភស្តុតាងទទួល បិទ និងរក្សាទុកដោយរបៀបណា?
- តើមានបណ្តាញគ្រប់គ្រងដែរឬទេ?
- តើអ្នកណាចងក្រងឯកសារអំពីរបួស និងតើចងក្រងឯកសារនេះយ៉ាងដូចម្តេច?
- តើនរណាគ្រប់គ្រងរបាយការណ៍វេជ្ជសាស្ត្រ និងមន្ទីរពិសោធន៍?

២) ក្នុងនាមជាក្រុមការងារនៃកន្លែងព្យាបាលសុខភាពគួរតែពិភាក្សាអំពីចំណុចខ្សោយ និងរៀបចំផែនការសកម្មភាពដើម្បីដោះស្រាយ។

៣) ជួបជាមួយនឹងអ្នកផ្តល់សេវាថែទាំសុខភាពក្រោយមានអំពើហឹង្សាទៅលើស្ត្រីនិងកុមារជាប្រចាំ ដូចជានគរបាលតុលាការ អង្គការមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហានានា និងកំណត់ចន្លោះពេលនិងធនធាននៅក្នុងការផ្តល់សេវាថែទាំសុខភាព។ ស្នើសុំព័ត៌មានត្រឡប់ស្តីពីគុណភាពនៃសេវាថែទាំសុខភាព។

៤) ធ្វើការវាយតម្លៃនៃការពេញចិត្តជាមួយជនរងគ្រោះ ដោយសួរថាតើពួកគេពេញចិត្តនឹងសេវាថែទាំសុខភាពដែរឬទេ និងតើពួកគេចូលចិត្តអ្វី ឬមិនចូលចិត្តអ្វី។

**ឧបសម្ព័ន្ធ ១៖ បែបបទយល់ព្រម**

ឈ្មោះកន្លែងព្យាបាលសុខភាព៖_______________________________________________

ខ្ញុំ..........................................................................អនុញ្ញាតឱ្យកន្លែងព្យាបាលសុខភាពដែលមានឈ្មោះខាងលើអនុវត្តដូចខាងក្រោម៖

| | មាន | មិនមាន |
|---|---|---|
| ធ្វើការពិនិត្យសុខភាព រួមមានការពិនិត្យអាងត្រគាក។ | | |
| ប្រមូលភស្តុតាង ដូចជាសំណាកសារធាតុរាវនៃរាងកាយ ការប្រមូលសំលៀកបំពាក់ ការសិតសក់ ការកោសយកសំណាក ឬការកាត់ក្រចកដៃ សំណាកឈាម និងរូបថត។ | | |
| ផ្តល់ភស្តុតាង និងព័ត៌មានសុខភាពទៅឱ្យប៉ូលិស និងតុលាការផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងសំណុំរឿងរបស់ខ្ញុំ ព័ត៌មាននេះនឹងត្រូវបានកំណត់ចំពោះលទ្ធផលនៃការពិនិត្យនេះ និងការថែទាំដែលពាក់ព័ន្ធនឹងការតាមដានសុខភាពដែលបានផ្តល់ឱ្យ។ | | |

បើសិនជាអនីតិជនចុះបញ្ជីឈ្មោះរបស់អនីតិជន _______________________________________

ហត្ថលេខា៖___________________________ កាលបរិច្ឆេទ៖ _______________________

សាក្សី៖ ___________________________ កាលបរិច្ឆេទ៖___________________________

# ឧបសម្ព័ន្ធ ២៖ គំនូស

## Sketch of person

Comments

Antertor view

Posterior view





## Female Genilalia



## Male Genitalia



## ឧបសម្ព័ន្ធ ៣៖ បែបបទនៃឯកសារអំពីអំពើហឹង្សាទៅលើស្ត្រីនិងកុមារ

| ព័ត៌មានទូទៅ | ឈ្មោះកន្លែងព្យាបាលសុខភាព៖ |
|---|---|
| នាមត្រកូល៖ | លេខចុះឈ្មោះជនរងគ្រោះ៖ |
| នាមខ្លួន៖ | ឈ្មោះមាតិបិតា ឬអាណាព្យាបាល (បើមានកូន) |
| ថ្ងៃខែឆ្នាំកំណើត<br>ថ្ងៃ ខែ ឆ្នាំ | ស្ថានភាពនៅលីវ៖<br>នៅលីវ☐រៀបការ ☐លែងលះ☐ |
| ភេទ៖ ប្រុស ☐ ស្រី ☐ | កន្លែងស្នាក់នៅ៖ |
| មុខរបរ៖ | លេខទំនាក់ទំនង៖ |
| សាក្សី (បើមាន) | ព័ត៌មានទំនាក់ទំនងផ្សេងៗ៖ |

**ឧបទ្ទវហេតុ**

**បរិយាយអំពីឧបទ្ទវហេតុរបស់ជនរងគ្រោះ៖**

| អំពើហឹង្សាលើរាងកាយ | មាន | មិនមាន | បរិយាយអំពីប្រភេទ និងទីតាំងនៅលើដងខ្លួន |
|---|---|---|---|
| ប្រភេទ (ការវាយ ការខាំ ការទាញសក់ ។ល។) | | | |
| ការប្រើប្រាស់ការរឹតត្បិត | | | |
| ការប្រើប្រាស់អាវុធ | | | |
| ពាក់ព័ន្ធនឹងគ្រឿងញៀន/គ្រឿងស្រវឹង | | | |

| ការជ្រៀតចូល | មាន | មិនមាន | មិនប្រាកដ | បរិយាយ (មាត់ ទ្វារមាស រន្ធគូទ ប្រភេទនៃវត្ថុ) |
|---|---|---|---|---|
| លិង្គ | | | | |
| ម្រាមដៃ | | | | |
| ផ្សេងទៀត (បរិយាយ) | | | | |
| | មាន | មិនមាន | មិនប្រាកដ | ទីតាំង (មាត់ទ្វារមាស រន្ធគូទ ផ្សេងទៀត) |
| ការចេញទឹកកាម | | | | |
| បានប្រើប្រាស់ស្រោមអនាម័យ | | | | |

**ប្រវត្តិវេជ្ជសាស្ត្រ**

| បន្ទាប់ពីឧបទ្ទវហេតុ តើជនរងគ្រោះ: | មាន | មិនមាន | | មាន | មិនមាន |
|---|---|---|---|---|---|
| ក្អួត? | | | ខ្ពុលមាត់? | | |
| បត់ជើងតូច? | | | ប្តូរសំលៀកបំពាក់? | | |
| បត់ជើងធំ? | | | លាងសម្អាត ឬងូតទឹក? | | |

| | | | | | |
|---|---|---|---|---|---|
| ដុសធ្មេញ? | | | ប្រើតំប៉ុង ឬទ្រនាប់? | | |

| | | | | | |
|---|---|---|---|---|---|
| **ការប្រើប្រាស់មធ្យោបាយពន្យារកំណើត** | | | | | |
| ថ្នាំលេប | | កងដាក់ក្នុងស្បូន | | វិធីបញ្ឈប់កំណើត | |
| ថ្នាំចាក់ | | ស្រោមអនាម័យ | | ផ្សេងទៀត | |

| | |
|---|---|
| **ប្រវត្តិមករដូវ/សម្រាលកូន** | |
| រយៈពេលមករដូវចុងក្រោយបង្អស់ (ថ្ងៃ ខែ ឆ្នាំ) | ការមានរដូវនៅពេលកើតហេតុការណ៍ មាន ☐ |
| ភស្តុតាងនៃការមានផ្ទៃពោះមាន ☐មិនមាន ☐ | ចំនួនសប្តាហ៍នៃការមានផ្ទៃពោះ ________ សប្តាហ៍ |
| ប្រវត្តិសម្រាលកូន | |

| | | |
|---|---|---|
| **ប្រវត្តិនៃការរួមភេទដែលមានការយល់ព្រម (ប្រសិនបើសំណាកត្រូវបានយកទៅវិភាគ DNA )** | | |
| ការរួមភេទដែលមានការយល់ព្រមក្នុងមួយសប្តាហ៍មុនពេលរំលោភបំពាន | កាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) | ឈ្មោះ៖ |
| **បញ្ហាសុខភាពដែលមានស្រាប់** | | |
| ប្រវត្តិនៃការកាត់អវយវៈប្រដាប់បន្តពូជស្ត្រី ប្រភេទ | | |
| អាលែកហ្ស៊ី/ប្រតិកម្ម | | |
| ការលេបថ្នាំបច្ចុប្បន្ន | | |

| **ស្ថានភាពការចាក់ថ្នាំវ៉ាក់សាំង** | **បានចាក់ថ្នាំវ៉ាក់សាំង** | **មិនបានចាក់ថ្នាំវ៉ាក់សាំង** | **មិនដឹង** | **មតិ** |
|---|---|---|---|---|
| តេតាណូស | | | | |
| ជំងឺរលាកថ្លើមប្រភេទ បេ | | | | |

| | | |
|---|---|---|
| **ស្ថានភាពមេរោគអេដស៍/ជំងឺអេដស៍** | ដឹង | មិនដឹង |

| | | |
|---|---|---|
| **ការពិនិត្យសុខភាព** | | |
| សភាពខាងក្រៅ (សំលៀកបំពាក់ សក់ ពិការភាពផ្នែករាងកាយ ឬផ្លូវចិត្ត) | | |
| សភាពផ្លូវចិត្ត (ធម្មតា យំ រសាប់រសល់ ពិបាកចិត្ត ផ្សេងៗ) | | |
| ទម្ងន់៖ | កម្ពស់៖ | ដំណាក់កាលពេញវ័យ (មុនពេញវ័យ ពេញវ័យ ភាពចាស់ទុំ)៖ |

| | | |
|---|---|---|
| ចង្វាក់ជីពចរ៖ | សម្ពាធឈាម៖ | អត្រាដង្ហើម៖ កម្តៅ៖ |

**លទ្ធផលពិនិត្យ**

រៀបរាប់តាមលំដាប់លំដោយ និងគូរលើគំនូសតាងរាងកាយដែលបានភ្ជាប់ ទីតាំងជាក់លាក់នៃរបួស ស្នាម ជាំ សញ្ញាទាំងអស់។ ល។ ប្រភេទឯកសារ ទំហំ ពណ៌ ទម្រង់ និងលក្ខណៈផ្សេងទៀត។ សូមពិពណ៌នា មិនត្រូវបកស្រាយលទ្ធផលឡើយ។

| |
|---|
| ក្បាល និងមុខមាត់ និងច្រមុះ |
| ភ្នែក និងត្រចៀកក |
| ទ្រូងខ្នង |
| ពោះគូទ |
| ដៃ និងប្រអប់ដៃជើង និងប្រអប់ជើង |

**ការពិនិត្យប្រដាប់បន្តពូជ និងរន្ធគូទ**

| | | |
|---|---|---|
| យោនី/ពងស្វាស | រន្ធអវយវៈ និងសន្ទះរន្ធយោនី | រន្ធគូទ |
| ទ្វាមាស/លិង្គ | កស្បូន | ការពិនិត្យប្រដាប់ភេទ/រន្ធយោនីនិងរន្ធគូទ |

**ឥរិយាបថរបស់អ្នកជំងឺ (ដេកផ្ងារ ផ្កាប់មុខ ឱបជង្គង់ ចំហៀង ដេកបញ្ឆិត)**

សម្រាប់ការពិនិត្យប្រដាប់បន្តពូជ៖សម្រាប់ការពិនិត្យរន្ធគូទ៖

| ការព្យាបាល | មាន | មិនមាន | ប្រភេទនិងមតិ |
|---|---|---|---|
| ការបង្ការ/ការព្យាបាលជំងឺកាមរោគ | | | |
| ការការពារកំណើតបន្ទាន់ | | | |
| ការព្យាបាលរបួស | | | |
| វិធីការពារជំងឺតេតាណូស | | | |
| វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ បេ | | | |
| វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដ | | | |
| ផ្សេងទៀត | | | |
| តើមានទទួលថ្នាំ/ការព្យាបាលអ្វីដែរឬទេ? | | | |

| ការស៊ើបអង្កេតក្នុងមន្ទីរពិសោធន៍ | មតិ |
|---|---|
| ការធ្វើតេស្តទឹកនោមរកការមានផ្ទៃពោះ: | |
| មីក្រូទស្សន៍ | |
| ផ្សេងទៀត | |
| សម្ភារគៀរសម្អាតមាត់ស្បូន ទឹកកាម | |
| វប្បធម៌ និងភាពរសើប | |
| ឈាម | |
| ភិនភាគនៃសាច់សាលោហិត | |

| | |
|---|---|
| បន្ទប់ពិសោធន៍ | |
| អង់ទីសែនការពារជំងឺរលាកថ្លើមប្រភេទ បេ | |
| រូបភាពឈាមពេញលេញ | |
| អេម៉ូគ្លូប៊ីន (HB) | |
| ការផ្គូផ្គង X | |
| សមាសធាតុគីមីក្នុងឈាម | |
| ការធ្វើតេស្តរកមេរោគអេដស៍ | |
| សម្ភារកៀរសម្អាតរន្ធគូទ | |
| ផ្សេងទៀត | |
| **ការបញ្ជូន និងការតាមដាន** | |

ស្ថានភាពផ្លូវចិត្តទូទៅ

ជនរងគ្រោះមានគម្រោងរាយការណ៍ទៅប៉ូលិស ឬបានធ្វើរបាយការណ៍មាន ☐មិនមាន ☐

| | |
|---|---|
| ជនរងគ្រោះមានកន្លែងត្រូវទៅ មាន ☐ មិនមាន ☐ | មាននរណាម្នាក់ទៅតាមគាត់<br><br>មាន ☐ មិនមាន ☐ |

ការពិគ្រោះដែលបានផ្តល់៖

ការបញ្ជូន

ការតាមដានត្រូវការ

កាលបរិច្ឆេទដែលត្រូវសួរសុខទុក្ខ

| | |
|---|---|
| ឈ្មោះវេជ្ជបណ្ឌិត៖ ____________________________<br><br>មុខងារ៖ ______________________________ | កាលបរិច្ឆេទ៖ ________________________________________ |

## ឧបសម្ពន្ធ ៤ ធនធានសហគមន៍

| ប្រភេទធនធាន | សេវាកម្មបានផ្តល់ | ទីតាំង | ព័ត៌មានទំនាក់ទំនង |
|---|---|---|---|
| មណ្ឌលស្នាក់នៅមានសុវត្ថិភាព | | | |
| មជ្ឈមណ្ឌលដោះស្រាយវិបត្តិ | | | |
| ការគាំទ្រ ឬជំនួយផ្នែកហិរញ្ញវត្ថុ | | | |
| ជំនួយ ឬព័ត៌មានស្របច្បាប់ | | | |
| ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម | | | |
| ការថែទាំសុខភាពផ្លូវចិត្ត | | | |
| ការថែទាំសុខភាពបឋម | | | |
| ការគាំទ្រសម្រាប់រកប្រាក់ចំណូល | | | |
| ផ្សេងទៀត | | | |
| | | | |
| | | | |
| | | | |

# បញ្ជីរាយឈ្មោះឯកសារពាក់ព័ន្ធ

Astbury, Jill, and Fareen Walji. Triple Jeopardy: Gender-based violence and human rights violatiosn experienced by women with disabilities in Cambodia. Phnom Penh: AusAID, 2013.

CARE. A Report on the Situation of Beer Promotion Women in the Workplace. Phnom Penh: CARE, 2005.

CDC. Adverse Childhood Experiences Study. Atlanta: National Centers For Injury Prevention and Control, CDC, 2006.

DRAFT VAC. Draft Findings Violence Against Children Survey Provided by UNICEF. Phnom Penh: MoWA and NIS, 2014.

Fulu, E., X Warner, S. Miedema, R. Jewkes, T. Roselli, and J. Lang. Why do some men use violence and how can we prevent it? Phnom Penh: UN Partners for Prevention, 2013.

ILO. Action-oriented research on gender equality and the working and living conditions of garent factory workers in Cambodia. Phnom Penh: ILO, 2012.

Menzel, Dr. Jorg. Support for MoWA Judicial Police Baseline Report. Phnom Penh: GIZ Access to Justice , 2011.

MOH and WHO. Health Service Delivery Profile Cambdia. Phnom Penh: WHO MOH, 2012.

MoWA. Feasibility Study for One Stop Service Center. Phnom Penh: MoWA, 2012.

MoWA. Follow Up Survey, Violence Against Women. Phnom Penh: MoWA, 2009.

NC for the Management of D&D Reform. The Functioning of Commune Committe for Women and Children. Phnom Penh: Royal Government of Cambodia, 2008.

NIS. CDHS. Phnom Penh: Ministry of Planning, 2005.

Perry, B D. "The Neurodevelopmetal Impact of Violence in Childhood." In Textbook of Child and Adolescent Experiences (ACE) Study, by D Schetky and E P Benedek, 221-238. Washington, DC: American Psychiatric Press, 2001.

USAID. The Clinical Manual for Children and Adolescents that Experience Sexual Violene. Washington, DC: AIDSTAR-One, 2013.

V J Feleti, et. al. "Relationship of Childhood Abuse an Household Dysfuction to Many of the Leading Causes of Death in Adults." American Journal of Preventive Medicine , 1998: 14:245-258.

WHO. Responding to intimate partner and sexual violence against women: Clinical and Policy Guidelines. Geneva: WHO, 2013.

World Health Organization. Intimate Partner and Sexual Violence Against Women. 2013.

http://www.who.int/mediacentre/factsheets/fs239/en/ (accessed December 27, 2013).

11 (V J Feleti 1998)

12 (CDC 2006)

15 Penal Code, article 239

2.4.3 First Line Support for intimate partner and sexual violence against women

2.4.3.1 General Considerations

- All health care providers should be able to provide basic First Line Support to VAW survivors;
- First-line support provides practical care and responds to the survivors' needs.
- VAW survivors undergo psychological distress, some immediately, while others may suffer in the short or long term;
- PEP should be initiated within 72 hours.
- HIV pre- and post-test counseling should be done before and after the HIV test is done, respectively.
- If test is negative give PEP for 28 days; provide adherence counseling for PEP before administering the drug; inform the survivor that PEP only reduces the changes of acquiring HIV; inform the survivor about potential side effects, how to deal with them, including that they will diminish with time.
- If the result is positive, discontinue the PEP, as this shows survivor had HIV prior to VAW incident and refer appropriately.